**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economiques

Royal university of Law and Economics


# សារណាបញ្ចប់ការសិក្សា

# ជម្លោះសមុទ្រចិនខាងត្បូងរវាង ចិន និងហ្វីលីពីន ក្នុងទិដ្ឋភាពច្បាប់អន្តរជាតិ

ស្រាវជ្រាវពីថ្ងៃទី០៣ ខែ មេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ លោក ពៅ សុភា

លោក ហ្លួច ជាម៉ិញ

ណែនាំដោយ

សាស្ត្រាចារ្យជំនួយ ដុំ អ៊ឹម


ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ

ជំនាន់ទី ២៣

ឆ្នាំចូលសិក្សា ២០១៩

ឆ្នាំសរសេរសារណា ២០២៣

# សេចក្ដីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **ឃួច ជាម៉ិញ** និងខ្ញុំបាទឈ្មោះ **ពៅ សុភា** ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី២៣ ឆ្នាំសិក្សា ២០១៩-២០២៣ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

សូមសម្ដែងនូវកតញ្ញូតាធម៌ សេចក្ដីគោរពដ៏ខ្ពង់ខ្ពស់ និងសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ៖

**លោកឪពុក** និង**អ្នកម្ដាយ** ជាអ្នកមានគុណនៃយើងមិនអាចកាត់ថ្លៃបាន នៃយើងខ្ញុំទាំងពីរ ដែលលោកទាំងទ្វេរបានផ្ដល់កំណើត ចិញ្ចឹមបីបាច់ ថែរក្សា អប់រំ និងផ្ដល់ដំបូន្មានល្អៗ ដោយចិត្តសន្ដោសប្រណីប្រកបដោយព្រហ្មវិហារធម៌ ព្រមទាំងហ៊ានលះបង់កាយចិត្ត លះបង់គ្រប់យ៉ាងដើម្បីឲ្យ កូនមានចំណេះដឹងខ្ពង់ខ្ពស់ និងចំណាយទាំងញើសឈាម និងថវិកាតាំងពីកូនចាប់កំណើតរហូតដល់ធំដឹងក្ដី ដើម្បីឲ្យកូនក្លាយជាមនុស្សល្អនៅក្នុងសង្គម។ ក្នុងនាមពួកយើងជាកូន ពុំមានអ្វីតបស្នងអ្នកមានគុណនោះទេ មានតែខិតខំប្រឹងប្រែងរៀនសូត្រឲ្យអស់ពីកម្លាំងកាយចិត្ត ដើម្បីកុំឲ្យការប្រឹងប្រែងរបស់អ្នកមានគុណក្លាយជាឥតន័យ។

**ឯកឧត្ដមសាកលវិទ្យាធិការ លុយ ចន្ណា** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានផ្ដល់ឱកាសដល់យើងខ្ញុំទាំងពីរ បានសរសេរសារណាបញ្ចប់ការសិក្សាមួយនេះ។

**លោកសាស្ត្រាចារ្យណែនាំ ជុំ អ៊ីម** ដែលលោកបានចំណាយពេលដ៏មានតម្លៃក្នុងការដឹកនាំដោយយកចិត្តទុកដាក់ពន្យល់ កែតម្រូវ ណែនាំ ផ្ដល់ចំណេះដឹងបន្ថែមដល់យើងទាំងពីរ នូវចំណុចដែលខ្វះខាត និងប្រាប់ពីរបៀបតាក់តែងឱ្យពួកយើងទាំងពីរងាយស្រួលឆ្ពោះទៅរកគោលដៅ និងទទួលបានជោគជ័យជាស្ថាពរ នៃការសរសេរសារណាបញ្ចប់ការសិក្សាមួយនេះ។

**លោកគ្រូ អ្នកគ្រូ** ទទួលបន្ទុកការិយល័យស្រាវជ្រាវ ដែលបានជួយពិនិត្យណែនាំ និងបង្ហាត់លើទម្រង់នៃកិច្ចការស្រាវជ្រាវមួយនេះពីដើមរហូតបានសម្រេចចេញជាសៀវភៅផ្លូវការ។

ជាចុងក្រោយ យើងខ្ញុំទាំងពីរអ្នកសូមលើកប្រាមដៃដប់ប្រណម្យបួងសួងដល់វត្ថុស័ក្តិសិទ្ធិទាំងអស់ក្នុងលោក សូមព្រះប្រទានពរជ័យ សិរីមង្គល ជូនដល់លោកអ្នកមានគុណទាំងអស់ សូមឲ្យអ្នកទាំងអស់ ជោគជ័យគ្រប់ភា-រកិច្ច ជាពិសេសជួបនូវពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ជម្លោះសមុទ្រចិនខាងត្បូងរវាងចិន និងហ្វីលីពីនជារឿយៗតែងបានបង្កឱ្យមានការប្រឈមមុខដាក់គ្នាក្នុងដែនទឹកមានជម្លោះ ជាហេតុបង្កនូវការគម្រាមកំហែងសន្តិសុខដល់ប្រទេសជាភាគី រួមទាំងតំបន់អាស៊ីអាគ្នេយ៍ដែលកម្ពុជាក៏ជាប្រទេសមួយនៅតំបន់នេះផងដែរ។ ជម្លោះដ៏រ៉ាំរ៉ៃ និងដែលនៅតែរកច្រកចេញពុំទាន់ឃើញនេះបានចោទជាសំណួរពីប្រសិទ្ធិភាពនៃការដោះស្រាយជម្លោះអន្តរជាតិដោយផ្អែកលើស្មារតីច្បាប់ និងស្មារតីកិច្ចសហប្រតិបត្តិការក្នុងការដោះស្រាយជម្លោះ ដោយការមិនប្រើប្រាស់កម្លាំង ដ្បិតទោះបីជាហ្វីលីពីនបានសម្រេចជ្រើសយកយន្តការតុលាការក្តី ក៏យើងសង្កេតឃើញថាវាហាក់គ្មានប្រសិទ្ធិភាពទៅលើការដោះស្រាយជម្លោះទាល់តែសោះ។ ដូច្នេះសារណានេះនឹងលើកយកមកនូវចំណុចគោលរួមក្នុងបរិបទមួយ ដែលនឹងព្យាយាមបកស្រាយបង្ហាញពីបុព្វហេតុនៃជម្លោះ រួមទាំងយន្តការច្បាប់ផ្សេងៗដែលធ្លាប់បានប្រើប្រាស់ ក៏ដូចជាយន្តការផ្សេងៗដែលគូភាគីអាចពិចារណាជ្រើសរើសដើម្បីជាមធ្យោបាយក្នុងការស្វែងរកច្រកចេញពីជម្លោះដ៏រ៉ាំរ៉ៃមួយនេះ ដោយសន្តិវិធី កិច្ចសហប្រតិបត្តការល្អ។

យ៉ាងណាមិញ ខ្លឹមសារនេះពុំទាន់មានភាពពេញលេញឥតខ្ចោះ និងល្អិតល្អន់គ្រប់ជ្រុងជ្រោយទៅលើជម្លោះរវាងចិន និងហ្វីលីពីនៅឡើយទេ ដ្បិតវានឹងបង្ហាញតែទិដ្ឋភាពធំជារួមប៉ុណ្ណោះដោយសារជម្លោះនេះមានបានប្រែប្រួល និងបត់បែនឥតឈប់ឈរទៅតាមការប្រែប្រួលភូមិសាស្ត្រនយោបាយសកល។ ហេតុនេះយើងខ្ញុំសូមខន្តីអភ័យទោសរាល់កំហុសឆ្គងដែលកើតមានឡើងដោយអចេតនា និងកាលបើមានភាពចន្លោះខ្វះខាតនូវត្រង់ពាក្យពេចន៍ ឬខ្លឹមសារណាមួយ។ យើងខ្ញុំសូមស្វាគមន៍នូវរាល់មតិរិះគន់កែលម្អ ដើម្បីជាប្រយោជន៍ក្នុងការពង្រឹង និងធ្វើឱ្យខ្លឹមសារនៃសារណានេះកាន់តែប្រសើរឡើងទៅមុខជាបន្តទៀត។

ជាចុងក្រោយយើងខ្ញុំសូមគោរពអរគុណលោកសាស្ត្រាចារ្យ **ជុំ អ៊ីម** ម្តងទៀតដែលលោកបានចំណាយគំនិត និងពេលវេលាណែនាំទូន្មានពួកខ្ញុំក្នុងការសម្រេចបានសារណាមួយនេះ។ ពួកយើងសង្ឃឹមថាលោគ្រូ អ្នកគ្រូសាស្ត្រាចារ្យ មិត្តនិស្សិត និងប្រិយមិត្តអ្នកអានទាំងអស់ជួបតែសេចក្តីសុខ និងសុភមង្គលកុំបីឃ្លៀងឃ្លាតឡើយ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃព្រហស្បតិ៍ ១០កើត ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

ភ្នំពេញ ថ្ងៃព្រហស្បតិ៍ ទី២៧ ខែកក្កដា ឆ្នាំ២០២៣

# មាតិកា

ទំព័រ


**តារាងសម្គាល់ពាក្យកាត់** ....... iii

**សេចក្តីផ្តើម** ....... ១

**ជំពូកទី១៖ សាវតា និងទិដ្ឋភាពទូទៅនៃជម្លោះ** ....... ៤

**ផ្នែកទី១៖ ប្រវត្តិ និងបុព្វហេតុបង្កជម្លោះ** ....... ៤

កថាខណ្ឌទី១៖ ជម្លោះប្រវត្តិសាស្រ្ត ....... ៥

កថាខណ្ឌទី២៖ បញ្ហានយោបាយ និងជម្លោះធនធានធម្មជាតិ ....... ១០

**ផ្នែកទី២៖ ស្ថានភាពទូទៅនៃតំបន់ជម្លោះ** ....... ១២

កថាខណ្ឌទី១៖ វឌ្ឍនភាពទូទៅនៃជម្លោះ ....... ១២

កថាខណ្ឌទី២៖ ភាពជាប់គាំង និងការមិនអាចដោះស្រាយបានតាមផ្លូវច្បាប់ ....... ១៤

**ជំពូកទី២៖ យន្តការ និងនីតិវិធីដែលធ្លាប់បានអនុវត្តលើជម្លោះ** ....... ១៧

**ផ្នែកទី១៖ ជំហរ និងអំណះអំណាងរបស់គូភាគី** ....... ១៧

កថាខណ្ឌទី១៖ ជំហរ និងអំណះអំណាងរបស់ចិន ....... ១៧

កថាខណ្ឌទី២៖  ជំហរ និងអំណះអំណាងរបស់ហ្វីលីពីន ....... ២១

**ផ្នែកទី២៖ យន្តការនាពេលកន្លងមក** ....... ២៣

កថាខណ្ឌទី១៖ យន្តការចរចារការទូត ....... ២៣

កថាខណ្ឌទី២៖  យន្តការច្បាប់ ....... ២៦

**ផ្នែកទី៣៖ មូលហេតុនៃការមិនអាចដោះស្រាយបាននៃជម្លោះ** ....... ៣៦

កថាខណ្ឌទី១៖ ភាពមិនអាចអនុវត្តទៅបាននូវសេចក្តីសម្រេចរបស់មជ្ឈត្តការ ....... ៣៦

កថាខណ្ឌទី២៖ ការលូកដៃពីរដ្ឋមិនមែនភាគីនៃជម្លោះ ....... ៣៨

**ជំពូកទី៣៖ យន្តការដោះស្រាយជម្លោះដែលអាចប្រកាន់យក** ............................... ៤១
**ផ្នែកទី១៖ យន្តការក្រៅប្រព័ន្ធតុលាការ** ............................................................................ ៤១
កថាខណ្ឌទី១ ការចរចាការទូត ............................................................................................ ៤៣
កថាខណ្ឌទី២ ការបង្កើតតំបន់អភិវឌ្ឍន៍រួម (Joint Development Zone) ..................................... ៤៤
**ផ្នែកទី២៖ យន្តការតាមផ្លូវតុលាការ** ................................................................................. ៤៥
កថាខណ្ឌទី១ តុលាការអន្តរជាតិនីតិសមុទ្រ The International Tribunal for the Law of the Sea (ITLOS) ............................................................................................................................ ៤៥
កថាខណ្ឌទី២ តុលាការយុត្តិធម៌អន្តរជាតិ (International Court of Justice – ICJ) ..................... ៤៧
កថាខណ្ឌទី៣ តុលាការមជ្ឈត្តការទូទៅ (General Arbitration) ................................................ ៤៩
**សេចក្តីសន្និដ្ឋាន និងអនុសាសន៍** ........................................................................... ៥០
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# តារាងសម្គាល់ពាក្យកាត់

**ASEAN**: Association of Southeast Asian Nations: សមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន)

**COC**: Code of Conduct in the South China Sea: ក្រមប្រតិបត្តិនៃសមុទ្រចិនខាងត្បូង

**EEZ**: Exclusive Economic Zone: តំបន់សេដ្ឋកិច្ចផ្តាច់មុខ

**DTI**: Department of Trade and Industry: នាយកដ្ឋានពាណិជ្ជកម្ម និងឧស្សាហកម្ម

**DOT**: Department of Tourism: នាយកដ្ឋានទេសចរណ៍

**DOC**: Declaration on the Conduct of Parties in the South China Sea: សេចក្តីថ្លែងការណ៍រួមស្តីពីកិច្ចប្រតិបត្តិរបស់ភាគីក្នុងសមុទ្រចិនខាងត្បូង

**ITLOS**: International Tribunal for the Law of the Sea: តុលាការអន្តរជាតិនីតិសមុទ្រ

**ICJ:** International Court of Justice: តុលាការយុត្តិធម៌អន្តរជាតិ

**JDZ:** Joint Development Zone: តំបន់អភិវឌ្ឍន៍រួម

**UN** : United Nations : អង្គការសហប្រជាជាតិ

**UNCLOS** : United Nations Convention on Law of the Se: អនុសញ្ញាសហប្រជាជាតិស្តីពីនីតិសមុទ្រ

**PCA** : Permanent Court of Arbitration: តុលាការមជ្ឈត្តការអចិន្ត្រៃយ៍

**UNSC** : United Nations Security Council: ក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិ

**P5** : Five Permanent Members of United Nations Security Council: សមាជិកអចិន្ត្រៃយ៍ទាំង០៥ នៃក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិ

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំនៃបញ្ហាស្រាវជ្រាវ

ជម្លោះដែនអធិបតេយ្យនៅតំបន់សមុទ្រចិនខាងត្បូង ជាជម្លោះមួយដែលមានលក្ខណៈស្មុគស្មាញ និងសាំញ៉ាំច្រើន ដ្បិតក្នុងជម្លោះនេះយើងសង្កេតឃើញមានការទាមទារលើការកាន់កាប់ដែនអធិបតេយ្យដែនកោះ និងតំបន់សេដ្ឋកិច្ចផ្តាច់មុខ (Exclusive Economic Zone ឬ EEZ) រវាងភាគីរហូត០៦ រួមមានចិន ហ្វីលីពីន ម៉ាឡេស៊ី ឥណ្ឌូនេស៊ី ប្រ៊ុយណេ និងវៀតណាមផង។ យ៉ាងណាមិញក្នុងចំណោមភាគីទាំង០៦ មានភាគីពីរដែលយើងសង្កេតឃើញថាជាភាគីដំបូងក្នុងជម្លោះ ហើយមកទល់សព្វថ្ងៃជម្លោះរវាងភាគីទាំងពីរនោះ គឺហាក់មានលក្ខណៈស្មុគស្មាញ និងពិសេសជាងគេដ្បិតវាពាក់ព័ន្ធនឹងកម្មវត្ថុនៃការទាមទារច្រើន នោះគឺជម្លោះរវាងចិន និងហ្វីលីពីនជុំវិញការទាមទារអធិបតេយ្យដែនកោះ និយមន័យនិងលក្ខខណ្ឌបង្កើតតំបន់សេដ្ឋកិច្ចផ្តាច់មុខ រួមទាំងក្របខណ្ឌច្បាប់នៃផែនទីខ្សែបន្ទាត់ប្រាំបួនចំណុច ឬ Nine-Dash Line Map របស់ចិនផងដែរ។

មកទល់សព្វថ្ងៃនេះជម្លោះរវាងប្រទេសទាំងពីរ នៅពុំទាន់រកច្រកចេញបាននៅឡើយទេ បើទោះបីជាមានការប្រើប្រាស់យន្តការច្បាប់ពីភាគីម្ខាង ក៏ដូចជាការបង្កើនការចរចា រួមទាំងកិច្ចព្រមព្រៀងទ្វេ និងពហុភាគីមួយចំនួនបានចុះហត្ថលេខាដោយភាគីទាំងពីរហើយក៏ដោយ ក៏ភាពតានតឹងនៅតំបន់ទឹកមានជម្លោះនៅតែបន្តកើតមាន ហើយជារឿយៗបានបង្កឱ្យមានការប៉ះទង្គិចគ្នារវាងភាគីទាំងសងខាង។ មិនតែប៉ុណ្ណោះជម្លោះនេះក៏បានជះឥទ្ធិពលអវិជ្ជមានដល់តំបន់អាស៊ីអាគ្នេយ៍ និងពិភពលោកទាំងមូលផងដែររួមមានវិបត្តិការទូត ការកើនឡើងការចំណាយយោធាជាដើម ជាហេតុបង្កឱ្យមានលទ្ធភាពគម្រាមកំហែងដល់សន្តិសុខ និងស្ថិរភាពតំបន់អាស៊ីអាគ្នេ-យ៍ដែលក្នុងនោះកម្ពុជាក៏ជាប្រទេសមួយស្ថិតក្នុងទ្វីបនេះដែរ។

ដោយលក្ខណៈស្មុគស្មាញនៃជម្លោះ បូកផ្សំនឹងយន្តការដែលគូភាគីធ្លាប់បានប្រើដើម្បីជាក្តីសង្ឃឹមឆ្ពោះទៅរកការបញ្ចប់ជម្លោះ ព្រមទាំងហានិភ័យដែលស្តែងចេញពីការរកច្រកចេញពុំទាន់បាននៃជម្លោះរ៉ាំរ៉ៃនេះ និងឥទ្ធិពលរបស់វាមកលើតំបន់ និងកម្ពុជាផង ទើបទាមទារឱ្យមានការស្វែងយល់បន្ថែមជាគោលទៅលើកម្មវត្ថុ និងយន្តការដែលធ្លាប់ប្រើផ្អែកលើគោលការណ៍ច្បាប់អន្តរជាតិ ដើម្បីបានជាគតិក្នុងការពិចារណាទៅលើលទ្ធភាពនៃការរកច្រកចេញនៃជម្លោះជាប្រវត្តិសាស្ត្រនេះ។

## ២. ចំណោទបញ្ហាស្រាវជ្រាវ

ដោយសារតែជម្លោះការទាមទារដែនអធិបតេយ្យនៅសមុទ្រចិនខាងត្បូងរវាងចិន និងហ្វីលីពីន មានលក្ខណៈស្មុគស្មាញសាំញ៉ាំ និងត្រូវការយន្តការដោះស្រាយសមស្របមួយដែលរហ័ស និងមានប្រសិទ្ធិភាពដើម្បីទប់ទល់ការកើនឡើងនៅភាពតានតឹង និងការប្រឈមមុខដាក់គ្នាពិសេស ក្នុងតំបន់អាស៊ីអាគ្នេយ៍ផង សំណួរ

មួយចំនួនត្រូវបានលើកឡើងដើម្បីព្យាយាមស្វែងរកចម្លើយក្នុងខ្លឹមសារនៃសារណានេះ។ សំនួរគោលទាំងនោះរួមមាន៖

- តើអ្វីបុព្វហេតុ និងដើមចមនៃជម្លោះ?
- អ្វីទៅកម្មវត្ថុនៃជម្លោះ ដោយបូករួមទាំងអំណះអំណាងរបស់ភាគីសងខាង?
- កន្លងមកតើយន្តការផ្អែកលើគោលការណ៍ច្បាប់អន្តរជាតិអ្វីខ្លះដែលធ្លាប់បានប្រើដើម្បីដោះស្រាយជម្លោះហើយលទ្ធផលបែបណាដែរ?
- យន្តការផ្អែកលើស្មារតីច្បាប់អន្តរជាតិអ្វីខ្លះទៀតដែលគូភាគីអាចជ្រើសរើសដើម្បីជាច្រកចេញបញ្ចប់ជម្លោះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងចម្បងនៃកិច្ចស្រាវជ្រាវនេះគឺដើម្បីបំផុសគំនិតក្នុងការឈ្វេងយល់អំពី ជម្លោះនៅមុទ្រចិនខាងត្បូង ក៏ដូចជាការដោះស្រាយជម្លោះអន្តរជាតិបែបសន្តិនិយមដោយផ្អែកលើស្មារតីច្បាប់ និងកិច្ចសហប្រតិបត្តការ។ ក៏ចង់បង្ហាញឱ្យឃើញត្រួសៗផងដែរនូវខ្លឹមសារគោលមួយចំនួន ពាក់ព័ន្ធនឹងភាពមិនអាចដោះស្រាយទៅបាននូវជម្លោះអន្តរជាតិដោយមូលហេតុកង្វះឆន្ទៈក្នុងការដោះស្រាយបញ្ហាតាមផ្លូវច្បាប់ និងការមិនអាចអនុវត្តបានដោយបង្ខំទៅលើភាគីជម្លោះដែលជារដ្ឋអធិបតេយ្យ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ដោយសារតែភាពស្មុគស្មាញខ្លាំង រួមទាំងយន្តការនិងនីតិវិធីដែត្រូវបានលើកយកមកដោះស្រាយមានលក្ខណៈបច្ចេកទេសច្រើនដោយត្រូវចំណាយពេលវេលាយូរក្នុងកាស្វែងយល់ឱ្យគ្រប់ជ្រុងជ្រោយ ជាហេតុនាំឱ្យការស្រាវជ្រាវនេះនឹងផ្តោតជាគោលក្នុងការរំលេចបង្ហាញត្រួសៗទាក់ទិននឹងចំណុចស្នូលនៃជម្លោះ ក្នុងទិដ្ឋភាពច្បាប់អន្តរជាតិជារួមប៉ុណ្ណោះ ដោយពុំចូលជ្រៅដល់ចំណុច និងកម្មវត្ថុគោលនីមួយៗនៃការទាមទារនោះឡើយ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

កិច្ចការស្រាវជ្រាវនេះនឹងបានជាប្រយោជន៍ដល់អ្នកអានជារួមដើម្បី បានឈ្វេងយល់ទៅបន្ថែមទៅលើជម្លោះជាប្រវត្តិសាស្ត្រមួយនេះ រួមទាំងបានជាបច្ច័យត្រួសៗពីយន្តការច្បាប់ដែលធ្លាប់បានប្រើ រួមទាំងលទ្ធភាពដែលអាចបញ្ចប់ជម្លោះនេះបាន ដើម្បីបានជាគតិក្នុងការពិចារណាស្វែងយល់ និងវាយតម្លៃទៅលើជម្លោះដទៃដែលកំពុងកើតមានស្រដៀងគ្នាផងដែរ។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ការប្រមូលទិន្នន័យក្នុងកិច្ចការស្រាវជ្រាវនេះ នឹងត្រូវបានយកមកពីគេហទំព័រ ក៏ដូចជាសេចក្តីថ្លែងការណ៍ផ្លូវការរបស់ភាគីទាំងសងខាង តួយ៉ាងតាមរយៈគេហទំព័រក្រសួងការបរទេសរបស់ភាគីទាំងអស់ក្នុង

ជម្លោះ រួមទាំងឯកសារច្បាប់ និងឯកសារផ្លូវការរបស់ស្ថាប័នពាក់ព័ន្ធផ្សេងទៀតដែលស្ថិតក្នុងទម្រង់ឌីជីថល។ ក្រៅពីនេះការស្វែងយល់នូវគោលការណ៍ច្បាប់ផ្សេងៗនឹងត្រូវបានសាកសួរទៅសាស្ត្រាចារ្យ ឬអ្នកជំនាញ រួមទាំងដកស្រង់ចេញពីសៀវភៅ និងឯកសារសិក្សាផ្លូវការ (Academic Paper/Thesis) របស់អ្នកជំនាញផ្សេងៗផងដែរដើម្បីធានាបាននូវគុណភាព និងសុក្រឹតភាពនៃឯកសារយោងទាំងនោះ។

## ៧. រចនាសម្ព័ន្ធស្រាវជ្រាវ

សារណានេះត្រូវបានបែងចែកចេញជា០៣ជំពូកធំៗដោយក្នុងនោះរួមមាន៖ **ជំពូកទី១៖** សាវតានៃជម្លោះ និងទិដ្ឋភាពទូទៅនៃតំបន់ជម្លោះ។ **ជំពូកទី២៖** យន្តការ និងនីតិវិធីដែលធ្លាប់បានអនុវត្តលើជម្លោះ។ និងចុងក្រោយ **ជំពូកទី៣៖** យន្តការដោះស្រាយជម្លោះដែលអាចប្រកាន់យក។

# ជំពូកទី១៖ សាវតា និងទិដ្ឋភាព ទូទៅនៃជម្លោះ

# ជំពូកទី១៖ សាវតា និងទិដ្ឋភាពទូទៅនៃជម្លោះ

ជម្លោះទាមទារដែនអធិបតេយ្យនៅសមុទ្រចិនខាងត្បូងរវាងចិន និងហ្វីលីពីនជាជម្លោះមួយដែលមានការចាប់ផ្ដើមជាច្រើនទសវត្សរ៍មកហើយ ពោលគឺចាប់ផ្ដើមពីការលេចរូបរាងឡើងនៅអ្វីដែលគេស្គាល់ថាផែនទីខ្សែបន្ទាត់ដប់មួយចំណុច ឬ Eleven-Dash Line Map ដែលបានលេចរូបរាងឡើយតាមរយៈការបង្ហាញជាសាធារណៈរបស់រដ្ឋាភិបាលចិន ក្នុងឆ្នាំ១៩៤៧[1]។ ប៉ុន្តែក្នុងកម្មវត្ថុនៃការទាមទារនេះចិនបានប្រើប្រាស់ផែនទី ខ្សែបន្ទាត់ប្រាំបួនចំណុច ឬ Nine-Dash Line Map ដោយសារតែខ្សែបន្ទាត់២ទៀតវាហួសទៅតំបន់ច្រកសមុទ្រកោះតៃវ៉ាន់ និងសមុទ្រជប៉ុនឯណោះ។ ជម្លោះនេះបានបណ្ដាលឱ្យមានការកើនឡើងកំដៅ និងការប្រឈមមុខគ្នាជាហូហែររវាងភាគីទាំងពីទាំងលើវិស័យការទូត ផ្លូវច្បាប់ និងយោធា។ ដើម្បីស្វែងយល់កាន់តែច្បាស់ក្នុងជំពូកនេះ នឹងរៀបរាប់ត្រួសៗពីសាវតាប្រវត្តិ និងបុព្វហេតុនាំឱ្យមានជម្លោះ (ផ្នែកទី១) និងស្ថានភាពទូទៅនៃតំបន់ជម្លោះ (ផ្នែកទី២)។

## ផ្នែកទី១៖ ប្រវត្តិ និងបុព្វហេតុបង្កជម្លោះ

ទាំងប្រទេសចិន និងហ្វីលីពីនសុទ្ធសឹងតែបានលើឡើងពីការទាមទារនូវដែនអធិបតេយ្យដែនកោះ និងតំបន់សេដ្ឋកិច្ចផ្ដាច់មុខ ក្នុងតំបន់សមុទ្រចិនខាងត្បូងនិងផ្អែកលើអំណះអំណាងរៀងៗខ្លួន។ ផ្នែកមួយនៃជម្លោះគឺរឿងរ៉ាវជម្លោះពាក់ព័ន្ធនឹងបញ្ហាប្រវត្តិសាស្ត្រ ដ្បិតចិនដែលក្នុងផែនទីឆ្នាំ១៩៤៧ រួមទាំងខ្លឹមសារកត់សម្គាល់របស់ខ្លួនដែលបានចេញកាលពីឆ្នាំ២០០៩ផងនោះ បានទាមទារនូវអធិបតេយ្យទៅលើដែនទឹក និងរចនាសម្ព័ន្ធសមុទ្រមួយចំនួន (Maritime Features) គ្របដណ្ដប់លើផ្ទៃសមុទ្រហួតជាង ២លានគីឡូម៉ែត្រក្រលា ឬប្រហាក់ប្រហែលនឹង ២២ភាគរយនៃផ្ទៃដែនចិន។[2] នៅក្នុងផែនទីដែលទីក្រុងប៉េកាំងនិយាយថាបានគូសឡើងផ្អែកលើមូលដ្ឋានប្រវត្តិសាស្ត្រ មានកម្មវត្ថុនៃការទាមទារអធិបតេយ្យចម្បងទៅលើរចនាសម្ព័ន្ធសមុទ្រចំនួន៣ក្រុមដែលរួមមាន៖ ១. ប្រជុំកោះ Paracel *(ចិនហៅថា Xisha Qundao)* ២. ប្រជុំកោះ Spratly *(ចិនហៅថា Nansha Qundao)* និង៣. តំបន់ថ្មប៉ប្រះទឹក *Scarborough (ចិនហៅថា Huangyan Dao)*។[3] ការទាមទារនេះត្រូវបានទីក្រុងអះអាងថាផ្អែកទៅតាមសិទ្ធិប្រវត្តិសាស្ត្រ (Historic Bays and Title) និងខ្លឹមសារនៃតំបន់សេដ្ឋកិច្ចផ្ដាច់មុខ (Exclusive Economic Zone ឬ EEZ)។ ជាក់ស្ដែងនៅក្នុងច្បាប់ស្ដីពីតំបន់សេដ្ឋកិច្ចផ្ដាច់មុខ និងតំបន់ជាយទ្វីប (Continental Shelf) របស់ខ្លួនកាលពីឆ្នាំ១៩៩៨ ចិនបានចែងបង្កើតនូវតំបន់សេដ្ឋកិច្ចផ្ដាច់-

---

[1] Buamet K., (2014)., China: Maritime Claims in the South China Sea (Limits in the Seas No. 143) https://www.researchgate.net/publication/286459698_China_Maritime_Claims_in_the_South_China_Sea_Limits_in_the_Seas_No_143

[2] Ibid

[3] Ibid

មុខចម្ងាយ ២០០ ណូទីខលម៉ាយល៍ (200-nm) រួមទាំងបរិយាយពីសិទ្ធិ និងយុត្តាធិការរបស់ខ្លួនទៅលើតំបន់នោះផងដែរ។ ក្រោយមកក្នុងឆ្នាំ ២០១១ ចិនបានបញ្ជាក់ជាថ្មីថាដែនកោះ Nansha របស់ខ្លួនគឺមានលក្ខខណ្ឌគ្រប់គ្រាន់ក្នុងការទទួលបាននូវ អធិបតេយ្យដែនសមុទ្រ តំបន់សេដ្ឋកិច្ចផ្ដាច់មុខ និងជាយទ្វីបផ្ទាល់ខ្លួន។[4]ការលើកនូវសំអាងទាំងនេះត្រូវបានប្រទេសហ្វីលីពីនបដិសេធ និងអះអាងថាផែនទីរបស់ចិនបានគូសរំលោភលើដែនអធិបតេយ្យរបស់ខ្លួន។ ហ្វីលីពីនបានច្រានចោលនូវផែនទីខ្សែបន្ទាត់៩ចំណុចរបស់ចិន និងបានលើកឡើងថាអ្វីដែលចិនទាមទាររហូតគ្រប់ដណ្ដប់ ៨៥.៧ ភាគរយនៃដែនទឹកទាំងមូលគឺវាផ្ទុយនឹងអនុសញ្ញាសហប្រជាជាតិស្ដីពីនីតិសមុទ្រ (UNCLOS) ដែលនិយាយម្យ៉ាងទៀតថាចិនបានទាមទារលើសពីដែនអធិបតេយ្យអតិបរមា ៣៥០ ណូទីខលម៉ាយល៍ ដែលបានចែងដោយច្បាប់។[5] ក្រៅពីនេះហ្វីលីពីនក៏បានច្រានចោលផែនទីរបស់ចិន និងលើកឡើងថាការទាមទារនោះគឺពុំមានមូលដ្ឋានអ្វីសោះ ហើយទីក្រុងម៉ានីលបានប្ដឹងទៅតុលាការមជ្ឈត្តការពិសេសសុំឱ្យតុលាការនេះសម្រេចថាផែនទី និងការទាមទាររបស់ចិនមិនអាចយកជាការបានសម្រាប់ជាមូលដ្ឋានក្នុងការទាមទារដែនអធិបតេយ្យ និងបានសុំឱ្យតុលាការបកស្រាយពីរបបគតិយុត្តនៃរចនាសម្ព័ន្ធសមុទ្រ (Maritime Features) មួយចំនួនក្នុងដែនទឹកមានជម្លោះនោះដើម្បីវិនិច្ឆ័យពីប្រវែងតំបន់សេដ្ឋកិច្ចផ្ដាច់មុខ។[6]

ក្រៅតែពីជម្លោះប្រវត្តិសាស្ដនេះហើយ បុព្វហេតុនៃជម្លោះ និងភាពមិនអាចរកច្រកចេញបាននៃជម្លោះដំរ៉ាំរ៉ៃក្នុងសមុទ្រចិនខាងត្បូង ក៏អាចបណ្ដាលមកពីឆន្ទៈ និងការប្រកួតប្រជែងភូមិសាស្ត្រនយោបាយ រួមទាំងផលប្រយោជន៍លើធនធានធម្មជាតិក្នុងតំបន់ផងដែរ។[7]

**កថាខណ្ឌទី១៖ ជម្លោះប្រវត្តិសាស្ត្រ**

ផ្អែកតាមការលើកឡើងរបស់ភាគីចិន ប្រទេសចិនបានធ្វើសកម្មភាពជាច្រើននៅសមុទ្រចិនខាងត្បូងនៅក្នុងអំឡុងពេលជាង២០០០ឆ្នាំ នេះ។ ប្រជាជនចិនបានហៅសមុទ្រចិនខាងត្បូងថា ណានហៃ ឬ (Nanhai) មានឯកសារនិងភស្តុតាងជាច្រើន ដែលបញ្ជាក់ថាសមុទ្រចិនខាងត្បូងគឺជារបស់ចិន។ នៅចន្លោះទសវត្សរ៍ឆ្នាំ ១៩៣០ និងឆ្នាំ១៩៤០ ប្រទេសបារាំង និងប្រទេសជប៉ុនបានចូលឈ្លានពានដោយខុសច្បាប់ និងកាន់កាប់ដោយយោធាដោយខុសច្បាប់នូវកោះ Xisha ដែលបច្ចុប្បន្នជាប្រជុំកោះ Paracel និងកោះ Nansha ដែលបច្ចុប្បន្នជាប្រជុំកោះ Spratly ដែលចិនលើកឡើងថាជារបស់ប្រទេសចិនក្នុងប្រវត្តិសាស្ត្រ។ ប៉ុន្តែប្រជាជន រួម

[4] Ibid

[5] Gabriel Domínguez, 'No basis for China's claims'; https://www.dw.com/en/chinas-nine-dashed-line-has-no-basis-under-international-law/a-18609290

[6] Ibid

[7] Mitchell D. M., (2016)., The South China Sea: A Geopolitical Analysis; https://www.researchgate.net/publication/306527696_The_South_China_Sea_A_Geopolitical_Analysis

ជាមួយរដ្ឋាភិបាលចិននៅតែប្រកាន់ខ្ជាប់ខ្លួនក្នុងការការពារអធិបតេយ្យភាពរបស់ចិនលើកោះ និងថ្មទាំងនេះ។[8] បន្ទាប់ពីសង្គ្រាមលោកលើកទី២ សេចក្តីថ្លែងការណ៍ចំនួន០២ ពោលគឺៈ Cairo Declaration [9]និង Potsdam Proclamation[10] ឆ្នាំ ១៩៤៥ បានប្រកាសថាប្រទេសជប៉ុននឹងដកកងទ័ព និងប្រគល់ត្រលប់ទៅឱ្យប្រទេសចិនវិញនូវទឹកដីចិន ដែលខ្លួនបានកាន់កាប់ រួមមានកោះតៃវ៉ាន់ និងកោះ Penghu កោះ Xisha និងកោះ Nansha ដែលនៅពេលនោះតៃវ៉ាន់គ្រាន់តែជាកោះរបស់ប្រទេសចិន។ ក្រោយមកនៅឆ្នាំ ១៩៤៨ ប្រទេសចិនបានប្រកាសចេញនូវផែនទី នៃតំបន់រដ្ឋបាលរបស់ប្រទេសចិនដោយគូសយ៉ាងច្បាស់នូវខ្សែបន្ទាត់ប្រាំបួនចំណុច (Nine-Dash Line) នៃសមុទ្រចិនខាងត្បូង និងបានអះអាងជាថ្មីនូវការទាមទារអធិបតេយ្យភាពលើតំបន់ទាំងនោះ មកជាដែនអធិបតេយ្យរបស់ចិន និងសិទ្ធិពាក់ព័ន្ធលើទឹកដីទាំងនេះផងដែរ។[11] បន្ទាប់ពីសង្គ្រាមលោកលើកទី២ ខ្សែបន្ទាត់ប្រាំបួនចំណុច (Nine-Dash Line) នៃសមុទ្រចិនខាងត្បូងគឺជាបន្ទាត់កំណត់ជាតិដែលត្រូវបានគូសនៅលើផែនទីផ្លូវការជាច្រើនដែលផលិតដោយសហរដ្ឋអាមេរិក សហភាពសូវៀត ជប៉ុនក្នុងចំណោមប្រទេសដទៃទៀត។ សូម្បីតែប្រទេសជិតខាងជុំវិញសមុទ្រចិនខាងត្បូង ដូចជាវៀតណាម និងហ្វីលីពីន ក៏មានផែនទីដែលទទួលស្គាល់ថា ប្រជុំកោះ Nansha ត្រូវបានសម្គាល់យ៉ាងច្បាស់ថា ជាទឹកដីរបស់ចិន។ នេះបើយោងតាមការអះអាងប្រវត្តិសាស្ត្ររបស់ភាគីចិន។

មុនទសវត្សរ៍ឆ្នាំ១៩៧០ អធិបតេយ្យភាពរបស់ចិនលើប្រជុំកោះសមុទ្រចិនខាងត្បូងមិនដែលត្រូវបានជំទាស់ដោយកម្លាំងខាងក្រៅណាមួយឡើយ។ ដើមហេតុនៃជម្លោះនៅសមុទ្រចិនខាងត្បូង គឺដោយសារតែចាប់តាំងពីការលេចឡើងរបស់ចិនជាប្រទេសមានសេដ្ឋកិច្ចធំមក បូករួមទាំងការប្រែប្រួលភូមិសាស្ត្រនយោបាយ គេសង្កេតឃើញថាចាប់ពីពេលនោះមក ប្រទេសមួយចំនួនបានឈ្លានពាន និងកាន់កាប់ព្រមទាំងទាមទារអធិបតេយ្យភាពលើកោះ និងថ្មប៉ប្រះទឹកនៃប្រជុំកោះ Nansha និងតំបន់កោះផ្សេងទៀត។ ក្រោយមក ជាមួយនឹងការប្រកាសឱ្យប្រើប្រាស់ និងការអនុវត្តជាបន្តបន្ទាប់ នៃអនុសញ្ញាសហប្រជាជាតិស្តីពីនីតិសមុទ្រ UNCLOS ជម្លោះលើសិទ្ធិ និងផលប្រយោជន៍ដែនសមុទ្រ ក៏ដូចជាតំបន់សេដ្ឋកិច្ចផ្តាច់មុខ (EEZ) និងជាយទ្វីបបានកើត

---

8 H.E. CONG Peiwu, Ambassador of People's Republic of China in Canada, The History and Reality of the South China Sea Issue, 2020 http://ca.china-embassy.gov.cn/eng/sgxw/202009/t20200913_4615002.htm

9 Cairo Declaration, 1943, https://www.ndl.go.jp/constitution/e/shiryo/01/002_46shoshi.html

10 Potsdam Declaration, 1945, https://www.atomicarchive.com/resources/documents/hiroshima-nagasaki/potsdam.html

11 H.E. CONG Peiwu, Ambassador of People's Republic of China in Canada, The History and Reality of the South China Sea Issue, 2020 http://ca.china-embassy.gov.cn/eng/sgxw/202009/t20200913_4615002.htm

ឡើងរវាងប្រទេសចិន និងប្រទេសទាំងនោះ ដោយភាគច្រើនសុទ្ធតែសំអាងលើសិទ្ធជាប្រវត្តិសាស្ត្ររបស់ខ្លួនក្នុងការកាន់កាប់តំបន់ទាំងអស់នោះ។

នៅឆ្នាំ១៩៩៨ រដ្ឋាភិបាលចិនបានប្រកាសឱ្យប្រើ និងអនុវត្តច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចផ្តាច់មុខ និងតំបន់ជាយទ្វីបនៃសាធារណរដ្ឋប្រជាមានិតចិន ដើម្បីបញ្ជាក់ម្តងទៀតនូវការទាមទារ ជាប្រវត្តិសាស្ត្ររបស់ចិននៅតំបន់សមុទ្រចិនខាងត្បូង។ រដ្ឋាភិបាលចិនក៏បានអះអាង និងប្រកាន់ខ្ជាប់នូវទីតាំងទឹកដីរបស់ខ្លួននៅលើខ្សែបន្ទាត់ប្រាំបួនចំណុច ក្នុងលំហដែនសមុទ្រចិនខាងត្បូង។ កាលពីថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៦ រដ្ឋាភិបាលចិនបានចេញសេចក្តីថ្លែងការណ៍ អះអាងអំពីអធិបតេយ្យភាពទឹកដី និងសិទ្ធិដែនសមុទ្រ និងផលប្រយោជន៍របស់ចិននៅសមុទ្រចិនខាងត្បូង ព្រមទាំងបញ្ជាក់ឡើងវិញថា *"ចិនមានសិទ្ធិជាប្រវត្តិសាស្ត្រនៅសមុទ្រចិនខាងត្បូង"*។

ចំពោះចិន បញ្ហាសមុទ្រចិនខាងត្បូងគឺភាគីចិន នៅតែប្តេជ្ញាចិត្តរក្សាអធិបតេយ្យភាពទឹកដីសិទ្ធិដែនសមុទ្រ និងផលប្រយោជន៍ពាណិជ្ជកម្មរបស់ចិននៅសមុទ្រចិនខាងត្បូងដែលខ្លួនបានអះអាង និងទាមទារ។ ដើម្បីសម្រេចបាននូវតម្រូវការនេះ ការថែរក្សា សន្តិភាព និងស្ថិរភាពនៅសមុទ្រចិនខាងត្បូង ការដោះស្រាយជម្លោះដោយសន្តិវិធី តាមរយៈការចរចា និងការពិគ្រោះយោបល់ រួមទាំងកិច្ចសហប្រតិបត្តការ សំដៅគ្រប់គ្រងភាពផ្ទុយមតិគ្នាតាមរយៈវិធាន និងយន្តការ ដែលសំដៅការការពារដល់សេរីភាពនៃការធ្វើនាវាចរណ៍ (Freedom of Navigation) និងការហោះហើរ (Freedom of Overflight) លើដែនលំហនៃសមុទ្រចិនខាងត្បូង និងការសម្រេចបាននូវលទ្ធផលឈ្នះឈ្នះ តាមរយៈកិច្ចសហប្រតិបត្តិការដែលមានផលប្រយោជន៍ទៅវិញទៅមក។ ប្រទេសចិនអះអាងម្តងជាពីរដងថា ខ្លួនមិនដែលស្វែងរកការបង្កើត *"អាណាចក្រសមុទ្រ"* នៅសមុទ្រចិនខាងត្បូងនោះទេ ប៉ុន្តែចិននឹងអនុវត្តសកម្មភាពសមស្របចំពោះប្រទេសជាប់ព្រំដែនសមុទ្រចិនខាងត្បូងដោយឈរលើមូលដ្ឋានសមភាពនៃរដ្ឋជាគោល។ មកទល់ពេលនេះ ប្រទេសចិនលើកឡើងថាខ្លួនបានអនុវត្តខ្ជាប់ខ្ជួននូវការអត់ធ្មត់ជាទីបំផុត (Maximum Restraint) ក្នុងកិច្ចការការពារ និងការទាមទារអធិបតេយ្យភាព សិទ្ធិ និងផលប្រយោជន៍នៅសមុទ្រចិនខាងត្បូង។

នៅថ្ងៃទី ០៤ ខែវិច្ឆិកា ឆ្នាំ ២០០២ គំនិតផ្តួចផ្តើមនូវអ្វីដែលគេស្គាល់ថាជាសេចក្តីថ្លែងការណ៍ស្តីពីការប្រតិបត្តិនៃភាគីនៅសមុទ្រចិនខាងត្បូង(Declaration of The Conduct Parties in South China Sea ឬ DOC) បានកើតឡើង និងរហូតឈានដល់ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះក្នុងឆ្នាំដែលខណៈកម្ពុជាធ្វើជាប្រធានអាស៊ានសម័យនោះ។ DOC នេះគឺជាឯកសារគតិយុត្តដំបូងគេទាក់ទងនឹងបញ្ហា សមុទ្រចិនខាងត្បូងដែលត្រូវបានចុះហត្ថលេខាដោយប្រទេសចិន បូករួមទាំងបណ្តាប្រទេសអាស៊ានទាំងជាគូភាគី និងមិនមែនហើយវាបានដើរតួនាទីយ៉ាងសំខាន់ក្នុងការរក្សាសន្តិភាព និងស្ថិរភាព ពិសេសស្ថានភាពដើមមួយ (Status quo) នៅក្នុងតំបន់។ ជាបន្តបន្ទាប់ចិន បាននឹងកំពុងធ្វើការជាមួយបណ្តាប្រទេសអាស៊ានដើម្បីអនុវត្ត DOC យ៉ាងពេញ

លេញ និងប្រកបដោយប្រសិទ្ធភាព ដោះស្រាយជម្លោះដែលពាក់ព័ន្ធបានត្រឹមត្រូវតាមរយៈការសន្ទនា ជៀសវាងសកម្មភាពដែលធ្វើឱ្យមានភាពស្មុគស្មាញ ឬបង្កើនជម្លោះ ពិសេសគ្រប់ភាគីបាននឹងកំពុងខិតខំយ៉ាងសកម្មដើម្បីសម្រេចបាននូវ ក្រមប្រតិបត្តិស្តីពីការប្រតិបត្តិនៃភាគីជម្លោះសមុទ្រចិនខាងត្បូង (Code of Conduct ឬ COC) សម្រាប់សមុទ្រចិនខាងត្បូងនាពេលណាមួយ។

នៅក្នុងការកំណែទម្រង់បន្ថែមពីលើ DOC COC នឹងក្លាយជាលិខិតបទដ្ឋានគតិយុត្តមានចំណង (Binding Force) ដោយអនុលោមតាមច្បាប់អន្តរជាតិ ហើយវានឹងផ្តល់ការពិចារណាយ៉ាងត្រឹមត្រូវចំពោះសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ប្រទេសនានានៅក្រៅតំបន់ក្នុងសមុទ្រចិនខាងត្បូង។ ដូច្នេះ COC នេះនឹងក្លាយជាគ្រឹះគ្រឹះសម្រាប់កសាងសមុទ្រចិនខាងត្បូងទៅជាសមុទ្រសន្តិភាព មិត្តភាព និងកិច្ចសហប្រតិបត្តិការប្រសិនបើវាលេចចេញជារូបរាងនៅទីបំផុត។

ក្នុងពេលបច្ចុប្បន្ន យ៉ាងហោយជាបណ្តោះអាសន្ន យើងឃើញថា សេរីភាពនៃការធ្វើនាវាចរណ៍ និងការហោះហើរនៅដែនសមុទ្រចិនខាងត្បូងជាប្រវត្តិសាស្ត្រមិនទាន់ដែលមានបញ្ហាអ្វីធំដុំនោះទេ។ បច្ចុប្បន្នសមុទ្រចិនខាងត្បូងជាផ្លូវសមុទ្រដែលមានសុវត្ថិភាពបំផុត (Uncontested) និងបើកចំហបំផុតមួយក្នុងពិភពលោក។ យោងតាមច្បាប់អន្តរជាតិ ប្រទេសចិន និងភាគីដទៃតែងតែគោរព និងគាំទ្រដល់សេរីភាពនៃការធ្វើនាវាចរណ៍ និងការហោះហើរ ដែលបច្ចុប្បន្នបានអនុវត្តដោយប្រទេសទាំងអស់នៅជាប់ និងមិនជាប់សមុទ្រចិនខាងត្បូង។ គួរបញ្ជាក់ផងដែរថា ប្រហែល៥0% នៃកប៉ាល់ពាណិជ្ជកម្មរបស់ពិភពលោក និងជាងមួយភាគបីនៃពាណិជ្ជកម្មតាមសមុទ្រត្រូវបានដឹកនិងជិះឆ្លងកាត់ដែនទឹកមានជម្លោះនេះ។ មានកប៉ាល់ឈ្នួញជាងមួយសែនគ្រឿងបានធ្វើដំណើរឆ្លងកាត់តំបន់នេះជារៀងរាល់ឆ្នាំ ហើយជិត ៦0% នៃពាណិជ្ជកម្មតាមសមុទ្រ និងជាង ៨៥% នៃការនាំចូលថាមពលរបស់ចិន បានដឹកឆ្លងកាត់សមុទ្រចិនខាងត្បូង។ ជារួមបច្ចុប្បន្នសេរីភាពនៃការធ្វើនាវាចរណ៍ និងការហោះហើរនៅសមុទ្រចិនខាងត្បូងមិនដែលជាបញ្ហាទេ។

ទោះបីជាមានជម្លោះខ្លះលើសិទ្ធិ និងផលប្រយោជន៍ដែនអធិបតេយ្យក្នុងសមុទ្ររវាងចិន និងប្រទេសពាក់ព័ន្ធផ្សេងទៀតក៏ដោយ ជម្លោះបែបនេះមិនដែលប៉ះពាល់ដល់សេរីភាពនៃការធ្វើនាវាចរណ៍ និងការហោះហើរលើសចំណុះដែលគ្រប់ប្រទេសទាំងអស់នៅក្នុងសមុទ្រចិនខាងត្បូងនោះទេ។ ស្ថិតនៅលើមាត់ទ្វាររបស់ប្រទេសចិន សមុទ្រចិនខាងត្បូងគឺជាខ្សែបន្ទាត់ជីវិតរបស់ប្រទេសចិន។ ចិនតែងអះអាងថា ខ្លួនស្រឡាញ់សន្តិភាព និងស្ថិរភាពសមុទ្រចិនខាងត្បូងច្រើនជាងប្រទេសដទៃ ហើយយកចិត្តទុកដាក់ខ្លាំងជាងមុនក្នុងការរក្សាផ្លូវសមុទ្រនៃសមុទ្រចិនខាងត្បូងឱ្យមានសុវត្ថិភាព និងគ្មានការរារាំង។ ក្នុងពេលជាមួយគ្នានេះ ចិនក៏តែងនិយាយម្តងហើយម្តងទៀតថា នឹងប្រឆាំងយ៉ាងម៉ឺងម៉ាត់ចំពោះទង្វើណាមួយដែលបំផ្លាញអធិបតេយ្យភាព និងផលប្រយោជន៍សន្តិសុខរបស់ប្រទេសនានានៅតាមបណ្តោយសមុទ្រចិនខាងត្បូង ក្រោមលេសមិនពិតនៃការអនុវត្តសិទ្ធិ "សេរី

ភាពនៃការធ្វើនាវាចរណ៍" (Freedom of Nevigation)។ ប្រការនេះគេសង្កេតឃើញថាចិនមានជំហរប្រឆាំងសហរដ្ឋអាមេរិក ដែលជារឿយៗបានបញ្ជូននាវាចម្បាំង និងយន្តហោះជាញឹកញាប់ទៅកាន់សមុទ្រចិនខាងត្បូង ដើម្បីបង្ហាញពីវត្តមានយោធារបស់ពួកគេដោយអះអាងថាខ្លួនអនុវត្តនូវសិទ្ធិ "សេរីភាពនៃការធ្វើនាវាចរ"(Freedom of Nevigation)។

សរុបជារួម ជាបរិបទប្រវត្តិសាស្ត្រនៃជម្លោះដ៏រ៉ាំរ៉ៃនៅសមុទ្រចិនខាងត្បូង បានកើតមានឡើងតាំងពីឆ្នាំ ១២៧៩ នៅពេលដែលភាគីចិនបានគូសផែនទីទឹកដីនៃឥទ្ធិពលរបស់ខ្លួន ដែលរួមបញ្ចូលសមុទ្រចិនខាងត្បូងស្ទើរតែទាំងមូល។ ចាប់តាំងពីពេលនោះមក ការគ្រប់គ្រងលើតំបន់បានផ្លាស់ប្តូរដៃគ្នារវាងមហាអំណាចក្នុងតំបន់ និងក្រោយមករដ្ឋអាណានិគម។ ទោះជាយ៉ាងណាក៏ដោយ មនុស្សភាគច្រើនយល់ស្របថា ភាគច្រើននៃបញ្ហាបច្ចុប្បន្នកើតចេញពីសន្ធិសញ្ញាសាន់ហ្វ្រាន់ស៊ីស្កូឆ្នាំ ១៩៥១[12] ដែលបានធ្វើឡើងក្រោយការបរាជ័យរបស់កងទ័ពជប៉ុនក្នុងសង្គ្រាមលោកលើកទី២។ ក្នុងលក្ខខណ្ឌនៃការចុះចាញ់ ប្រទេសជប៉ុនបានសម្រេចលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាន់កាប់តំបន់កោះមួយចំនួនក្នុងសមុទ្រចិនខាងត្បូង ដោយប្រការនេះបានបន្សល់ទុកនូវភាពទំនេរនៃអំណាចនៅក្នុងតំបន់។ គ្មានប្រទេសណាមួយត្រូវបានផ្តល់អធិបតេយ្យភាពច្បាស់លាស់លើដែនទឹកទាំងនេះទេហើយចិន (រដ្ឋាភិបាលគួមីនតាងជំនាន់នោះ) បានអះអាងពីអត្ថប្រយោជន៍របស់ទីក្រុងប៉េកាំង និងបានដាក់ពាក្យបណ្តឹងទាមទារ "ខ្សែបន្ទាត់ដប់មួយចំណុច ឬ Eleven-Dash Line" ដែលលាតសន្ធឹងគ្របដណ្តប់ស្ទើរតែទាំងមូលសមុទ្រចិនខាងត្បូងក្នុងឆ្នាំ១៩៤៧។ ខ្សែបន្ទាត់នេះបានក្លាយជាការទាមទារផ្លូវការរបស់ខ្លួន និងត្រូវបានគេស្គាល់សព្វថ្ងៃនេះថាជា "ខ្សែបន្ទាត់ប្រាំបួនចំណុច ឬ Nine-Dash Line" [13] ។ នៅឆ្នាំ១៩៨២ អនុសញ្ញាសហប្រជាជាតិស្តីពីនីតិសមុទ្របានបង្កើតឱ្យមាននូវមូលដ្ឋានគតិយុត្តនៃតំបន់សេដ្ឋកិច្ចផ្តាច់មុខ (EEZ) ។ ភ្លាមៗនោះប្រទេសចិនបានរំលឹកឡើងវិញនូវខ្សែបន្ទាត់ប្រាំបួនចំណុចរបស់ខ្លួន ប៉ុន្តែបដិសេធមិនបញ្ជាក់ពីដែនកំណត់នៃបន្ទាត់នេះ និងបដិសេធការទាមទាររបស់ប្រទេសអ្នកទាមទារផ្សេងទៀត។

ចាប់តាំងពីពេលនោះមក ភាពតានតឹងបានកើតមានឡើងជាថ្មីថា តើអ្នកណាជាម្ចាស់សមុទ្រចិនខាងត្បូង។ ក្នុងពេលជាមួយគ្នានេះ ជម្លោះបានផ្តោតលើអធិបតេយ្យភាពលើប្រជុំកោះ Paracel និង Spratly ដែលជាប្រជុំកោះមួយស្ថិតនៅ ចំកណ្តាលសមុទ្រចិនខាងត្បូង។ បច្ចុប្បន្ននេះ ចិន ម៉ាឡេស៊ី ហ្វីលីពីន រួមជាមួយនឹងវៀតណាមផង បានទាមទារជាផ្នែកមួយចំនួននៃប្រជុំកោះ Paracel និង Spratly។ ប្រទេសទាំងអស់នោះសុទ្ធតែបានអះអាងលើអធិបតេយ្យភាពលើតំបន់រចនាសម្ព័ន្ធសមុទ្រមួយចំនួន និងបានលើកឡើងពីប្រវត្តិនៃការ

---

[12] Peace Treaties after World War II: Peace treaty signed in San Francisco, September 8, 1951.

[13] Khoury, E. (2017). "Recent trends in the South China Sea disputes", Asia Focus#16 – Asia Programme, Insititut de relations internationales et stratégiques.

ធ្វើនាវាចរណ៍របស់ខ្លួនក្នុងតំបន់ទាំងនោះ។ យ៉ាងណាមិញមានតែចិនប៉ុណ្ណោះដែលមានកម្មវត្ថុនៃការទាមទារធំជាងគេរហូតជាង ៨៦% នៃដែនទឹកក្នុងសមុទ្រចិនខាងត្បូង។

**កថាខណ្ឌទី២៖ បញ្ហានយោបាយ និងជម្លោះធនធានធម្មជាតិ**

ការប្រែប្រួលភូមិសាស្ត្រនយោបាយបន្តិចម្តងៗ បាននឹងកំពុងធ្វើឱ្យពិភពលោកក្លាយទៅជាពិភពលោកពហុប៉ូល[14] ដែលប្រការនេះក៏ត្រូវបានគេមើលឃើញថាបានជះឥទ្ធិពលទៅលើបុព្វហេតុនៃជម្លោះ រួមទាំងការរកច្រកចេញសម្រេចបិទបញ្ចប់នៃជម្លោះនេះផងដែរ។ ចាប់តាំងពីឆ្នាំ១៩៤៥មក សមុទ្រចិនខាងត្បូង និងផ្នែកខាងលិចនៃមហាសមុទ្រប៉ាស៊ីហ្វិកបានស្ថិតនៅជាតំបន់ដែនទឹកគ្មានការប៉ះទង្គិចយោធា ប៉ុន្តែក្រោយពីការលេចត្រដែតឡើងយ៉ាងលឿនរហ័សរបស់សេដ្ឋកិច្ច និងទំនើបកម្មសង្គមចិន ដែនទឹកនេះក៏បានប្រែមួយរំពេចទៅជាសមរភូមិនៃការដណ្តើមគ្នាកាន់កាប់ព្រោះដែនទឹកនេះ ត្រូវបានគេមើលឃើញថាជាដែនទឹកយុទ្ធសាស្ត្រដ៏សំខាន់សម្រាប់ការបង្កើនអនុត្តរភាពរបស់ចិន។[15] សម្រាប់ទីក្រុងប៉េកាំងដែនទឹកនេះគឺមានសារៈសំខាន់ណាស់សម្រាប់ការធ្វើទំនើបកម្មយោធាពិសេសកងទ័ពជើងទឹករបស់ខ្លួន ដ្បិតចិនសម្លឹងឃើញថានេះជាទីតាំងល្អសម្រាប់សាងសង់មូលដ្ឋានយោធា និងការបង្ហាញសាច់ដុំយោធា រួមទាំងឥទ្ធិពលនយោបាយរបស់ខ្លួនក្នុងផ្លូវដែលចិនកំពុងដើរ ពិសេសសម្រាប់មហិច្ឆតាចង់ក្លាយខ្លួនជាមហាអំណាចពិភពលោក។[16] ជាក់ស្តែង ភាគីចិនបានសាងសង់កោះសិប្បនិម្មិតមួយចំនួននៅក្នុងដែនទឹកមានជម្លោះសម្រាប់បម្រើឱ្យមូលដ្ឋានយោធារបស់ខ្លួន។[17] ស្រដៀងគ្នានេះដែរដែនទឹកនេះក៏ត្រូវបានសហរដ្ឋអាមេរិក និងសម្ព័ន្ធមិត្តក្នុងតំបន់រួមមានជប៉ុនជាដើម សម្លឹងឃើញថាជាទីតាំងយុទ្ធសាស្ត្រសន្តិសុខ និងសេដ្ឋកិច្ចផងដែរពិសេសក្រោយការស្ទុះឡើងដ៏លឿននៃទំហំ និងអនុភាពសេដ្ឋកិច្ចនិងនយោបាយរបស់ចិន។ សម្រាប់អាមេរិក ការរក្សាបាននូវស្ថានភាពដើម និងតំណែងជាមហាអំណាចពិភពលោកគឺមានន័យថាត្រូវរាំងខ្ទប់ជាចាំបាច់ការលេចត្រដែតឡើងរបស់ចិន ហើយសមុទ្រចិនខាងត្បូងជាដែនទឹកយុទ្ធសាស្ត្រសម្រាប់ប្រការនេះដោយសារតែទំហំពាណិជ្ជកម្មក្នុងតំបន់នេះ និងលទ្ធភាពក្នុងការដាក់មូលដ្ឋានយោធាលើភាគីមានជម្លោះជាមួយចិនជាក់ស្តែងដូចជាហ្វីលីពីន ដើម្បីជាការបង្ហាញសាច់ដុំយោធារបស់ខ្លួន។[18] ជប៉ុននិងសម្ព័ន្ធមិត្តដទៃទៀតរបស់អាមេរិក ក៏ដូចគ្នាដែរដ្បិតរាល់ការចរាចរចេញចូលទំនិញដ៏ច្រើនត្រូវឆ្លងកាត់តំបន់

---

[14] សៀវភៅ អាស៊ីប៉ាស៊ីហ្វិក បេះដូងនៃពិភពលោកសតវត្សរ៍ទី២១

[15] Mitchell D. M., (2016)., The South China Sea: A Geopolitical Analysis; https://www.researchgate.net/publication/306527696_The_South_China_Sea_A_Geopolitical_Analysis

[16] Ibid

[17] China has fully militarized three islands in South China Sea, US admiral says; https://meet.google.com/uud-ehuu-phw

[18] Ibid

ដែនទឹកសមុទ្រចិនខាងត្បូង ហើយប្រសិនបើចិនទាមទារបានដែនអធិបតេយ្យមែន នោះនឹងលើកជាការគម្រាមកំហែងដល់សេដ្ឋកិច្ច និងសន្តិសុខរបស់ពួកគេទាំងមូល។ ហេតុនេះទើបមានការលើកក្តីបារម្ភពីសេរីភាពនាវាចរណ៍ប្រសិនបើចិនទទួលបានអធិបតេយ្យលើដែនទឹក និងដែនកោះដែលទីក្រុងប៉េកាំងបានទាមទារ។[19]

ចំពោះហ្វីលីពីនវិញដែនទឹកនេះជាដែនទឹកសំខាន់សម្រាប់សន្តិសុខ និងសេដ្ឋកិច្ចរបស់ខ្លួន។ ហ្វីលីពីនបានលើកឡើងម្តងហើយម្តងទៀតពីសារៈសំខាន់នៃការពង្រឹងសម្ថភាពកងទ័ព ដើម្បីទប់ទល់នឹងការប៉ុនប៉ងរំលោភបំពានអធិបតេយ្យពីរដ្ឋណាមួយ។[20] ជាក់ស្តែងកងទ័ពហ្វីលីពីនបានលើកឡើងថាខ្លួនកំពុងពិនិត្យមើលមធ្យោបាយផ្សេងៗ ដើម្បីពង្រឹងការគ្រប់គ្រងទៅលើតំបន់ដែលខ្លួនកាន់កាប់ក្នុងដែនទឹករបស់ខ្លួននៅសមុទ្រចិនខាងត្បូង។[21] ការលើកឡើងបែបនេះគឺក្រោយពេលដែលប្រធានាធិបតីហ្វីលីពីនបានអនុញ្ញាតឱ្យសហរដ្ឋអាមេរិកប្រើប្រាស់មូលដ្ឋានយោធារបស់ខ្លួនចំនួន០៤បន្ថែមទៀតនាពេលកន្លងទៅ ដែលទីតាំងទាំងនោះស្ថិតក្បែរតៃវ៉ាន់ និងសមុទ្រចិនខាងត្បូង។[22]

ក្រៅពីជម្លោះប្រវត្តិសាស្ត្រ និងនយោបាយហើយជម្លោះនេះក៏បណ្តាលមកពីការប្រណាំងប្រជែង ដើម្បីកាន់កាប់នូវធនធានធម្មជាតិក្នុងតំបន់នោះផងដែរសម្រាប់បម្រើដល់តម្រូវការ និងសេដ្ឋកិច្ចនាពេលបច្ចុប្បន្ន និងថ្ងៃអនាគត។ សម្រាប់ចិន តំបន់សមុទ្រចិនខាងត្បូងគឺជាប្រភពនៃធនធានថាមពលដ៏ធំមួយ ដែលអាចជួយលើវិស័យថាមពល និងចិញ្ចឹមកំណើនសេដ្ឋកិច្ចរបស់ខ្លួន ដ្បិតធនធានប្រេងបម្រុងទុករបស់ចិនមានតែ១.១% ប៉ុណ្ណោះនៃធនធានប្រេងសកល ខណៈដែលចិនប្រើប្រាស់រហូតជាង ១០%នៃការផលិតប្រេងជាសកល។ លើសពីនេះតំបន់សមុទ្រចិនខាងត្បូងក៏ជាជម្រកនៃធនធាន និងផលនេសាទដ៏ច្រើមហិមាដែលអាចនឹងផ្គត់ផ្គង់តម្រូវការរបស់ចិនផងដែរ ដ្បិតទៅថ្ងៃខាងមុខពិភពលោកនឹងពឹងផ្អែកខ្លាំងទៅលើភាពជាម្ចាស់ទៅលើធនធានទាំងនេះ។[23] សម្រាប់ហ្វីលីពីនវិញ សមុទ្រចិនខាងត្បូងជាទីតាំងដែលផ្ទុកនូវឧស្ម័នធម្មជាតិទំហំធំ និងដែលផ្តល់នូវលក្ខខន្តិកៈចាំបាច់សម្រាប់ប្រទេសនេះ ដែលកំពុងព្យាយាមដើរចេញពីការប្រើប្រាស់រោងចក្រថាមពលដើរដោយ

---

[19] Macaraig E., Z., & Fenton A., J., (2021)., Analyzing the Causes and Effects of the South China Sea Dispute; https://www.journalofterritorialandmaritimestudies.net/_files/ugd/36708f_b68a81a820e94ca0a35e5430cd9dda9f.pdf?index=true

[20] Ibid

[21] Analysts: China-Philippine Territorial Dispute May Foster Insecurity in South China Sea

[22] US gains military access to Philippine bases close to Taiwan and South China Sea; https://edition.cnn.com/2023/04/04/asia/us-philippines-military-base-access-intl-hnk-ml/index.html

[23] Macaraig E., Z., & Fenton A., J., (2021)., Analyzing the Causes and Effects of the South China Sea Dispute; https://www.journalofterritorialandmaritimestudies.net/_files/ugd/36708f_b68a81a820e94ca0a35e5430cd9dda9f.pdf?index=true

ផ្សេងៗ។[24] ហ្វីលីពីនក៏តែងអាស្រ័យផលលើនេសាទពីតំបន់នេះផងដែរ ដែលឆ្លុះបញ្ចាំងពីសារៈសំខាន់នៃដែនទឹកនេះសម្រាប់ហ្វីលីពីន។

**ផ្នែកទី២៖ ស្ថានភាពទូទៅនៃតំបន់ជម្លោះ**

ក្រោយពីបានស្ងប់ស្ងាត់ទៅមួយរយៈក្រោយពីអតីតប្រធានាធិបតីលោក Rodrigo Duterte ឡើងកាន់អំណាចដោយលោកបានប្រើគោលនយោបាយឆ្ពោះទៅរកចិន "Pivot to China" រហូតហ៊ាននិយាយថារូបលោកមិនមែនជាអាយ៉ងរបស់អាមេរិក[25] ជម្លោះនេះចាប់ផ្តើមកើនឡើងកំដៅឡើងវិញក្រោយលោកប្រធានាធិបតី Ferdinand Romualdez Marcos Jr. ឡើងកាន់អំណាចក្នុងឆ្នាំ២០២២។ ការប្រឈមមុខដាក់គ្នាកាន់តែបន្តកើនឡើងជាលំដាប់ក្រោយការអនុញ្ញាតឱ្យកងទ័ពអាមេរិកចូលប្រើមូលដ្ឋានយោធារបស់ហ្វីលីពីន រហូតមានការបាញ់ទឹកដាក់គ្នាជារឿយៗរវាងកងកម្លាំងចិន និងហ្វីលីពីន។[26] ខាងក្រោមយើងនឹងពិនិត្យលើវឌ្ឍនភាពទូទៅ និងបញ្ហាមួយចំនួននៃជម្លោះ។

**កថាខណ្ឌទី១៖ វឌ្ឍនភាពទូទៅនៃជម្លោះ**

ក្នុងរយៈពេល១០ឆ្នាំចុងក្រោយនេះ ជម្លោះនៅសមុទ្រចិនខាងត្បូងបានកើតមានជាបន្តបន្ទាប់។ នៅពេលដែលចិនសាងសង់កោះសិប្បនិម្មិតតនៅកណ្តាលសមុទ្រចិនខាងត្បូង អ្វីដែលជាអតីតតំបន់ដីដុះធម្មជាតិត្រូវបានប្រែក្លាយទៅជាកោះខ្សាច់ដែលមានវាលអាកាស ផ្លូវថ្នល់ អគារ និងមូលដ្ឋានសម្រាប់ប្រព័ន្ធមីស៊ីលផងដែរ។ ក្នុងរយៈពេលតិចជាងពីរឆ្នាំ ប្រទេសចិនបានប្រែក្លាយថ្មប៉ប្រះទឹកចំនួន ៧ ទៅជាមូលដ្ឋានយោធាចំនួន ៧ ដែលធ្វើឱ្យសមុទ្រចិនខាងត្បូងក្លាយជាតំបន់ដែលមានជម្លោះសមុទ្រច្រើនបំផុតក្នុងពិភពលោក [27] ។

តំបន់សមុទ្រនេះត្រូវបានគេប៉ាន់ប្រមាណថាមានប្រេងឆៅជាង ១១ ពាន់លានបារ៉ែល ឧស្ម័នធម្មជាតិ ១៩០ ពាន់ពាន់លានហ្វីតគូប[28] និងតំណាងជាង ១០% នៃធនធាននេសាទរបស់ពិភពលោក។ អ្វីដែលសំខាន់ជាងនេះទៅទៀតនោះ ប្រហែល ៣០% នៃពាណិជ្ជកម្មតាមសមុទ្រសកលលោកឆ្លងកាត់សមុទ្រចិនខាងត្បូង

---

[24] Ibid

[25] Philippines: Rodrigo Duterte's pivot to China; https://www.aljazeera.com/opinions/2016/10/14/philippines-rodrigo-dutertes-pivot-to-china

[26] China, Philippines Tensions Risk Wider Conflict that Could Draw in the U.S. https://www.usip.org/publications/2023/08/china-philippines-tensions-risk-wider-conflict-could-draw-us

[27] Damn, M.J. (2020). Introduction to South China Sea military capability studies, South China Sea military capability series, July, 2020.

[28] "Territorial Disputes in the South China Sea", Council on Foreign Relations, 2021, https://www.cfr.org/global-conflict-tracker/conflict/territorial-disputes-south-china-sea.

តាមផ្លូវរបស់ខ្លួនទៅកាន់កំពង់ផែ ដែលមានការជួញដូរយ៉ាងមមាញឹកនៅអាស៊ីអាគ្នេយ៍[29]។ ដោយសារទិដ្ឋភាពទាំងនេះ សមុទ្រចិនខាងត្បូងគឺជាតំបន់ដែនសមុទ្រដែលមានការប្រកួតប្រជែងខ្លាំង និងដែលត្រូវបានទាមទារកម្មសិទ្ធិជាច្រើនផ្នែកដោយប្រទេសចំនួនប្រាំមួយនាពេលបច្ចុប្បន្ននេះ។

ជម្លោះក្នុងចំណោមរដ្ឋទាំងប្រាំមួយគឺហ្វីលីពីន វៀតណាម ចិន ប្រ៊ុយណេ និងម៉ាឡេស៊ី និងឥណ្ឌូនេស៊ីនៅតែមិនទាន់ដោះស្រាយអស់ជាច្រើនទសវត្សរ៍មកហើយ។ រដ្ឋដែលជាភាគីជម្លោះ មានការទាមទារអធិបតេយ្យដែនកោះខុសគ្នា និងជួនកាលទៀយត្រួតស៊ីគ្នា ដោយផ្អែកលើទិន្នន័យ និងអំណះអំណាងប្រវត្តិសាស្ត្រ និងភូមិសាស្ត្រផ្សេងៗគ្នា[30] ។ ជាឧទាហរណ៍ បច្ចុប្បន្ននេះ ប្រទេសចិនបានទាមទារជាង ៨០ភាគរយនៃកោះនេះ ខណៈដែលវៀតណាមទាមទារអធិបតេយ្យភាព ទាំងស្រុងលើកោះ Paracels និង Spratly [31]។

មូលហេតុដំបូងនៃជម្លោះ និងសំខាន់បំផុត ធនធានធម្មជាតិនៃតំបន់គឺជាលក្ខណៈពិសេសប្លែកពីគេ នៃសមុទ្រចិនខាងត្បូងដែលតាមពិតទៅ ជាតំបន់ដែលសម្បូរទៅដោយទិដ្ឋភាពនេះ ដោយសារខ្ពង់រាបទ្វីបដ៏ធំទូលាយ ទឹករាក់ដែលទាក់ទង។ ការចូលរួមចំណែកនៃទន្លេដែលហូរលឿនជាច្រើន និងជីវចម្រុះដ៏អស្ចារ្យរបស់វាផងដែរ [32]។ បញ្ហាមួយទៀតដែលសំខាន់គឺស្ថានភាពភូមិសាស្ត្រនៃតំបន់ជម្លោះ។ ច្រកផ្លូវទៅកាន់ច្រកសមុទ្រម៉ាឡាកា និងកំពង់ផែសិង្ហបុរី នៅលើផ្លូវដឹកជញ្ជូនទំនិញដ៏សំខាន់បំផុតមួយរបស់ពិភពលោក ការច្របាច់កនៅលើកោះ Paracel និងកោះ Spratly ក៏ធានានូវការគ្រប់គ្រងលើការផ្គត់ផ្គង់សេដ្ឋកិច្ចនៃអាស៊ីផងដែរ [33]។

ជាងនេះទៅទៀត សម្រាប់ប្រទេសជុំវិញនោះ សមុទ្រចិនខាងត្បូងគឺជាប្រភពចម្បងនៃស្បៀងអាហារដែលស្មើនឹង ៨% នៃផលិតកម្មនេសាទពាណិជ្ជកម្មសរុបរបស់ពិភពលោក ហើយទទួលខុសត្រូវក្នុងការផ្តល់អាហារ ដល់ប្រទេសដែលមានប្រជាជនច្រើនបំផុតនាពេលបច្ចុប្បន្ននេះ ចាប់ពីប្រជាជនប៉ាគីស្ថានចំនួន ២២៦ លាននាក់ទៅកាន់ប្រទេសចិនដែលមានប្រជាពលរដ្ឋ ១.៤ ពាន់លាននាក់ [34] ។ លើសពីនេះទៅទៀត សមុទ្រចិន

[29] Khoury, E. (2017). "Recent trends in the South China Sea disputes", Asia Focus#16 – Asia Programme, Insititut de relations internationales et stratégiques.

[30] Wang, K.H. (2015). "Peaceful settlement of disputes in the South China Sea through fisheries resources cooperation and management", Maryland series in Contemporary Asian Studies: Vol.2015: No. 3, Article 1

[31] Storey, I. (2014). "Discordes en Mer de Chine Méridionale : Les Eaux Troubles du Sud-Est Asiatique", Institut français des relations internationales, 2014/3 Automne, pages 34 à 47.

[32] Roche, Y. (2013). "La Mer de Chine Méridionale : un Jeu Frontalier Majeur en Asie du Sud-Est", OpenEdition Journals, L'Espace Politique, 21/2013-3.

[33] Roche, Y. (2013). "La Mer de Chine Méridionale : un Jeu Frontalier Majeur en Asie du Sud-Est", OpenEdition Journals, L'Espace Politique, 21/2013-3.

[34] Khoury, E. (2017). "Recent trends in the South China Sea disputes", Asia Focus#16 – Asia Programme, Insititut de relations internationales et stratégiques.

ខាងត្បូងដែលជាតំបន់សេដ្ឋកិច្ច និងយុទ្ធសាស្ត្រដ៏សំខាន់បំផុតមួយក្នុងពិភពលោក មានសារៈសំខាន់មិន អាចប្រកែកបានចំពោះរបៀបរស់នៅរបស់អាស៊ីអាគ្នេយ៍[35]។ តំបន់ដែលមានសារៈសំខាន់បែបនេះ មិនត្រូវបានកំណត់ចំពោះផលប្រយោជន៍របស់រដ្ឋនៅជុំវិញនោះទេ វាហួសពីរដ្ឋដែលទាមទារនៅក្នុងតំបន់ ហើយថែមទាំងនាំតំបន់នេះទៅចាប់អារម្មណ៍ពីតួអង្គដទៃទៀតផងដែរ។

ជារួមក្នុងពេលបច្ចុប្បន្នដែនទឹកមានជម្លោះនេះបាននឹងកំពុងកើនឡើងកំដៅជាថ្មី ក្នុងបរិបទដែលចិន និងហ្វីលីពីនហាក់ប្រកាន់ជំហរដាច់ណាត់ក្នុងការទាមទារដែនអធិបតេយ្យរៀងខ្លួន។ បូករួមពីវត្តមានបន្ថែមពីកងទ័ពប្រទេសមិនស្ថិតក្នុងតំបន់ ដែលករណីនេះគឺសហរដ្ឋអាមេរិក និងមូលដ្ឋានយោធាដែលទើបទទួលបានពីហ្វីលីពីនផង បាននឹងកំពុងរុញជម្លោះនេះឱ្យហួសពីការរកច្រកចេញបាន។ ជាក់ស្តែងថ្មីៗនេះតែងមានការប៉ះទង្គិចពាក្យសម្តី និងការប៉ះទង្គិចរវាងកងទ័ពជើងទឹករបស់ប្រទេសទាំងពីរផងដែរ បន្ថែមពីនេះចិនម្តងទៀតបានទាមទារឱ្យហ្វីលីពីនអូសខ្មោចកប៉ាល់ចេញពីតំបន់ថ្មប៉ប្រះទឹកក្នុងដែនទឹកមានជម្លោះផងដែរ។[36]

**កថាខណ្ឌទី២៖ ភាពជាប់គាំង និងការមិនអាចដោះស្រាយបានតាមផ្លូវច្បាប់**

ជម្លោះដែនអធិបតេយ្យនៅសមុទ្រចិនខាងត្បូងគឺនៅតែ ពិបាកឈានដល់ការដោះស្រាយសម្រេចបិទបញ្ចប់។ ទោះបីជាមានការវិវត្តគួរឱ្យកត់សម្គាល់ និងការធានាឡើងវិញតាមរយៈសេចក្តីថ្លែងការណ៍ផ្លូវការនូវកិច្ចសហប្រតិបត្តិការនានាក៏ដោយ ក៏ស្ថានការណ៍នៅតែតានតឹង និងហាក់មានសភាពគ្រោះថ្នាក់ដោយសារការប្រណាំងប្រជែងសព្វាវុធ និងភូមិសាស្ត្រនយោបាយដែលបន្តធ្វើឱ្យមានការកើនឡើងដែលអាចកើតមានកាន់ តែគួរឱ្យព្រួយបារម្ភ។

ចាប់តាំងពីបង្កើតឡើងមក អាស៊ាន ដែលជាអង្គការអន្តរជាតិតែមួយគត់ដែលមានឥទ្ធិពលក្នុងតំបន់ក្នុងការដោះស្រាយជម្លោះនេះ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការធានាការសន្ទនា ការពង្រីកផលប្រយោជន៍ ក្នុងតំបន់ត្រួតស៊ីគ្នា និងការអភិវឌ្ឍនៃការជឿទុកចិត្ត និងកិច្ចសហប្រតិបត្តិការរវាងភាគីនៃតំបន់ជម្លោះ។ ស្មារតីនៃសេចក្តីថ្លែងការណ៍ឆ្នាំ ២០០២ របស់អាស៊ានពិតជាគាំទ្រដល់ សេចក្តីថ្លែងការណ៍នានផ្សេងទៀតស្តីពីការប្រតិបត្តិនៃភាគីនៅសមុទ្រចិនខាងត្បូង ជាក់ស្តែងកិច្ចព្រមព្រៀងដែលបានចុះហត្ថលេខាដោយទីក្រុងប៉េកាំងក្នុងឆ្នាំ ១៩៩៧ ដែលបានអំពាវនាវឱ្យមាន ការដោះស្រាយជម្លោះដោយសន្តិវិធីនៅសមុទ្រចិនខាងត្បូង។ ចាប់តាំងពីពេលនោះ

[35] Khoury, E. (2017). "Recent trends in the South China Sea disputes", Asia Focus#16 – Asia Programme, Insititut de relations internationales et stratégiques.

[36] What's behind rising China-Philippines tensions in the South China Sea?; https://www.aljazeera.com/news/2023/8/9/whats-behind-rising-china-philippines-tensions-in-the-south-china-sea

មក អង្គការបានផ្តួចផ្តើម និងការប៉ុនប៉ងជាច្រើនដើម្បីបង្កើតវេទិកាដោះស្រាយជម្លោះ[37] ។ យ៉ាងណាក៏ដោយ ទាំងនោះបានបង្ហាញឲ្យឃើញយ៉ាងសាមញ្ញថា អាស៊ានមិនមានសមត្ថភាពក្នុងការដើរតួជាអ្នកដឹកនាំ ហើយថា ខ្លួនមិនអាចសម្របខ្លួនតាមបរិបទនយោបាយ និងបញ្ហាប្រឈមបច្ចុប្បន្នបានឡើយ។ ជាអកុសល ដំណើរការធ្វើ សេចក្តីសម្រេចចិត្តរបស់អាស៊ាន អាស្រ័យទៅលើការឯកភាពគ្នាជាឯកច្ឆន្ទ ឬកុងសង់ស៊ីសនៅក្នុងចំណោម សមាជិករបស់ខ្លួន ដែលជាកិច្ចការដ៏លំបាកក្នុងការសម្រេចបាន នៅពេលដែលសមាជិករបស់ខ្លួនភាគច្រើនពឹង ផ្អែកទាំងស្រុងលើប្រទេសចិនសម្រាប់ការអភិវឌ្ឍន៍ និងពាណិជ្ជកម្មរបស់ពួកគេ។ ជាឧទាហរណ៍ មានការ លើកឡើងថា កម្ពុជា និងឡាវ បានសម្រេចចិត្តដកខ្លួនចេញពីជម្លោះនេះដោយសារតែការពឹងផ្អែកស្ទើរតែ ទាំងស្រុងលើភាពជាដៃគូរបស់ចិនដោយរលូន ដែលគាំទ្រជាផ្លូវការនូវការទាមទារ របស់ចិន[38] ។ បន្ថែមពីលើនេះ ប្រទេសចិនបានជំទាស់ជាយូរមកហើយក្នុងការដោះស្រាយបញ្ហាអាស៊ីប៉ូព៌ានៅក្នុងស្ថាប័នពហុភាគី ហើយបាន ពេញចិត្តការចរចាទ្វេភាគីជាមួយប្រទេសដទៃទៀតនៅក្នុងតំបន់។ ដោយហេតុផលនេះ ប្រទេសចិនមានទំនោរ ក្នុងការកសាងទំនាក់ទំនងទ្វេភាគីជាជាងនៅក្នុងវេទិការអាស៊ានជាច្រើន [39]។

នៅតំបន់ដែលពិបាក និងស្មុគស្មាញងាយឲ្យមានជម្លោះដូចសមុទ្រចិនខាងត្បូង ប្រាកដណាស់យើងគួរ តែមានច្បាប់អន្តរជាតិមួយសម្រាប់ការពារកុំឲ្យមានជម្លោះយ៉ាងមានប្រសិទ្ធភាព។ ឯកសារយោងសំខាន់មួយ ទៀតសម្រាប់ការជូនដំណឹងអំពីអនាគតនៃជម្លោះនេះអាចនិយាយបានថា ជាសេចក្តីសម្រេចរបស់តុលាការ មជ្ឈត្តការពិសេសឆ្នាំ ២០១៦។ តុលាការទីក្រុងឡាអេ បានកាត់សេចក្តីប្រឆាំងនឹង ការទាមទាររបស់ចិននៅក្នុង សមុទ្រចិនខាងត្បូងដោយប្រកាសថាពួកគេមិនមានមូលដ្ឋានផ្លូវច្បាប់។[40] នៅក្នុងសេចក្តីសម្រេចដដែលនេះ តុលាការមជ្ឈត្តការដែលមានមូលដ្ឋាននៅទីក្រុងឡាអេ បានរកឃើញថាអ្វីដែលគេហៅថាខ្សែបន្ទាត់ប្រាំបួន ចំណុច (Nine-Dash Line) របស់ទីក្រុងប៉េកាំងនៃការទាមទារទឹកដីរបស់ខ្លួននៅក្នុងសមុទ្រចិនខាងត្បូងមិន មានមូលដ្ឋានផ្លូវច្បាប់នោះទេ។ ដោយបដិសេធការទាមទាររបស់ខ្លួនអំពី "ខ្សែបន្ទាត់ប្រាំបួនចំណុច" ដែលជា ផ្នែកនៃសំណុំរឿងដែលហ្វីលីពីនបានចោទប្រកាន់ ជាលើកដំបូងប្រឆាំងនឹងប្រទេសចិនក្នុងឆ្នាំ ២០១៣។ ប៉ុន្តែ

---

[37] Sakamoto, S. (2021). "The global South China Sea issue", The Diplomat, July 04, 2021, https://thediplomat.com/2021/07/the-global-south-china-sea-issue/

[38] "Territorial Disputes in the South China Sea", Council on Foreign Relations, 2021, https://www.cfr.org/global-conflict-tracker/conflict/territorial-disputes-south-china-sea.

[39] Storey, I. (2014). "Discordes en Mer de Chine Méridionale : Les Eaux Troubles du Sud-Est Asiatique", Institut français des relations internationales, 2014/3 Automne, pages 34 à 47.

[40] The South China Sea Arbitration Award of 12 July 2016; https://docs.pca-cpa.org/2016/07/PH-CN-20160712-Award.pdf

ប្រទេសចិនដែលមិនទទួលស្គាល់សេចក្តីសម្រេច របស់តុលាការអន្តរជាតិបានព្រមានថា ខ្លួននឹងធ្វើអ្វីគ្រប់យ៉ាងនៅក្នុងអំណាចរបស់ខ្លួនដើម្បី ការពារអធិបតេយ្យភាពរបស់ខ្លួន។[41]

[41] Sakamoto, S. (2021). "The global South China Sea issue", The Diplomat, July 04, 2021, https://thediplomat.com/2021/07/the-global-south-china-sea-issue/

# ជំពូកទី២៖ យន្តការ និងនីតិវិធី ដែលធ្លាប់បានអនុវត្តលើជម្លោះ

# ជំពូកទី២៖ យន្តការ និងនីតិវិធីដែលធ្លាប់បានអនុវត្តលើជម្លោះ

គិតចាប់ពីការផ្ទុះឡើងនៃការទាមទារ និងជម្លោះមក មានការលើកឡើងពីអំណះអំណាងផ្សេងៗរបស់ភាគីនីមួយៗ ហើយន្តការជាច្រើនត្រូវបានប្រើប្រាស់សម្រាប់ព្យាយាមដោះស្រាយបញ្ចប់ជម្លោះនេះ។ ក្នុងជំពូកនេះយើងនឹងពិនិត្យលើ ជំហរ និងអំណះអំណាងរបស់គូភាគីនីមួយៗ(ផ្នែកទី១) យន្តការដែលធ្លាប់បានប្រើប្រាស់ដើម្បីព្យាយាមបញ្ចប់ជម្លោះ(ផ្នែកទី២) មូលហេតុនៃការមិនអាចដោះស្រាយបាននៃជម្លោះ(ផ្នែកទី៣)។

## ផ្នែកទី១៖ ជំហរ និងអំណះអំណាងរបស់គូភាគី

នៅក្នុងការដោះស្រាយជម្លោះសមុទ្រចិនខាងត្បូងរវាងចិន និងហ្វីលីពីនយ៉ាងតានតឹងមួយនេះ គឺមានអំណះអំណាងរៀងៗខ្លួន ដែលទាក់ទងទៅនឹងភស្តុតាង និងការលើកយកគោលការណ៍ រួមជាមួយស្មារតីច្បាប់អន្តរជាតិផ្សេងៗ ដែលប្រទេសទាំងពីរនេះបានលើកឡើងជាសំអាង។ ខាងក្រោមនេះយើងនឹងមើលឃើញពីជំហរ និងអំណះអំណាងរបស់ខ្លួនក្នុងការទាមទារ ដែនអធិបតេយ្យ ក្នុងសមុទ្រចិនខាងត្បូង។

### កថាខណ្ឌទី១៖ ជំហរ និងអំណះអំណាងរបស់ចិន

ប្រទេសចិន បានប្រើសិទ្ធិប្រវត្តិសាស្ត្រ ដែលជាចំណុចមួយដែលប្រទេសចិនលើកយកមក ក្នុងការទាមទារយកសមុទ្រចិនខាងត្បូង។ សិទ្ធិប្រវត្តិសាស្ត្រគឺ មិនមានអ្វីដែលបញ្ជាក់ច្បាស់ក្នុងច្បាប់អន្តរជាតិ ប៉ុន្តែគេអាច យកសញ្ញាណសិទ្ធិប្រវត្តិសាស្ត្រមួយចំនួនដែលយោងតាមរយៈឯកសារអន្តរជាតិដូចជា ឆ្នេរប្រវត្តិសាស្ត្រ៖ អនុស្សារណៈរបស់លេខាធិការដ្ឋានអង្គការសហប្រជាជាតិ (Historic Bays: Memorandum by the Secretariat of the United Nations) និង របបគតិយុត្តនៃដែនទឹកប្រវត្តិសាស្ត្រ រួមទាំងឆ្នេរប្រវត្តិសាស្ត្រ (Juridical Regime of Historic Waters, including Historic bays) ដែលបានបកស្រាយខ្លះៗទាក់ទងទៅនឹងពាក្យសិទ្ធិប្រវត្តិសាស្ត្រ។ នៅក្នុងរបាយការណ៍របស់ប្រទេសចិនមួយចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ២០១៦[42] ដែលមានឈ្មោះថា *ចិនប្រកាន់ជំហរដោះស្រាយតាមរយៈការចរចាជម្លោះពាក់ព័ន្ធរវាងចិននិងហ្វីលីពីននៅសមុទ្រចិនខាងត្បូង* បាននិយាយបញ្ជាក់ពីបញ្ហាដែលចិនបានអះអាងថាមិនយល់ព្រមនិងមិនទទួលស្គាល់សេចក្តីសម្រេចមជ្ឈត្តការអន្តរជាតិ និងបាននិយាយអំពីជំហររបស់ប្រទេសចិនដែលប្រកាន់ខ្ជាប់ថា ប្រទេសហ្វីលីពីនបានឈ្លានពាន ដោយខុសច្បាប់ និងបានរួមបញ្ចូលជាមួយសិទ្ធិប្រវត្តិសាស្ត្រ។

ដោយប្រទេសចិនបានប្រកាន់យកជំហររបស់ខ្លួន ដែលនិយាយពីសិទ្ធិប្រវត្តិសាស្ត្រ គឺមិនមានភាពសមស្របទៅតាមអនុសញ្ញាសហប្រជាជាតិស្តីពីនីតិសមុទ្រ(UNCLOS) ដោយការទាមទារកាប់កាប់សមុទ្រសមុទ្រ

[42] Ministry of Foreign Affairs of the People´s Republic of China Adheres to the Position of Setting Through Negotiation the Relevant Disputes Between China and the Philippines in the South China Sea, (13,Juy, 2016) < https://www.fmprc.gov.cn/nanhai/eng/snhwtlcwj_1/201607/t20160713_8527301.htm >

ចិនខាងត្បូង គឺទាមទារទាំងធនធានទាំងអស់ដែលនៅក្នុងសមុទ្រចិនខាងត្បូង ដែលវាប៉ះពាល់ទៅដល់សិទ្ធិទទួលបានតំបន់សេដ្ឋកិច្ចផ្តាច់មុខ (EEZ) ដែលមានចែងក្នុងមាត្រា៥៩ នៃអនុសញ្ញាសហប្រជាជាតិស្តីពីនីតិសមុទ្រ(UNCLOS)[43]។ ប្រទេសចិនក៏បានទទួលស្គាល់ចំណុចខ្លះ នៃអនុសញ្ញាសហប្រជាជាតិស្តីពីនីតិសមុទ្រ។ ប៉ុន្តែការទទួលស្គាល់របស់ចិន គឺបានទទួលស្គាល់ទៅលើ អនុសញ្ញាសហប្រជាជាតិស្តីពីនីតិសមុទ្រ ទាក់ទងទៅនឹងការការពារសិទ្ធិនិងកម្មសិទ្ធិរបស់ខ្លួនទៅវិញ។ មិនត្រឹមតែប៉ុណ្ណោះ ប្រទេសចិនថែមទាំងចោទប្រកាន់ទៅលើហ្វីលីពីនថា បានកាន់កាប់កោះរបស់ចិនខុសច្បាប់ និងរំលោភសិទ្ធិផលប្រយោជន៍នៅក្នុងដែនសមុទ្រចិន ហើយការចាប់ផ្តើមរបស់ហ្វីលីពីនទៅលើការប្តឹងមជ្ឈត្តការគឺជាទង្វើទុច្ចរិត (Bad faith) និងមិនអនុលោមតាមច្បាប់អន្តរជាតិដ្បិតបណ្តឹងនោះកើតឡើងជាឯកតោភាគី។

ទាក់ទងទៅនឹងការច្រានចោល និងមិនទទួលស្គាល់យុត្តាធិការរបស់តុលាការមជ្ឈត្តការ ចិនបានលើកយកមាត្រា ២៨៩ នៃអនុសញ្ញាសហប្រជាជាតិស្តីពីនីតិសមុទ្រ(UNCLOS)[44] មកប្រើប្រាស់។ ក្នុងករណីដូចមាត្រានេះបានចែង ដោយហ្វីលីពីនបានកំណត់លក្ខណៈខុស និងមានចេតនាលើកឡើងពីបញ្ហាទឹកដី ដែលមិនមែនស្ថិតនៅក្រោមអនុសញ្ញាសហប្រជាជាតិស្តីពីនីតិសមុទ្រ(UNCLOS) ហើយប្រទេសបានបន្ថែមថា ករណីមានជម្លោះនេះមិនគួរស្ថិតនៅក្រោមយុត្តាធិការតុលាការឡើយ ទង្វើនេះគឺជាការរំលោភបំពានលើនីតិវិធីរបស់អនុសញ្ញាសហប្រជាជាតិស្តីពីនីតិសមុទ្រ(UNCLOS) ។ ដោយការផ្តើមពីមជ្ឈត្តការជាឯកតោភាគី ហ្វីលីពីនបានបំពាននីតិវិធីដោះស្រាយវិវាទរបស់ អនុសញ្ញាសហប្រជាជាតិស្តីពីនីតិសមុទ្រ។ មូលហេតុចម្បងដែលលើកឡើងដោយ ហ្វីលីពីន គឺជាបញ្ហានៃអធិបតេយ្យភាពទឹកដីលើកោះមួយចំនួន និងថ្មប៉ប្រះទឹករបស់ សមុទ្រចិនខាងត្បូង ហើយដំណោះស្រាយនៃបញ្ហាពាក់ព័ន្ធក៏ជាផ្នែកសំខាន់មួយនៃការកំណត់ព្រំដែនសមុទ្ររវាងចិន និងហ្វីលីពីនផងដែរ។ ដោយយោងតាម មាត្រា ២៩៨ នៃអនុសញ្ញាសហប្រជាជាតិស្តីពីនីតិសមុទ្រ(UNCLOS)[45] ប្រទេសចិនបានចេញសេចក្តីប្រកាសមួយ ដោយមិនរាប់បញ្ចូលពីនីតិវិធីដោះស្រាយវិវាទជាកាតព្វកិច្ចនៃជម្លោះនីតិសមុទ្រ ទាក់ទងនឹងបញ្ហាផ្សេងទៀត ការកំណត់ព្រំដែនសមុទ្រ ច្រកប្រវត្តិសាស្ត្រ ឬចំណងជើង សកម្មភាពយោធា និងការអនុវត្តច្បាប់។ ចំពោះបញ្ហាទាក់ទងនឹងដែនដី និងការកំណត់ព្រំដែនសមុទ្រ ចិនមិនទទួលយកមធ្យោបាយដោះស្រាយវិវាទណាមួយដែលដាក់លើខ្លួននោះទេ ហើយក៏មិនទទួលយកដំណោះស្រាយដោយមានភាគីទីបីដែរ។ នៅថ្ងៃទី ២៥ ខែសីហា ឆ្នាំ ២០០៦ ប្រទេសចិនបានតម្កល់ដោយអនុលោមតាមមាត្រា ២៩៨ នៃអនុសញ្ញាសហប្រជាជាតិស្តីពីនីតិសមុទ្រ(UNCLOS) ជាមួយនឹងសេចក្តីប្រកាសរបស់អគ្គលេខាធិការអង្គ

[43] Artcle 59, UNCLOS

[44] Article 289, UNCLOS

[45] Article 298, UNCLOS

ការសហប្រជាជាតិដោយបញ្ជាក់ថា "រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិនមិនទទួលយកនីតិវិធីណាមួយដែលមានចែងនៅក្នុងផ្នែកដែលទាក់ទងទៅនឹងគ្រប់ប្រភេទវិវាទដែលមានចែងក្នុងកថាខណ្ឌទាំងអស់នៃអនុសញ្ញានេះ"។ ចំពោះវិវាទទាក់ទងនឹងការកំណត់ព្រំដែនសមុទ្រ ឆ្នេរសមុទ្រប្រវត្តិសាស្ត្រ ឬចំណងជើង សកម្មភាពអនុវត្តច្បាប់ និងយោធា មិនរាប់បញ្ចូលយ៉ាងច្បាស់ពីនីតិវិធីដោះស្រាយវិវាទជាកាតព្វកិច្ចរបស់អនុសញ្ញាសហប្រជាជាតិស្តីពីនីតិសមុទ្រ(UNCLOS) ។

តាមរយៈបណ្ដឹងស្នើបង្កើតតុលាការមជ្ឈការជាឯកតោភាគី ហ្វីលីពីនបានរំលោភសិទ្ធិរបស់ចិនក្នុងការជ្រើសរើសមធ្យោបាយដោះស្រាយជម្លោះ តាមឆន្ទៈរបស់ខ្លួនក្នុងនាមជារដ្ឋភាគីនៃអនុសញ្ញាសហប្រជាជាតិស្ដីពីនីតិសមុទ្រ(UNCLOS)។ ដោយយោងតាមមាត្រា ២៨០ នៃអនុសញ្ញាសហប្រជាជាតិស្ដីពីនីតិសមុទ្រ(UNCLOS)[46] បានចែងថា គ្មានបញ្ញត្តិណាមួយនៅក្នុងផ្នែកនេះធ្វើឲ្យប៉ះពាល់ដល់សិទ្ធិរដ្ឋភាគី នៅក្នុងការព្រមព្រៀងគ្នាដោះស្រាយវិវាទពួកគេ ដែលទាក់ទងទៅនឹងការបកស្រាយ ឬ ការអនុវត្តបញ្ញត្តិនៃអនុសញ្ញានេះ តាមរយៈមធ្យោបាយសន្តិវិធីដែលពួកគេបានជ្រើសរើសដោយខ្លួនឯងផ្ទាល់នៅពេលណាមួយនោះទេ។ យោងតាមមាត្រា ២៨១ នៃអនុសញ្ញាសហប្រជាជាតិស្ដីពីនីតិសមុទ្រ(UNCLOS)[47] ក៏បានចែងដែរថា ប្រសិនបើរដ្ឋភាគីដែលជាភាគីជម្លោះទាក់ទងនឹងការបកស្រាយ ឬការអនុវត្តអនុសញ្ញានេះ បានយល់ព្រមស្វែងរកដំណោះស្រាយដោយសន្តិវិធីតាមជម្រើសរបស់ពួកគេ នោះនីតិវិធីដែលមានចែងក្នុងផ្នែកនេះអនុវត្តតែក្នុងករណីដែលមិនមានដំណោះស្រាយ តាមរយៈ ការទទួលយកមធ្យោបាយបែបនេះ ហើយកិច្ចព្រមព្រៀងរវាងភាគី មិនរាប់បញ្ចូលនីតិវិធីបន្ថែមណាមួយឡើយ។ ដោយសារប្រទេសចិន និងហ្វីលីពីនបានបង្កើតជម្រើសច្បាស់លាស់មួយដើម្បីដោះស្រាយតាមរយៈការចរចាលើជម្លោះដែលពាក់ព័ន្ធ នោះនីតិវិធីដោះស្រាយជម្លោះភាគីទីបីជាកំហិតក្រោមអនុសញ្ញាសហប្រជាជាតិស្ដីពីនីតិសមុទ្រ(UNCLOS) មិនត្រូវបានអនុវត្តទេ។

ប្រទេសចិន និងហ្វីលីពីន ក៏បានប្ដេជ្ញាយ៉ាងម៉ឺងម៉ាត់ក្នុងការដោះស្រាយវិវាទពាក់ព័ន្ធតាមរយៈការចរចា និងការពិគ្រោះយោបល់នៅក្នុងសេចក្ដីថ្លែងការណ៍ឆ្នាំ ២០០២ ស្ដីពីការប្រតិបត្តិនៃភាគីនានានៅសមុទ្រចិនខាងត្បូង (DOC) ដែលប្រទេសចិន និងរដ្ឋសមាជិកអាស៊ានបានចុះហត្ថលេខារួមគ្នា។[48] ចិននិងហ្វីលីពីនមិនទាន់មានការចរចាណាមួយដែលរៀបចំឡើង ដើម្បីដោះស្រាយជម្លោះពាក់ព័ន្ធរបស់ខ្លួន នៅសមុទ្រចិនខាងត្បូងនៅឡើយទេ។ ទោះបីជា ព្មយ៉ាងណាក៏ដោយ ប្រទេសទាំងពីរបានធ្វើកិច្ចពិភាក្សាជាច្រើនជុំស្ដីពីការគ្រប់គ្រងត្រឹមត្រូវ

[46] Article 280, UNCLOS

[47] Article 281, UNCLOS

[48] Ministry of Foreign Affairs of the People´s Republic of China Adheres to the Position of Setting Through Negotiation the Relevant Disputes Between China and the Philippines in the South China Sea, (13,Juy, 2016) < https://www.fmprc.gov.cn/nanhai/eng/snhwtlcwj_1/201607/t20160713_8527301.htm >

នៃជម្លោះនៅសមុទ្រ និងបានឈានដល់ការឯកភាពគ្នាលើការដោះស្រាយតាមរយៈការចរចា និងពិគ្រោះយោបល់លើជម្លោះពាក់ព័ន្ធដែលត្រូវបានបញ្ជាក់ម្តងហើយម្តងទៀតនៅក្នុងឯកសារទ្វេភាគីមួយចំនួន។ នៅខែវិច្ឆិកា ឆ្នាំ ២០០២ ប្រទេសចិន និងរដ្ឋសមាជិកអាស៊ានទាំងដប់បានចុះហត្ថលេខាលើ DOC ដែលភាគីទាំងពីរអនុវត្តយ៉ាងធំធេងដើម្បីដោះស្រាយជម្លោះដែនដី និងយុត្តាធិការដោយសន្តិវិធី ដោយមិនប្រើការគំរាមកំហែង ឬការប្រើប្រាស់កម្លាំង តាមរយៈការពិគ្រោះ និងចរចាជាមិត្តដោយរដ្ឋអធិបតេយ្យ។ ពាក់ព័ន្ធដោយផ្ទាល់ ស្របតាមគោលការណ៍ច្បាប់អន្តរជាតិដែលទទួលស្គាល់ជាសកល រួមទាំងអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រឆ្នាំ ១៩៨២។ បន្ទាប់មក ចិន និងហ្វីលីពីនបានបញ្ជាក់ឡើងវិញនូវការប្តេជ្ញាចិត្តនេះ ដែលពួកគេបានធ្វើនៅក្នុង DOC នៅក្នុងឯកសារទ្វេភាគីមួយចំនួន ដូចជាសេចក្តីថ្លែងការណ៍រួមខែកញ្ញា ឆ្នាំ ២០០៤ រវាងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន និងរដ្ឋាភិបាលនៃសាធារណរដ្ឋហ្វីលីពីន និង សេចក្តីថ្លែងការណ៍រួមខែកញ្ញា ឆ្នាំ ២០១១ រវាងសាធារណរដ្ឋប្រជាមានិតចិន និងសាធារណៈរដ្ឋហ្វីលីពីន។ បទប្បញ្ញត្តិពាក់ព័ន្ធនៅក្នុងឧបករណ៍ទ្វេភាគីខាងលើទាំងអស់ និង DOC រួមបញ្ចូលការឯកភាព និងការប្តេជ្ញាចិត្តដូចខាងក្រោមរវាងចិន និងហ្វីលីពីនលើការដោះស្រាយជម្លោះដែលពាក់ព័ន្ធនៅសមុទ្រចិនខាងត្បូង៖ ១.ជម្លោះពាក់ព័ន្ធត្រូវដោះស្រាយរវាងរដ្ឋអធិបតេយ្យដែលពាក់ព័ន្ធដោយផ្ទាល់ ២.វិវាទដែលពាក់ព័ន្ធត្រូវដោះស្រាយដោយសន្តិវិធី តាមរយៈការចរចា និងការពិគ្រោះយោបល់ ដោយផ្អែកលើសមភាព និងការគោរពគ្នាទៅវិញទៅមក និង ៣.រដ្ឋអធិបតេយ្យដែលពាក់ព័ន្ធដោយផ្ទាល់ត្រូវទាក់ទងទៅនឹងការចរចាដំណោះស្រាយចំពោះបញ្ហាទ្វេភាគីជាយថាហេតុ ស្របតាមគោលការណ៍ទទួលស្គាល់ជាសកលនៃច្បាប់អន្តរជាតិ រួមទាំង អនុសញ្ញាសហប្រជាជាតិស្តីពីនីតិសមុទ្រ(UNCLOS) ឆ្នាំ ១៩៨២ ផងដែរ។ តាមរយៈការបញ្ជាក់ម្តងហើយម្តងទៀតការចរចាជាមធ្យោបាយដោះស្រាយវិវាទដែលពាក់ព័ន្ធ និងដោយសង្កត់ធ្ងន់ម្តងហើយម្តងទៀតថាការចរចាត្រូវបានធ្វើឡើងដោយរដ្ឋអធិបតេយ្យដែលពាក់ព័ន្ធដោយផ្ទាល់ នោះបទប្បញ្ញត្តិដែលបានរៀបរាប់ខាងលើច្បាស់ជាបង្កើតផលនៃការមិនរាប់បញ្ចូលមធ្យោបាយណាមួយនៃដំណោះស្រាយភាគីទីបី។ ការឯកភាព និងការប្តេជ្ញាចិត្តខាងលើបង្កើតបានជាកិច្ចព្រមព្រៀងរវាងរដ្ឋទាំងពីរ ដោយមិនរាប់បញ្ចូលការដោះស្រាយជម្លោះភាគីទីបី ដែលជាមធ្យោបាយដោះស្រាយជម្លោះពាក់ព័ន្ធនៅក្នុងសមុទ្រចិនខាងត្បូងរវាងចិន និងហ្វីលីពីន។ នៅក្នុង DOC ប្រទេសចិន និងហ្វីលីពីនក៏បានឈានដល់ការឯកភាពគ្នាដូចជា អនុវត្តការប្រុងប្រយ័ត្នក្នុងពេលដែលចូលរួមក្នុងសកម្មភាព ដែលអាចធ្វើឱ្យជម្លោះកាន់តែខ្លាំងឡើងនិងបំផ្លាញសន្តិភាពនិងស្ថិរភាព និងពង្រឹងកិច្ចខិតខំប្រឹងប្រែង រង់ចាំការដោះស្រាយដោយសន្តិវិធីនៃជម្លោះដែនដី និងយុត្តាធិការ ស្វែងរកមធ្យោបាយ ក្នុងស្មារតីនៃកិច្ចសហប្រតិបត្តិការ និងការយល់ដឹង កសាងទំនុកចិត្ត និងទំនុកចិត្ត និងដើម្បីរុករក ឬធ្វើសកម្មភាពសហប្រតិបត្តិការ រួមមានការការពារបរិស្ថានសមុទ្រ ការស្រាវជ្រាវ

វិទ្យាសាស្ត្រសមុទ្រ សុវត្ថិភាពនៃការធ្វើនាវាចរណ៍ និងការទំនាក់ទំនងនៅសមុទ្រ ប្រតិបត្តិការស្វែងរក និងជួយសង្គ្រោះ និងការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន។

**កថាខណ្ឌទី២៖ ជំហរ និងអំណះអំណាងរបស់ហ្វីលីពីន**

ប្រទេសហ្វីលីពីន បានដាក់សំណើរប្តឹងបង្កើតតុលាការមជ្ឈត្តការពិសេសក្រោមក្របខណ្ឌនៃឧបសម្ព័ន្ធ៧នៃអនុសញ្ញាសហប្រជាជាតិស្តីពីនីតិសមុទ្រ ដោយមានជំនួយរដ្ឋបាលពីតុលាការមជ្ឈត្តការអចិន្ត្រៃយ៍ (PCA) ។ ក្នុងបណ្តឹងនោះហ្វីលីពីនបានស្នើឱ្យតុលាការសម្រេចលើកម្មវត្ថុចំនួន១៥ចំណុច ហើយតុលាការមជ្ឈត្តការពិសេសឧបសម្ព័ន្ធ៧នៃអនុសញ្ញាសហប្រជាជាតិស្តីពីនីតិសមុទ្រ បានចេញសេចក្តីសម្រេចចុងក្រោយតាមរយៈសាលដីការបស់ខ្លួនក្នុងឆ្នាំ២០១៦ ដោយបានសម្រេចទៅលើកម្មវត្ថុទាំង១៥ ដែលបានដាក់ស្នើដោយទីក្រុងម៉ានីល។ បណ្តឹងនេះហ្វីលីពីនបានអះអាងថាធ្វើឡើងក្នុងគោលជំហររបស់ខ្លួនដើម្បីការពារដែនអធិបតេយ្យរបស់ខ្លួន ដែលឈ្លានពានដោយឈ្លានពានដោយប្រទេសចិន នៅសមុទ្រចិនខាងត្បូង។[49]

នៅក្នុងដីកាជាឯកច្ឆន្ទរបស់ខ្លួន តុលាការបានលើកឡើងថា ការទាមទាររបស់ចិនមិនអាចលើសពីដែនអធិបតេយ្យដែលកំណត់ក្នុង អនុសញ្ញាសហប្រជាជាតិស្តីពីនីតិសមុទ្រ (UNCLOS) បានទេ ដែលទីក្រុងប៉េកាំងបានផ្តល់សច្ចាប័ននៅក្នុងឆ្នាំ ១៩៩៦។ ដូចនេះ សិទ្ធិដែនសមុទ្ររបស់ប្រទេសចិនមិនអាចពង្រីកលើសពីការអនុញ្ញាតដោយ អនុសញ្ញាសហប្រជាជាតិស្តីពីនីតិសមុទ្រ (UNCLOS) បានទេ។ តុលាការក៏បានសម្រេចថាការទាមទាររបស់ចិន ចំពោះសិទ្ធិប្រវត្តិសាស្ត្រ និង សិទ្ធិគ្រប់គ្រងដែនអធិបតេយ្យនៅក្នុង ខ្សែបន្ទាត់ប្រាំបួនចំណុច (Nine Dash Line) គឺមិនត្រឹមត្រូវ ទៅតាម អនុសញ្ញាសហប្រជាជាតិស្តីពីនីតិសមុទ្រ (UNCLOS) នោះទេ និងបានបន្ថែមថាការទាមទារនេះគឺផ្ទុយទៅនឹង អនុសញ្ញាសហប្រជាជាតិស្តីពីនីតិសមុទ្រ (UNCLOS) ព្រោះវាលើសពីដែនកំណត់ភូមិសាស្ត្រ ជាពិសេស វាលើសពីសិទ្ធិ គ្រប់គ្រងដែនសមុទ្ររបស់ចិន។ ការទាមទាររបស់ចិនក្នុងសិទ្ធិគ្រប់គ្រងដែនអធិបតេយ្យលើ ខ្សែបន្ទាត់ប្រាំបួនចំណុច (Nine Dash Line) គឺមិនត្រឹមត្រូវទេ ដោយយោងទៅតាម អនុសញ្ញាសហប្រជាជាតិស្តីពីនីតិសមុទ្រ (UNCLOS)។ ចំពោះការដាក់ស្នើចំណុច ៣ ដល់ ៧ របស់ហ្វីលីពីន បានលើកយកមកដោះស្រាយនៅសមុទ្រចិនខាងត្បូង ទាក់ទងទៅនឹង រចនាសម្ព័ន្ធសមុទ្រនៅតំបន់ Scarborough សម្រេចថាតើវាជាដីដុះ ជាថ្ម ឬ ជាកោះ ហើយសមនឹងទទួលបានសិទ្ធិដែនសមុទ្រ ឬទេ។ ដីដុះ ដូចដែលបានណែនាំដោយឈ្មោះរបស់វា លេចឡើងតែក្នុងអំឡុងពេលទឹកទាបប៉ុណ្ណោះ។ វាមិនមានសិទ្ធិតាមសមុទ្រ និងមិនអាចកាន់កាប់ជាដែនអធិបតេយ្យបានទេ។ ថ្មមួយ ទោះបីជាអាចមើលឃើញក្នុងកំឡុង

[49] Matsuzawa, M. (2019, March 21). How The Hague Court ruled on the Philippines′s 15 arguments<https://www.philstar.com/news-commentary/2016/07/13/1602470/how-hague-court-ruled-philippiness-15-arguments>

ពេទឹកឡើងខ្ពស់ក៏ដោយ ក៏មិនអាចរក្សាលំនៅឋាន ឬជីវិតសេដ្ឋកិច្ចបានដែរ។ វាត្រូវបានអនុញ្ញាតត្រឹមតែសមុទ្រទឹកដី ១២ ណូទីខលម៉ាយល៍ (Nautical Mile) និងមិនអាចកាន់កាប់នៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ (EEZ)។[50]

ទន្ទឹមនឹងនោះកោះមួយអាចមានសិទ្ធិទទួលបានដែនអធិបតេយ្យនៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ (EEZ) បានត្រឹមចម្ងាយ ២០០ ណូទីខលម៉ាយល៍ (Nautical Mile) ប៉ុណ្ណោះ[51]។ រដ្ឋដែលជាម្ចាស់កោះនេះមានសិទ្ធិតែមួយគត់ក្នុងការរុករក និងទាញយកធនធានធម្មជាតិ ដូចជា ប្រេង ឧស្ម័ន និងរ៉ែ និងធនធានជីវចម្រុះនៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ (EEZ) របស់ខ្លួន ខណៈដែលរដ្ឋផ្សេងទៀតនៅតែអាចរីករាយនឹងសេរីភាពនៃការធ្វើនាវាចរណ៍ និងជើងហោះហើរ។ [52]តុលាការបានសម្រេចថា រចនាសម្ព័ន្ធសមុទ្រនៅតំបន់ Scarborough គឺត្រូវចាត់ទុកជាថ្ម ដូច្នេះហើយ វាមិនទទួលបានសិទ្ធិទទួលបានតំបន់សេដ្ឋកិច្ចផ្តាច់មុខទេ។ ចំពោះថ្មប៉ប្រះទឹក Mischief រចនាសម្ព័ន្ធសមុទ្រតំបន់ Thomas ទី២ និង ថ្មប៉ប្រះទឹក Subi តុលាការសម្រេចថា ទាំងបីនេះគឺជា ដីដុះ (Mischief Reef, Second Thomas shoal, and Subi Reef are Low-tide Elevations) ។ មិនត្រឹមតែប៉ុណ្ណោះ តុលាការ បានសម្រេចថា ថ្មប៉ប្រះទឹក Mischief និង រចនាសម្ព័ន្ធសមុទ្រនៅតំបន់ Thomas ទី២ គឺជាផ្នែករបស់តំបន់សេដ្ឋកិច្ចផ្តាច់មុខ (EEZ) និង ជាជាយទ្វីបរបស់ប្រទេសហ្វីលីពីន ដែលវាស្ថិតនៅក្នុងចន្លោះប្រហែល ២០០ ណូទីខលម៉ាយល៍ (Nautical Mile) ពីឆ្នេរហ្វីលីពីន គឺកោះ Palawan ។ តុលាការក៏ មិនយល់ស្របនឹង ហ្វីលីពីន ត្រង់ចំណុច ហ្វីលីពីន បកស្រាយថា ថ្មប៉ប្រះទឹក Gaven និង ថ្មប៉ប្រះទឹក McKennan ដែលក្នុងនោះក៏រាប់បញ្ចូល ថ្មប៉ប្រះទឹក Hughes ជាមួយគ្នាថាជា ថ្ម ដែលកើតចេញពីធម្មជាតិនៅតំបន់កោះ ហើយវានៅលើទឹកនៅពេលទឹកឡើង។ រីឯ ថ្មប៉ប្រះទឹកJohnson ថ្មប៉ប្រះទឹក Cuarteron និង ថ្មប៉ប្រះទឹក Fiery Cross តុលាការបានយល់ស្រប ថាជាថ្ម។ លើសពីនេះទៅទៀត ចិនបានឈ្លានពានដែនអធិបតេយ្យហ្វីលីពីនដោយខុសច្បាប់ និងរំលោភសិទ្ធិនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស និង ជាយទ្វីបរបស់ ហ្វីលីពីន។ នៅក្នុងនោះមានថ្មប៉ប្រះទឹក Mischief រចនាសម្ព័ន្ធសមុទ្រតំបន់ Thomas ទី២ និង ច្រាំង Reed ដែលស្ថិតនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស (EEZ) របស់ហ្វីលីពីន ដែលបានរកឃើញថា ទីក្រុងប៉េកាំង បានបំពានសិទ្ធិអធិបតេយ្យ របស់ទីក្រុងម៉ានីល ដោយបានចូលរុករកប្រេងរបស់ហ្វីលីពីន ហាមឃាត់កប៉ាល់ហ្វីលីពីនមិនឲ្យនេសាទ និងការសាងសង់កោះសិប្បនិម្មិតដោយគ្មានការអនុញ្ញាត។ សាលាក្តីបានបញ្ជាក់ថាប្រទេសចិនបានបង្ហាញទង្វើមិនត្រឹមត្រូវក្នុងសិទ្ធិជាដែនអធិបតេយ្យរបស់ហ្វីលីពីន ទាក់ទងទៅនឹងវិស័យជលផលដែលនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស (EEZ)។ ទីក្រុងប៉េកាំងបានបានបំពានលើកាតព្វកិច្ចដែលមានក្នុងមាត្រា ៥៨ នៃអនុញ្ញាសហប្រជាជាតិស្តីពីនីតិសមុទ្រ

---

[50] Article 03, UNCLOS

[51] Article 57, UNCLOS

[52] Article 56, UNCLOS

(UNCLOS) ដែលគ្របដណ្តប់សិទ្ធិ និងកាតព្វកិច្ចផ្សេងទៀតនៅក្នុង តំបន់សេដ្ឋកិច្ចពិសេស (EEZ) នៅពេលដែលហ្វីលីពីនបានបរាជ័យក្នុងការរារាំងនាវាប្រទេសចិនក្នុងការនេសាទនៅ ថ្មប៉ប្រះទឹក Mischief និង រចនាសម្ព័ន្ធសមុទ្រតំបន់ Thomas ទី២ កាលពីខែឧសភា ឆ្នាំ២០១៣។ តុលាការក៏បានសម្រេចផងដែរថា ចំពោះអ្នកនេសាទរបស់ ហ្វីលីពីន ចិន និង ប្រទេសផ្សេងទៀត អាចនេសាទនៅ រចនាសម្ព័ន្ធសមុទ្រតំបន់ Scarborough បាន និង មានសិទ្ធិនេសាទបែបប្រពៃណីនៅក្នុងតំបន់នោះ។ ទោះជាយ៉ាងណា គេបានរកឃើញថា ប្រទេសចិនមិនបានគោរពសិទ្ធិនេសាទបែបប្រពៃណី ដោយបានរារាំង អ្នកនេសាទហ្វីលីពីន មិនឲ្យចូលទៅ រចនាសម្ព័ន្ធតំបន់នោះ។ តុលាការក៏បានបញ្ជាក់ថា វានិងឈានដល់ចំណុចចុងក្រោយ ប្រសិនបើហ្វីលីពីន ការពារមិនឲ្យអ្នកនេសាទចិនចូលក្នុងរចនាសម្ព័ន្ធនេះបាន។ លើសពីនេះទៅទៀត តុលាការបានរកឃើញថា ចិនបានបំពានលើមាត្រា ១៩២[53] និង ១៩៤[54] កថាខណ្ឌទី៥ នៃអនុសញ្ញាសហប្រជាជាតិស្តីពីនីតិសមុទ្រ (UNCLOS) ដោយមិនបានរារាំងនាវានេសាទរបស់ប្រទេសចិនពីការចូលរួមក្នុងសកម្មភាពប្រមូលផលដែលបង្កគ្រោះថ្នាក់នៃ អណ្តើកផ្កាថ្ម និងក្តាមយក្ស នៅជាច្រើនកន្លែងក្នុងសមុទ្រចិនខាងត្បូងនៅ រចនាសម្ព័ន្ធសមុទ្រតំបន់ Scarborough រចនាសម្ព័ន្ធសមុទ្រតំបន់ Thomas ទី២ និងលក្ខណៈពិសេសផ្សេងទៀតនៅប្រជុំកោះ Spratly ។ ទីក្រុងប៉េកាំងបានបំពានលើមាត្រា ១៩២ មាត្រា១៩៤ កថាខណ្ឌទី១ និង កថាខណ្ឌទី៥ មាត្រា១៩៧ មាត្រា ១២៣ និងមាត្រា ២០៦ នៃអនុសញ្ញាសហប្រជាជាតិស្តីពីនីតិសមុទ្រ (UNCLOS) ដោយសកម្មភាពបង្កើតកោះសិប្បនិម្មិត នៅតំបន់ ថ្មប៉ប្រះទឹក Caurteron ថ្មប៉ប្រះទឹក Fiery Cross ថ្មប៉ប្រះទឹក Gaven ថ្មប៉ប្រះទឹក Johnson ថ្មប៉ប្រះទឹក Hughes ថ្មប៉ប្រះទឹក Rubi និងថ្មប៉ប្រះទឹក Mischief ។

## ផ្នែកទី២៖ យន្តការនាពេលកន្លងមក

ក្នុងស្មារតីចង់បញ្ចប់ជម្លោះគេសង្កេតឃើញថាគូភាគីបានប្រើប្រាស់យន្តការ២ នាពេលកន្លងទៅដើម្បីព្យាមរកច្រកចេញ ពោលគឺយន្តការចរចារ (Negotiaton) និងយន្តការច្បាប់ផងដែរ (Legal means of dispute settlement)។ ជាក់ស្តែងការសម្រេចបាននូវសេចក្តីថ្លែងការណ៍ភាគីសមុទ្រចិនខាងត្បូង DOC និងសេចក្តីសម្រេចរបស់តុលាការមជ្ឈត្តការពិសេសតាមឧបសម្ព័ន្ធ៧ នៃអនុសញ្ញានីតិសមុទ្រ (Tribunal Decision) គឺជាលទ្ធផលដែលស្តែងចេញពីយន្តការទាំងនោះ។

### កថាខណ្ឌទី១៖ យន្តការចរចារការទូត

មធ្យោបាយចរចាការទូតជាមធ្យោបាយដោះស្រាយជម្លោះដោយសន្តិវិធីមួយ ដែលពេញនិយមក្នុងការដោះស្រាយជម្លោះ ឬអរិភាពរវាងរដ្ឋហើយស្របតាមស្មារតីនៃមាត្រា២នៃធម្មនុញ្ញអង្គការសហប្រជាជាតិស្តីពី

[53] Article 192, UNCLOS

[54] Article 194, section 5, UNCLOS

គោលការណ៍ដោះស្រាយជម្លោះបែបសន្តិនិយម (Peaceful disputes settlement) ដែលប្រទេសចិន និង ហ្វីលីពីនផងជាសមាជិក[55]។ ជាពិសេសក្នុងខណៈដែលប្រទេសចិន បានប្រកាសជាផ្លូវការតាមរយៈសេចក្តីថ្លែងការណ៍មួយរបស់ក្រសួងការបរទេសចិនក្នុងខែកក្កដា ឆ្នាំ២០១៦ ដែលមានខ្លឹមសារបដិសេដមិនទទួលយក និងមិនទទួលចស្គាល់យុត្តាធិការនៃតុលាការមជ្ឈត្តការអន្តរជាតិទៀតនោះ (Neither accept nor recognize)[56] មធ្យោបាយការទូតជាមធ្យោបាយចម្បងមួយដែលអាចនឹងជាស្ពានចម្លងឆ្ពោះទៅរកការសម្រេចបានខ្លឹមសារដោះស្រាយជម្លោះរួមមួយរបស់ភាគីទាំងពីរ។

ប្រសិទ្ធិភាពនៃយន្តការនេះក៏បានជួយជម្រុញឱ្យគូភាគីទាំងពីរបានចូលអង្គុយតុចរចានិងសម្រេចបានលទ្ធផលជាដុំកំភួនផងដែរនាពេលកន្លងមក។ ជាក់ស្តែងតាមរយៈការផ្តោះប្តូរការចរចា និងពាក្យសម្តីការទូតចាប់តាំងពីកំឡុងទសវត្សរ៍៧០ ជាទីដែលហ្វីលីពីនចាប់ផ្តើមមានសកម្មភាពក្នុងសមុទ្រចិនខាងត្បូងមក[57] ភាគីទាំងពីបានសម្រេចទៅដល់ការព្រមព្រៀងគ្នាជាលើកដំបូងក្នុងរូបភាពជាសេចក្តីថ្លែងការណ៍រួមក្នុងខែសីហា ឆ្នាំ១៩៩៥ ដែលមានខ្លឹមសារឯកភាពគ្នាក្នុងការប្រកាន់យកការដោះស្រាយជម្លោះដោយសន្តិវិធី និងកិច្ចសហប្រតិបត្តិការ និងការពិភាក្សាតាមរយៈការប្រកាន់យកឱ្យបាននូវគោលការណ៍សមភាពរវាងរដ្ឋឯករាជ្យ និងការគោរពគ្នាទៅវិញទៅមក *"disputes shall be settled in a peaceful and friendly manner through consultations on the basis of equality and mutual respect"*[58]។

ការវិវត្តបន្ទាប់មកទៀត ពោលក្នុងចន្លោះឆ្នាំ ១៩៩៩ និងឆ្នាំ ២០០០ ប្រទេសទាំងពីរបានបន្តកិច្ចចរចា និងសកម្មភាពទ្វេភាគីផ្សេងទៀតជាក់ស្តែង ការរៀបចំឱ្យមានកិច្ចប្រជុំរវាងក្រុមបច្ចេកទេសដែលគោលដៅសំខាន់គឺសម្រេចឱ្យបានការបង្កើតវប្បធម៌សន្ទនា និងការពិភាក្សានានាដើម្បីជម្រុញការវិវត្តទៅមុខនៃកិច្ចខិតខំប្រឹងប្រែងស្វែងរកដំណោះស្រាយសមស្របមួយ។ ក្នុងខែវិច្ឆិកា ឆ្នាំ២០០០ សេចក្តីថ្លែងការណ៍រួមរវាងចិន និងហ្វីលីពីនស្តីពីក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការណ៍ទ្វេភាគីបានលេចរូបរាងឡើង ដោយក្នុងខ្លឹមសារកថាខ័ណ្ឌទី៩ នៃសេចក្តីថ្លែងការណ៍រួមនោះភាគីទាំងពីរបានលើកឡើងពីការប្តេជ្ញារៀងខ្លួន ក្នុងការលើកកំពស់ការដោះស្រាយជម្លោះក្នុង

---

[55] Article 2, section 2, UN Charter

[56] Statement of the Ministry of Foreign Affairs of the People's Republic of China on the Award of 12 July 2016 https://www.fmprc.gov.cn/eng/wjdt_665385/2649_665393/201607/t20160712_679470.html

[57] 1976 Philippines Discovers Oil Field https://www.cfr.org/timeline/chinas-maritime-disputes

[58] Statement of the Ministry of Foreign Affairs of the People's Republic of China on Settling Disputes Between China and the Philippines in the South China Sea Through Bilateral Negotiation https://www.fmprc.gov.cn/eng/wjdt_665385/2649_665393/201606/t20160608_679464.html

សមុទ្រចិនខាងត្បូងនេះដោយ សន្តិវិធីដែលប្រកាន់យកទាំងកិច្ចចរចាទ្វេភាគី និងគោលការណ៍ច្បាប់អន្តរជាតិដទៃទៀត ក្នុងនោះរួមបញ្ចូលទាំងអនុសញ្ញាសហប្រជាជាតិស្តីពីនីតិសមុទ្រឆ្នាំ១៩៨២ ផងដែរ[59]។

ទោះបីស្ថានភាពពេលនោះហាក់មានវឌ្ឍនភាពក្នុងរូបភាពហាក់មានភាពវិជ្ជមានក្តី ក៏ជម្លោះនេះជាជម្លោះដែលមានលក្ខណៈស្មុគស្មាញដដែល។ ប្រការនេះបាននាំឱ្យមានការចាប់អារម្មណ៍ពីសំណាក់សហគមន៍អន្តរជាតិ ពិសេសប្រទេសដែលស្ថិតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ដែលបានយល់ឃើញពីលទ្ធភាពនៃការវិវត្តជាអវិជ្ជមាននៃជម្លោះនេះ ដ្បិតមានការជាប់ពាក់ព័ន្ធនឹងរដ្ឋដទៃទៀតជាគូភាគីក្រៅពីចិន និងហ្វីលីពីន ហើយដែលអាចនឹងបង្ករភាពអសន្តិសុខដល់តំបន់ទាំងមូលផងនោះ អង្គការតំបន់មួយពោលគឺសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ហៅកាត់ថាអាស៊ាន (Association of Southeast Asian Nations - ASEAN) ដែលមានគូភាគីនៃជម្លោះជាសមាជិកដែរនោះត្រូវបានគេលើកជាវេទិការការទូតសម្រាប់ដោះដូរយបល់ និងពិភាក្សាចរចាស្វែងរកដំណោះស្រាយរវាងភាគីជម្លោះ ក្នុងនោះរាប់បញ្ចូលទាំងចិន និងហ្វីលីពីនផងដែរ។ សមិទ្ធផលថ្មីមួយទៀតបានលេចឡើងពីវេទិការការទូតនេះនោះគឺ សេចក្តីថ្លែងការណ៍រួមស្តីពីកិច្ចប្រតិបត្តិរបស់ភាគីក្នុងជម្លោះសមុទ្រចិនខាងត្បូងហៅកាត់ថា DOC (Declaration on The Conduct of Parties in The South China Sea – DOC) ដែលបានព្រមព្រៀងអនុម័តជាផ្លូវការណ៍ដោយរដ្ឋមន្ត្រីការបរទេសអាស៊ាន និងអតីតអនុរដ្ឋមន្ត្រីការបរទេសចិនលោក Wang Yi ក្នុងថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០០២ ក្នុងកិច្ចប្រជុំកំពូលអាស៊ានលើកទី៨ នាទីក្រុងភ្នំពេញប្រទេសកម្ពុជា។[60]

សេចក្តីប្រកាសរួមនេះ ជាឧបករណ៍គ្រឹះពហុភាគីដំបូងនៃភាគីជម្លោះសម្រាប់ជាមូលដ្ឋានដោះស្រាយជម្លោះនេះចាប់តាំងពីវាផ្ទុះឡើងមក។ កម្មវត្ថុចម្បងមួយចំនួននៃសេចក្តីប្រកាសរួមនេះមានជាអាទិ៍ ជាឯកសារបង្គោលសម្រាប់ការស្វែងរកដំណោះស្រាយនៃជម្លោះនៃអធិបតេយ្យដែនដី និងការកំណត់ព្រំដែនសមុទ្រក្នុងតំបន់ជម្លោះ ដែលវាបានចែងដាក់ចេញនៅគោលការណ៍គ្រឹះមួយចំនួនតួយ៉ាង ការធានាបាននូវសេរីភាពនាវាចរណ៍ និងការហោះហើរអន្តរជាតិ (Freedom of Navigation in and Overflight) ក្នុងសមុទ្រចិនខាងត្បូងហាមឃាត់ការបង្កអរិភាព និងធ្វើសកម្មភាពផ្សេងៗដែលអាចធ្វើឱ្យភាពតានតឹងនៃជម្លោះកើនឡើងដែលអាចជះឥទ្ធិពលដល់សន្តិសុខ និងស្ថិរភាពតំបន់ ការប្រកាន់យកយន្តការដោះស្រាយជម្លោះដោយសន្តិវិធី និងគោរពតាមគោលការណ៍ច្បាប់អន្តរជាតិ រួមទាំងអនុសញ្ញាសហប្រជាជាតិស្តីពីនីតិសមុទ្រ ១៩៨២ និងគោលកាណ៍គ្រឹះដទៃ

59 Joint Statement Between China and the Philippines on the Framework of Bilateral Cooperation in the Twenty-First Century https://www.fmprc.gov.cn/eng/wjdt_665385/2649_665393/200011/t20001115_678991.html

60 Declaration on The Conduct of Parties in The South China Sea https://asean.org/declaration-on-the-conduct-of-parties-in-the-south-china-sea-2/

ទៀត។[61] ដ្បិតថាសេចក្តីថ្លែងការណ៍រួមនេះជាសញ្ញានៃភាពវិជ្ជមានដ៏វិសេសមួយ និងជាមូលដ្ឋានគ្រឹះក្នុងការបោះជំហានទៅរកដំណោះស្រាយនៃជម្លោះក៏ដោយ ក៏សេចក្តីថ្លែងការរួមនេះពុំមានចរិតជាឧបករណ៍ច្បាប់ (Legal Instrument) ដែលមានអនុភាពគតិយុត្តចាប់បង្ខំឡើយ ពោលគឺការអនុវត្តទៅបាននូសេចក្តីថ្លែងការនេះអាស្រ័យទាំងស្រុងទៅលើឆន្ទៈរបស់គូភាគី។[62] ទោះបីជាបែបនេះក៏ដោយក៏សេចក្តីថ្លែងការណ៍រួមនេះជាឯកសារដ៏សំខាន់មួយផងដែរព្រោះវាបានបង្កលក្ខណៈ និងបរិយាកាសសមរម្យមួយសម្រាប់ការចរចាស្វែងរកដំណោះស្រាយតាមរយៈការដាក់ចេញនូវគោលការណ៍បែបសន្តិនិយមខាងលើ។ អ្វីដែលគួរឱ្យកត់សម្គាល់ទៀតនោះគឺត្រង់កថាខណ្ឌទី១០ ដែលជាកថាខណ្ឌចុងក្រោយនៃ DOC នេះបានលើកឡើងពីគំនិតផ្តួចផ្តើម និងលទ្ធភាពរបស់គូភាគីក្នុងការអនុម័តនូវក្រមប្រតិបត្តិ (Code of Conduct) ដែលអាចនឹងមានចរិត និងអនុភាពគតិយុត្តបែបចាប់បង្ខំ[63] ប្រសិនបើប្រការនេះទៅរួចនោះគូភាគីនឹងត្រូវជាប់ជាកាតព្វកិច្ចក្នុងការអនុវត្តនូវលក្ខខណ្ឌដែលបានកំណត់។ យ៉ាងណាមិញទោះបីជាសង្កេតឃើញមានគំនិតផ្តួចផ្តើមបែបនេះក៏ដោយ ក៏កិច្ចចរចាដែលឈានទៅដល់ការបង្កើតក្រមប្រតិបត្តិនេះតែងទទួលភាពបរាជ័យម្តងជាពីរដងចដ្បិតផលប្រយោជន៍របស់គូភាគីជម្លោះតែងជារនាំងនៃការឈានទៅរកការបង្កើតឡើងឱ្យចេញជារូបរាងនូវឯកសារនេះ ហេតុប្រធានបទនៃការបង្កើត COC នេះបានក្លាយជាដំឡូងក្តៅ (Hot Potato) សម្រាប់ប្រទេសជាម្ចាស់ផ្ទះនៃកិច្ចប្រជុំអាស៊ានដែលជារឿយៗត្រូវក្រពុលមុខដោយសារតែភាពស្មុគស្មាញ និងរឹងរុះរបស់ភាគីជម្លោះ។

យ៉ាងណាមិញក្រៅតែពីយន្តការចរចាការទូតទាំងនេះ ក៏នៅមានយន្តការនិងវិធីសាស្ត្រផ្សេងទៀត រួមទាំងយន្តការផ្លូវច្បាប់ផង ដែលគូភាគីអាចប្រកាន់យកមកស្វែងរកដំណោះស្រាយ។

### កថាខណ្ឌទី២៖ យន្តការច្បាប់

ក្រៅតែពីកិច្ចចរចាការទូតជាលក្ខណៈទ្វេភាគី និងពហុភាគីផងនោះ ភាគីក្នុងជម្លោះសមុទ្រចិនខាងត្បូងក៏ធ្លាប់បានប្រើប្រាស់យន្តការច្បាប់ដើម្បីមកដោះស្រាយវិបត្តិនេះផងដែរ ប៉ុន្តែហាក់ពុំទទួលបានជោគជ័យនោះឡើយ។ ផ្តើមចេញពីបណ្តឹងឯកតោភាគី ហ្វីលីពីនបានប្រើប្រាស់យន្តការច្បាប់ដែលមានចែងក្នុងឧបសម្ព័ន្ធ៧ នៃអនុសញ្ញាសហប្រជាជាតិស្តីពីនីតិសមុទ្រ ក្នុងការបង្កើតតុលាការមជ្ឈត្តការពិសេសមួយដើម្បីដោះស្រាយជម្លោះដ៏ស្មុគស្មាញមួយនេះ។

[61] Declaration on The Conduct of Parties in The South China Sea Sea https://asean.org/declaration-on-the-conduct-of-parties-in-the-south-china-sea-2/

[62] Thao, Nguyen. (2003). The 2002 Declaration on the Conduct of Parties in the South China Sea: A Note. Ocean Development and International Law - OCEAN DEV INT LAW. 34. 279-285. p 281

[63] Liu, F. (2016). *South China Sea Lawfare: Legal Perspectives and International Responses to the Philippines v. China Arbitration Case* (J. Spangler, Ed.).

### ២.១ ការប្រើប្រាស់តុលាការមជ្ឈត្តការពិសេសក្នុងក្របខ័ណ្ឌនៃឧបសម្ព័ន្ធ៧ នៃអនុសញ្ញាសហប្រជាជាតិស្តីពីនីតិសមុទ្រ ( Arbitral Tribunal Constituted in Accordance with Annex VII )

ក្នុងបញ្ញត្តិនៃមាត្រា ២៨៧ នៃអនុសញ្ញាស្តីពីនីតិសមុទ្រ UNCLOS ក្រៅតែពីបានចែងពីជម្រើសមួយចំនួនដែលគូភាគីអាចជ្រើសរើសយកមកជាយន្តការសម្រាប់បម្រើតម្រូវការរបស់ខ្លួនហើយនោះ វាក៏បានចែងផងដែរនូវយុត្តាធិការ ឬយន្តការចាប់បង្ខំមួយពោលគឺតាមរយៈការប្រើប្រាស់តុលាការមជ្ឈត្តការពិសេសតាមឧបសម្ព័ន្ធ៧[64] នៃអនុសញ្ញាឆ្នាំ១៩៨២ នេះ។ យន្តការនេះជាយន្តការចុងក្រោយបំផុតមួយដែលកម្រនឹងឃើញគេប្រើប្រាស់ ដោយលុះត្រាណាតែជម្លោះ ឬបញ្ហាដែលកំពុងកើតឡើងនោះពុំអាចស្វែងរកដំណោះស្រាយណាមួយផ្សេងបានទើបគេពិចារណាជ្រើសរើសយកមធ្យោបាយនេះ ដើម្បីដោះស្រាយ។ តុលាការនេះក៏ត្រូវបានគេរិះគន់ជារឿយៗផងដែរដោយសារតែបុគ្គលិកលក្ខណៈបែបចាប់បង្ខំរបស់វា ហើយបូករួមទាំងករណីជម្លោះរបស់ចិន និងហ្វីលីពីនផង តុលាការមជ្ឈត្តការពិសេសនេះបានសម្រេចលើករណីជម្លោះសរុបចំនួន១៤ករណីហើយ។[65] ដែលក្នុងនោះមួយចំនួនរួមមាន៖

1. រឿងក្តីរោងចក្រ MOX (អៀកឡង់ដ៍ ទល់នឹងចក្រភពអង្គគ្លេស) ក្នុងឆ្នាំ២០០១ និងបិទបញ្ចប់ក្នុងឆ្នាំ២០០៨
2. រឿងក្តីរបស់ម៉ាឡេស៊ី ទល់នឹងសិង្ហបុរី ក្នុងឆ្នាំ២០០៣ និងបិទបញ្ចប់ក្នុងឆ្នាំ២០០៥
3. រឿងក្តីព្រំដែនឆ្នេរ Bengal (បង់ក្លាដេស ទល់នឹងឥណ្ឌា) ក្នុងឆ្នាំ២០០៩ និងបិទបញ្ចប់ក្នុងឆ្នាំ២០១៤
4. រឿងក្តីរវាងសាធារណរដ្ឋប្រជាមានិតចិន និងសារធារណរដ្ឋហ្វីលីពីន ក្នុងវិវាទសមុទ្រចិនខាងត្បូងក្នុងឆ្នាំ២០១៣ និងបញ្ចប់ក្នុងឆ្នាំ ២០១៦។

ក្រៅតែពីរឿងក្តីដែលបានលើកឡើងខាងលើ ក៏នៅមានរឿងក្តីដទៃទៀតដែលកំពុងបន្តនីតិវិធី និងមួយចំនួនបានបិទបញ្ចប់ផងដែរ។

ចំពោះករណីជម្លោះសមុទ្រចិនខាងត្បូងរវាងចិន និងហ្វីលីពីននេះវិញ នីតិវិធីចាប់បង្ខំនៃតុលាការមជ្ឈត្តការពិសេសក្នុងឧបសម្ព័ន្ធនេះគឺត្រូវបានលើកយកមកអនុវត្ត ដែលស្តែងឡើងតាមរយៈបណ្តឹងជាឯកតោភាគីរបស់ភាគីជម្លោះណាមួយ ដ្បិតបើយើងពិនិត្យទៅលើអនុសញ្ញាសហប្រជាជាតិស្តីពីនីតិសមុទ្រត្រង់បញ្ញត្តិនៃមាត្រា២៨៧ កថាខណ្ឌ៣ *(...រដ្ឋភាគីណា ដែលជាភាគីនៅក្នុងជម្លោះដែលមិនស្ថិតក្រោមសេចក្តីប្រកាសដែលចូលជាធរមានណាមួយ នោះនឹងត្រូវបានចាត់ទុកថាទទួលយកនូវមជ្ឈត្តការដូចមានចែងក្នុងឧបសម្ព័ន្ធ៧។)* និង

---

[64] Article 287 section (C), UNCLOS

[65] PCA-UNCLOS Annex VII cases arbitrated under the auspices of the PCA. https://pca-cpa.org/en/services/arbitration-services/unclos/

កថាខណ្ឌ៥ (*…ប្រសិនបើភាគីក្នុងជម្លោះណាមួយ មិនទទួលយកនូវនីតិវិធីដោះស្រាយជម្លោះរួម ភាគីនោះអាចធ្វើបណ្ដឹងឯកតោភាគីទៅកាន់មជ្ឈត្តការដូចមានចែងក្នុងឧបសម្ព័ន្ធ៧ លើកលែងតែភាគីទាំងអស់យល់ព្រម។)*[66] ។ ក្រៅពីនេះលក្ខខណ្ឌចាំបាច់មួយចំនួនទៀតក៏ត្រូវបានបំពេញផងដែរក្នុងករណីនេះ៖

1. ភាគីទាំង២ ពោលគឺទាំងប្រទេសចិន និងប្រទេសហ្វីលីពីនសុទ្ធតែជាភាគីនៃអនុសញ្ញាសហប្រជាជាតិស្ដីពីនីតិសមុទ្រ (ចិនបានផ្ដល់សច្ចាប័ន ឬ Ratification នៅថ្ងៃទី០៧ ខែមិថុនា ឆ្នាំ១៩៩៦ និងហ្វីលីពីនបានផ្ដល់សច្ចាប័ននៅថ្ងៃទី០៨ ខែឧសភា ឆ្នាំ ១៩៨៤។[67]
2. នៅពេលផ្ដល់ និងរួមទាំងក្រោយពេលផ្ដល់សច្ចាប័ន ភាគីទាំង២សុទ្ធតែពុំបានចេញសេចក្ដីថ្លែងការណ៍ណាមួយដើម្បីជ្រើសរើសយន្តការ និងនីតិវិធីក្នុងការដោះស្រាយជម្លោះដែលខ្លួនពេញចិត្តតាមរយៈបញ្ញត្តិនៃមាត្រា២៨៧ កថាខណ្ឌ១ នៃអនុសញ្ញានោះឡើយ។[68]

ដូចនេះហើយទើបក្នុងចំណោមលទ្ធភាពមួយចំនួននៃយន្តការដោះស្រាយជម្លោះនេះ ហ្វីលីពីនបានលើកយកនូវយន្តការតុលាការមជ្ឈត្តការពិសេសនេះផងដែរ ពោលគឺហ្វីលីពីន តាមរយៈបណ្ដឹងឯកតោភាគីមួយដែលធ្វើឡើងក្នុងថ្ងៃទី២២ ខែមករា ឆ្នាំ២០១៣[69] បានស្នើបង្កើតតុលាការមជ្ឈត្តការពិសេសតាមឧបសម្ព័ន្ធ៧នៃអនុសញ្ញានីតិសមុទ្រ ប្រឆាំងនឹងចិន។ ជាការឆ្លើយតប ចិនតាមរយៈសេចក្ដីថ្លែងការណ៍បដិសេធមួយ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៣[70] នៅតែប្រកាន់ជំហរមិនទទួលស្គាល់យុត្តាធិការ និងមិនចូលបង្ហាញខ្លួនចំពោះមុខតុលាកានេះ យ៉ាងណាមិញតុលាការនេះបានរកឃើញថាខ្លួនមានសមត្ថភាពជំនុំជម្រះលើរឿងក្ដីនេះ និងបន្តនីតិវិធីរបស់ខ្លួនបន្តទៀត។

### ២.២ នីតិវិធីដែលបង្កើតនូវតុលាការមជ្ឈត្តការនៃឧបសម្ព័ន្ធ៧

យោងលើពាក្យបណ្ដឹងដែលហ្វីលីពីនបានដាក់ស្នើសុំបង្កើតនូវតុលាការខាងលើនេះ ហ្វីលីពីនបានសម្រេចដាក់សុំតែងតាំងចៅក្រមសញ្ជាតិអាល្លឺម៉ង់មួយរូបឈ្មោះ Rüdiger Wolfrum ដែលជាអតីតចៅក្រមនៅ

---

[66] Article 287, par. 3&5, UNCLOS

[67] Status of the United Nations Convention on the Law of the Sea, of the Agreement relating to the Implementation of Part XI of the Convention and of the Agreement for the Implementation of the Provisions of the Convention relating to the Conservation and Management of Straddling Fish Stocks and Highly Migratory Fish Stocks as at 27 June 2019 - status2019.pdf (un.org)

[68] UNCLOS, Declarations and Statements - Declarations or Statements upon UNCLOS ratification.pdf (marineregions.org)

[69] DFA: Notification and Statement of Claim On West Philippine Sea: Notification and Statement of Claim On West Philippine Sea | PDF (scribd.com)

[70] ARBITRATION 101: PHILIPPINES V. CHINA: Arbitration 101: Philippines v. China | Asia Maritime Transparency Initiative (csis.org)

តុលាការអន្តរជាតិនីតិសមុទ្រ។[71] ប៉ុន្តែអ្វីដែលគួរឱ្យចាប់អារម្មណ៍ត្រង់កន្លែងនេះគឺចិន ដែលជាភាគីម្ខាងទៀតនៃជម្លោះពុំបានអនុវត្តនូវសិទ្ធិតាមផ្លូវច្បាប់របស់ខ្លួន ក្នុងការជ្រើសរើសតែងតាំងចៅក្រមដែលមានសម្ថកិច្ចក្នុងការដោះស្រាយជម្លោះនៅសមុទ្រចិនខាងត្បូងនេះឡើយ ដែលត្រង់នេះវាបានចោទជាបញ្ហាមួយចំនួនឡើងទាក់ទិនទៅនឹងសមាសភាពនៃចៅក្រម ឬមជ្ឈតករនៅក្នុងដំណាក់កាលនៃនីតិវិធីក្នុងការបង្កើតតុលាការមជ្ឈតការនេះ ដ្បិតបើយោងទៅលើមាត្រា៣ នៃឧបសម្ព័ន្ធ៧ នៃអនុសញ្ញាសហប្រជាជាតិស្ដីពីនីតិសមុទ្រ UNCLOS បានចែងថា តុលាការមជ្ឈតការនេះបង្កើតឡើងដោយមានចៅក្រមសរុប ៥រូបក្នុងនោះ៖

- មាន១រូបត្រូវតែងតាំងដោយភាគីដើមបណ្ដឹង ឬភាគីដែលស្នើសុំបង្កើតតុលាការនេះ
- មាន១រូបទៀតត្រូវតែងតាំងដោយភាគីម្ខាងទៀតនៃជម្លោះ ក្នុងរយៈពេល៣០ថ្ងៃ បន្ទាប់ពីបានទទួលដំណឹងអំពីការស្នើសុំបង្កើតតុលការនេះ។
- ករណីដែលភាគីម្ខាងទៀតអាក់ខានក្នុងការអនុវត្តសិទ្ធ ដោយមិនបានតែងតាំងចៅក្រមក្នុងរយៈពេលកំណត់៣០ថ្ងៃ នោះតាមរយៈការស្នើសុំពីភាគីដែលស្នើបង្កើតតុលាការ ប្រធានតុលាការនីតិសមុទ្រ នឹងតែងតាំងចៅក្រមដែលនៅសេសសល់តាមការចាំបាច់។[72]

ត្រលប់មកកាន់ករណីយើងវិញឃើញថា ចិនបានអាក់ខានពុំបានតែងតាំងចៅក្រមនៅក្នុងដំណើរការនៃការបង្កើតតុលាការនេះឡើង ជាហេតុនាំឱ្យហ្វីលីពីនបានស្នើឱ្យប្រធានតុលាការនីតិសមុទ្រតែងតាំងចៅក្រមដែលនៅសេសល់ទាំងអស់បូករួមទាំងប្រធាននៃអង្គជំនុំជម្រះផងដែរ ហើយនាថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៣ តុលាការមជ្ឈត្តការពិសេសនេះ បានសម្រេចបន្តនីតិវិធីរបស់ខ្លួនតាមរយៈការអនុម័តវិធានមួយចំនួនរបស់ខ្លួនដោយនីតិវិធី និងសវនាការទាំងមូលបានធ្វើនៅទីក្រុងឡាអេប្រទេសអាល្លឺម៉ង់តាមរយៈជំនួយផ្នែករដ្ឋបាលដោយតុលាការមជ្ឈត្តការអចិន្ត្រៃយ៍ (PCA) ប៉ុន្តែត្រង់នេះគួររំលេចដែរថាតុលាការមជ្ឈត្តការអចិន្ត្រៃយ៍ ពុំមែនជាស្ថាប័នឬតួអង្គដែលមានយុត្តាធិការលើរឿងក្ដីសមុទ្រចិនខាងត្បូងនេះទេ ដោយអង្គការអន្តររដ្ឋាភិបាលមួយនេះគ្រាន់តែផ្ដល់នូវជំនួយផ្សេងៗផ្នែករដ្ឋបាលដល់ តុលាការមជ្ឈត្តការពិសេសប៉ុណ្ណោះដែលជាស្ថាប័នមានយុត្តាធិការដោះស្រាយលើរឿងក្ដីនេះ។[73] ក៏គួរបញ្ជាក់ផងដែរថាកាលនោះសមាសសភាពចៅក្រមទាំង៥រូបរួមមាន៖

1. លោក Thomas Mensah ជាប្រធាន សញ្ជាតិ ហ្កាណា
2. លោក Jean-Pierre Cot សញ្ជាតិ បារាំង

---

[71] Former Judge in South China Sea Arbitration Case Discusses New Challenges to Philippine Maritime Security. https://fsi.gov.ph/2022/01/04/former-judge-in-south-china-sea-arbitration-case-discusses-new-challenges-to-philippine-maritime-security/

[72] Article 3 in Annex XII, UNCLOS

[73] The PCA provides administrative support in international arbitrations: https://pca-cpa.org/en/services/arbitration-services/

3. លោក Stanislaw Pawlak សញ្ជាតិ ប៉ូឡូញ
4. លោក Alfred Soons សញ្ជាតិ ហូឡង់ដ៍
5. លោក Rüdiger Wolfrum សញ្ជាតិ អាល្លឺម៉ង់ (តែងតាំងដោយហ្វីលីពីន)។[74]

## ២.៣ គោលការណ៍អញ្ញត្រកម្មបឋមនៃអសមត្ថកិច្ចតុលាការ និងភាពមិនអាចទទួលយកបាននៃបណ្តឹង ( Preliminary Objection phase )

ជាគោលការណ៍នៅក្នុងនីតិវិធីដោះស្រាយទំនាស់អន្តរជាតិ មុននឹងឈានទៅដល់ការសម្រេច ឬចេញសាលដីកាលើអង្គសេចក្តី តុលាការអន្តរជាតិត្រូវរកឱ្យឃើញជាមុនសិនថាខ្លួនមានដែនយុត្តាធិការ និងសមត្ថកិច្ចដោះស្រាយពិតប្រកដលើរឿងក្តីនោះ ហើយជាភាគច្រើនភាគីដែលជាភាគីចុងបណ្តឹងជារឿយតែងតែបដិសេធជំទាស់នូវដែនយុត្តាធិការរបស់តុលាការតាមរយៈការលើកឡើងនូវវិធានអញ្ញត្រកម្មបឋម (Preliminary Objection) ស្តីពីអសមត្ថកិច្ចនៃតុលាការ និងភាពដែលមិនអាចទទួលយកបាននៃបណ្តឹង។ វិធានអញ្ញត្រកម្មបឋមនេះមានចែងក្នុងមាត្រា៧៩ នៃបទបញ្ជាផ្ទៃក្នុង (Rules of Court) នៃតុលាការយុត្តិធម៌អន្តរជាតិ ដោយមានសេចក្តីថាគូភាគីដែលលើកឡើងនូវវិធានអញ្ញត្រកម្មបឋម ត្រូវស្នើសុំជាលាយលក្ខណ៍ក្នុងអំឡុងពេល៣ខែបន្ទាប់ពីការដាក់ពាក្យ។[75] វិធានអញ្ញត្រកម្មបឋមនេះត្រូវគេប្រើប្រាស់ដោយភាគីជាចុងបណ្តឹងដើម្បីជំទាស់ ឬបដិសេធនូវសមត្ថកិច្ច ឬដែនយុត្តាធិការរបស់តុលាការ ឬដើម្បីលើកឡើងពីភាពមិនអាចទទួលយកបាននៃបណ្តឹង។ វាចែកចេញជាពីររួមមាន អញ្ញត្រកម្មបឋមស្តីពីអសមត្ថភាពនៃតុលាការ (Objection to Jurisdiction) ដែលជំទាស់នឹងដែនសមត្ថកិច្ច ឬយុត្តាធិការរបស់តុលាការ និងអញ្ញត្រកម្មបឋមស្តីពីភាពមិនអាចទទួលយកបាននៃបណ្តឹង (Objection to Admissibility) ដែលខុសពីអញ្ញត្រកម្មបឋមមុន វិធាននេះលើកឡើងដើម្បីជាមធ្យោបាយច្បាប់ជំទាស់ និងស្នើឱ្យតុលាការលើកចោលបណ្តឹងណាមួយដោយមូលហេតុវិការៈ ឬភាពមិនត្រឹមត្រូវនៃបណ្តឹងនោះ (បណ្តឹងដែលមិនបានបំពេញលក្ខខណ្ឌបឋមណាមួយដែលបានតម្រូវ)។ ជាទូទៅក្នុងវិវាទអន្តរជាតិអង្គជំនុំជម្រះដែលទទួលបន្ទុកលើរឿងក្តីនោះជាអ្នកសម្រេចខ្លួនឯងលើដែនសមត្ថកិច្ច ឬយុត្តាធិការរបស់ខ្លួនដោយផ្អែកលើគោលការមួយក្នុងច្បាប់ និងទំនៀមទម្លាប់អន្តរជាតិហៅថាគោលការ Competence-Competence។[76] ជាឧទាហរណ៍៖ មុននឹងឈានដល់ការសម្រេចក្តីលើរឿងក្តីវិវាទកម្ពុជា-ថៃ តុលាការយុត្តិធម៌

[74] NEW ARBITRATOR AND PRESIDENT APPOINTED IN THE ARBITRAL PROCEEDINGS INSTITUTED BY THE REPUBLIC OF THE PHILIPPINES AGAINST THE PEOPLE´S REPUBLIC OF CHINA: https://www.itlos.org/fileadmin/itlos/documents/press_releases_english/PR_197_E.pdf

[75] Article 79, Rules of Court - ICJ

[76] Competence-Competence doctrine មកពីពាក្យដើមជាភាសាអាល្លឺម៉ង់ Kompetenz-Kompetenz ដែលសំដៅលើគោលការមួយនៃច្បាប់អន្តរជាតិដែលតុលាការមជ្ឈត្តការមានយុត្តាធិការក្នុងការសម្រេចលើដែនយុត្តាធិការ និងសមត្ថកិច្ចរបស់ខ្លួនក្នុងជម្លោះ ឬវិវាទ

អន្តរជាតិ (ICJ) បានបដិសោធចោលនូវសំណើរអញ្ញត្រកម្មបឋមស្តីពីអសមត្ថភាពតុលាការដែលបានដាក់ជូនតុលាការក្នុងថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៦០[77] និងបានរកឃើញថាខ្លួនពិតជាមានយុត្តាធិការលើរឿងក្តីដែលកម្ពុជាដាក់ពាក្យជូននាថ្ងៃទី០៦ ខែតុលា ឆ្នាំ១៩៥៩ ។[78]

### ២.៣.១ ការជំទាស់ និងអំណះអំណាងរបស់ភាគីចិន

ត្រលប់មកមើលករណីជម្លោះរវាងចិន និងហ្វីលីពីនវិញ ក្នុងករណីដែលហ្វីលីពីនស្នើបង្កើតតុលាការមជ្ឈត្តការនេះ ភាគីចិនឯណោះនៅតែបន្តជំហររបស់ខ្លួនយ៉ាងម៉ឹងម៉ាត់ក្នុងការមិនចូលរួមដំណើរការនានានៃនីតិវិធីរបស់អង្គជំនុំជម្រះ ហើយតាមរយៈសេចក្តីថ្លែងការណ៍មួយរបស់ក្រសួងការបរទេសចិនដែលចេញផ្សាយជាសាធារណៈនាថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៤ រដ្ឋាភិបាលចិនក្រៅតែពីសង្កត់ធ្ងន់ថាខ្លួននឹងមិនទទួលស្គាល់ និងមិនចូលរួមកក្នុងនីតិវិធីដោះស្រាយជម្លោះតាមរយៈតុលាការមជ្ឈត្តការដែលស្នើបង្កើតដោយហ្វីលីពីន ប្រទេសនេះក៏បានប្រកាសមិនទទួលស្គាល់ និងបានលើកឡើងថាតុលាការនេះពុំមានយុត្តាធិការលើករណីជម្លោះរវាងខ្លួន និងហ្វីលីពីនឡើយ។ ក្នុងកថាខណ្ឌទី០៣ នៃសេចក្តីថ្លែងការណ៍ដដែលនោះភាគីចិនបានប្រកាសជំទាស់និង មិនទទួលស្គាល់ដែនយុត្តាធិការរបស់តុលាការដោយបានអះអាងលើ០៤ ចំណុចធំៗរួមមាន៖

- តបទៅនឹងកម្មវត្ថុចម្បងនៃការបង្កើតតុលការមជ្ឈត្តការនេះ គឺពាក់ព័ន្ធនឹងអធិបតេយ្យភាពដែនដីទៅលើរចនាសម្ព័ន្ធសមុទ្រមួយចំនួនក្នុងដែនទឹកនៃសមុទ្រចិនខាងត្បូង ដែលប្រការនេះវាហួសពីដែនសមត្ថកិច្ចនៃអនុសញ្ញានីតិសមុទ្រ និងមិនពាក់ព័ន្ធទៅលើការបកស្រាយ ឬការអនុវត្តបញ្ញត្តិនានានៃអនុសញ្ញានោះឡើយ។
- ភាគីចិន និងហ្វីលីពីនបានឯកភាពគ្នា តាមលក្ខណៈជាទ្វេភាគីផង និងអនុលោមតាមសេចក្តីថ្លែងការណ៍រួមស្តីពីកិច្ចប្រតិបត្តិរបស់ភាគីក្នុងជម្លោះសមុទ្រចិនខាងត្បូង (DOC) ផងថានឹងដោះស្រាយជម្លោះពាក់ព័ន្ធតាមរយៈលើការចរចាការទូត ហើយដោយការស្នើបង្កើតតុលាការមជ្ឈត្តការជាឯកតោភាគីនេះ ហ្វីលីពីនបានរំលោភលើកាតព្វកិច្ចរបស់ខ្លួនក្រោមច្បាប់អន្តរជាតិ។
- ទោះបីជាសន្មត់ថា តុលាការនេះរកឃើញថាកម្មវត្ថុចម្បងនៃរឿងក្តីពាក់ព័ន្ធនឹងការបកស្រាយ ឬការអនុវត្តបញ្ញត្តិនានានៃអនុសញ្ញានីតិសមុទ្រក៏ដោយ ក៏កម្មវត្ថុចម្បងនេះស្ថិតជាផ្នែកសំខាន់នៃការពន្លាតព្រំដែនសមុទ្ររវាងប្រទេសពីរ ដូចនេះតុលាការក៏នៅតែពុំមានយុត្តាធិការដោះស្រាយជម្លោះនេះឡើយ ដ្បិតវាត្រូវបានស្ថិតក្រោមខរក្សាសិទ្ធិអនុលោមតាមអនុសញ្ញានីតិសមុទ្រ ដែលចិនបានដាក់បញ្ចូលតាម

---

ណាមួយ។ យោង៖ Competence-Competence, para. 4; https://jusmundi.com/en/document/publication/en-competence-competence

[77] Preliminary Objections of the Government of Thailand; https://www.icj-cij.org/node/104467

[78] CASE CONCERNING THE TEMPLE OF PREAH VIHEAR: JUDGMENT OF 15 JUNE 1962; https://www.icj-cij.org/public/files/case-related/45/045-19620615-JUD-01-00-EN.pdf

សេចក្តីប្រកាសក្នុងឆ្នាំ២០០៦ ថាចិនមិនទទួលស្គាល់យុត្តាធិការ និងសម្ថកិច្ចតុលាការពាក់ព័ន្ធនឹងការកំណត់ព្រំដែនសមុទ្រ និងសិទ្ធិប្រវត្តិសាស្ត្រ (Maritime delimitation and historic titles) ទៅលើគ្រប់ករណីជម្លោះទាំងអស់។[79]

- ជាលទ្ធផល តុលាការមជ្ឈត្តការដែលបង្កើតឡើង មិនមានយុត្តាធិការលើរឿងក្តីបច្ចុប្បន្ននេះឡើយ ហើយផ្អែកលើគោលជំហរដែលបានលើកឡើង និងផ្អែលលើគោលការណ៍គុណធម៌នៃសេរីភាពរបស់រដ្ឋក្នុងការជ្រើសរើសគ្រប់វិធីសាស្ត្រដោះស្រាយជម្លោះដែលខ្លួនពេញចិត្ត ហើយការជំទាស់ និងការពហិការមិនចូលរួមរបស់ចិនក្នុងនីតិវិធីនៃតុលាការមជ្ឈត្តការនេះ ត្រូវបានគាំពារនិងស្របទៅតាមគោលការណ៍ច្បាប់អន្តរជាតិ។[80]

យ៉ាងណាមិញទោះបីជាយ៉ាងនេះក៏ដោយ ក៏អង្គជំនុំជម្រះនៃតុលាការមជ្ឈត្តការពិសេសសម្រេចចាត់យកសេចក្តីថ្លែងការណ៍នោះ ជាសារណាការពារខ្លួនរបស់ភាគីចិនទាក់ទឹននឹងអញ្ញត្រកម្មបឋមស្តីពីអសម្ថកិច្ចនៃតុលាការ និងភាពមិនអាចទទួលយកបាននៃបណ្តឹងព្រោះក្នុងនោះបានលើកឡើងពីមូលហេតុមួយចំនួនដែលភាគីចិនបានចាត់ទុកថាតុលាការមជ្ឈត្តការនេះពុំមានយុត្តាធិការលើរឿងក្តី។[81] បន្ទាប់មកអង្គជំនុំជម្រះបានសម្រេចបន្តនីតិវិធីបើកនូវការស្តាប់ហេតុផលផ្ទាល់មាត់ រួមទាំងសវនាការបឋម ដើម្បីពិនិត្យ និងសម្រេចលើដែនយុត្តាធិការ រួមទាំងភាពទទួលយកបាននៃបណ្តឹងរបស់ហ្វីលីពីន ហើយតុលាការមជ្ឈត្តការនេះបានចេញដីកាស្តីពីដែនយុត្តាធិការ និងភាពទទួលយកបាននៃបណ្តឹង (Award on Jurisdiction and Admissibility) លើរឿងក្តីរវាងចិន និងហ្វីលីពីនក្នុងថ្ងៃទី២៩ ខែតុលា ឆ្នាំ២០១៥។[82]

### ២.៣.២ ការជំទាស់ និងអំណះអំណាងរបស់ភាគីហ្វីលីពីន

យោងតាមដីកាស្តីពីយុត្តាធិការ និងភាពទទួលយកបាននៃបណ្តឹងរបស់តុលាការមជ្ឈត្តការពិសេសចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ២០១៥ បានបង្ហាញថានៅក្នុងបណ្តឹងរបស់ខ្លួន ភាគីហ្វីលីពីនបានទាមទារចំនួន១៥ ចំណុច[83] ដែលក្នុងនោះគោលដៅប្រទាក់ក្រឡាគ្នាសំខាន់មួយចំនួនដែលហ្វីលីពីនលើកឡើង និងទាមទាររួមមាន៖

[79] Declarations made by States Parties under article 298; https://www.itlos.org/en/main/jurisdiction/declarations-of-states-parties/declarations-made-by-states-parties-under-article-298/

[80] Position Paper of the Government of the People's Republic of China on the Matter of Jurisdiction in the South China Sea Arbitration Initiated by the Republic of the Philippines; https://www.fmprc.gov.cn/eng/wjdt_665385/2649_665393/201412/t20141207_679387.html

[81] The South China Sea Arbitration Award of 12 July 2016, para. 130 ; https://docs.pca-cpa.org/2016/07/PH-CN-20160712-Award.pdf

[82] The South China Sea Arbitration Award of 12 July 2016, para. 130; https://docs.pca-cpa.org/2016/07/PH-CN-20160712-Award.pdf

[83] AWARD ON JURISDICTION AND ADMISSIBILITY, para. 7; https://pcacases.com/web/sendAttach/2579

- ទីមួយៈ ហ្វីលីពីនស្នើសុំឱ្យតុលាការសម្រេចថាសិទ្ធិ និងកាតព្វកិច្ចរបស់គ្រប់ភាគីដែលពាក់ព័ន្ធទៅនឹងដែនទឹក បាតសមុទ្រ និងរចនាសម្ព័ន្ធសមុទ្រ នៅក្នុងលំហនៃមុទ្រចិនខាងត្បូងគឺស្ថិតក្រោមដែនអនុវត្តនៃអនុសញ្ញានីតិសមុទ្រ ហើយការទាមទាររបស់ចិនដែលផ្អែកលើសិទ្ធិប្រវត្តិសាស្ត្រ ដែលបានហ៊ុំព័ទ្ធនៅក្នុងអ្វីដែលចិនហៅថា "ខ្សែរបន្ទាត់ប្រាំបួនចំណុច" តាមរយៈផែនទីឆ្នាំ២០០៩ នោះគឺមិនស៊ីសង្វាក់គ្នា និងផ្ទុយទៅនឹងគោលការណ៍នៃអនុសញ្ញា រួមទាំងច្បាប់អន្តរជាតិនានាផ្សេងទៀត ដូចនេះមិនអាចយកជាការបាន។
- ទីពីរៈ ហ្វីលីពីនស្នើសុំការពិនិត្យ និងបកស្រាយរបបគតិយុត្តក្រោមក្របខណ្ឌអនុសញ្ញានីតិសមុទ្រថា តើរចនាសម្ព័ន្ធសមុទ្រផ្អែកខ្លះដែលគូភាគីទាំង២បានទាមទារ (ផ្អែកមួយចំនួននៃប្រជុំកោះ Spratly តំបន់ Scarborough ជាដើម) អាចត្រូវបានចាត់ទុកថាជាកោះ (Islands) ជាថ្មដុះ (Rocks) ជាតំបន់ដីដុះ (Low-tide elevations) ឬជាតំបន់ថ្មប៉ប្រះទឹក (Submerged banks) ដ្បិតប្រសិនបើរចនាសម្ព័ន្ធទាំងនោះត្រូវបានចាត់ទុកជា"កោះ" នោះតំបន់ទាំងនោះមានលទ្ធភាពអាចបង្កើតតំបន់សេដ្ឋកិច្ចពិសេស (EEZ) ផ្ទាល់ខ្លួន ឬអាចត្រូវបានភ្ជាប់ជាមួយខ្ពង់រាបបាតសមុទ្រដែលលាតសន្ធឹងបានរហូត ២០០ ណូទីខលម៉ាយល៍។ សរុបរួមកម្មវត្ថុត្រង់នេះគឺហ្វីលីពីន គ្រាន់តែស្នើសុំឱ្យតុលាការមជ្ឈត្តការពិសេសនេះបកស្រាយពីនិយមន័យ និងកំណត់របបគតិយុត្តនៃរចនាសម្ព័ន្ធសមុទ្រទាំងនោះប៉ុណ្ណោះ មិនមានអត្ថន័យពាក់ព័ន្ធនឹងអធិបតេយ្យលើរចនាសម្ព័ន្ធទាំងនោះដូចអ្វីដែលចិនបានលើកឡើងក្នុងសេចក្តីថ្លែងការណ៍របស់ខ្លួននោះឡើយ។
- ទីបីៈ ហ្វីលីពីនស្នើតុលាការនេះសម្រេចថា ចិនបានប្រព្រឹត្តិរំលោភលើបទបញ្ញត្តិនៃអនុសញ្ញាដោរារាំង និងជ្រៀតជ្រែកការអនុវត្តសិទ្ធិ សេរីភាព និងអធិបតេយ្យរបស់ហ្វីលីពីនដែលត្រូវបានការពារដោយអនុសញ្ញានោះតាមរយៈការសាងសង់សំណង់ និងសកម្មភាពនេសាទ ដែលប៉ះពាល់ដល់ជីវចម្រុះ រួមទាំងបរិស្ថានសមុទ្រ។[84]

## ២.៣.៣ យុត្តាធិការរបស់តុលាការមជ្ឈត្តការពិសេស ក្នុងរឿងក្តីចិន និងហ្វីលីពីន

ដីកាស្តីពីយុត្តាធិការ និងភាពទទួលយកបានៃបណ្តឹងបានប្រកាសចេញដោយតុលាការមជ្ឈត្តការពិសេស នាថ្ងៃ២៩ ខែតុលា ឆ្នាំ២០១៥ ក្រោយពីបានបន្តនីតិវិធីរបស់ខ្លួន និងឈានដល់ការបើកសវនាការបឋម ដើម្បីស្តាប់ហេតុផលផ្ទាល់មាត់ និងជាលាយលក្ខណ៍អក្សររបស់គូភាគីទាំងសងខាង បើទោះបីជាចិននៅតែជំទាស់ និងមិនចូលរួមក្នុងនីតិវិធីរបស់តុលាការមជ្ឈត្តការនេះក៏ដោយ។ ជាលទ្ធផល អង្គជំនុំជម្រះរបស់តុលាការមជ្ឈត្តការបានរកឃើញ និងសម្រេចថាខ្លួមានយុត្តាធិការសម្រេចក្នុងការសម្រេចទៅលើកម្មវត្ថុនៃជម្លោះចំនួន០៧ ក្នុងចំណោម១៥ចំណុចដែលបានស្នើ ចំណែកឯកម្មវត្ថុក្នុងជម្លោះដែលពាក់ព័ន្ធដល់ការសម្រេចដែនអធិបតេយ្យ

[84] AWARD ON JURISDICTION AND ADMISSIBILITY, para. 4, 5 & 6; https://pcacases.com/web/sendAttach/2579

និងការកំណត់ព្រំដែនបាតសមុទ្រ តុលាការនេះមិនមានយុត្តាធិការសម្រេចលើកម្មវត្ថុទាំងនោះឡើយ។[85] នៅក្នុងដីកា (Award) ដដែលនោះតុលាការបានសម្រេចលើបញ្ហាគតិយុត្តមួយចំនួន៖

- ចំណុចស្នើទី៣, ៤, ៦, ៧ របស់ហ្វីលីពីនដែលសុំឱ្យតុលាការបញ្ជាក់ពីឋានៈ លក្ខខន្តិៈ និងរបបគតិយុត្តរបស់រចនាសម្ព័ន្ធសមុទ្រមួយចំនួននៅប្រជុំកោះ Spratly តំបន់ Scarborough និងតំបន់ផ្សេងៗទៀតដែលពាក់ព័ន្ធថាជាកោះ ជាថ្មដុះ ជាតំបន់ដីដុះឬជាតំបន់ថ្មប៉ប្រះទឹកនោះមិនមែនជាជម្លោះលើការកំណត់ដែនអធិបតេយ្យលើរចនាសម្ព័ន្ធទាំងនោះឡើយ ហើយក៏មិនមែនជាជម្លោះពាក់ព័ន្ធនឹងការពន្លាតការកំណត់ព្រំដែនបាតសមុទ្រ (sea boundary delimitation) ដែលចិនបានធ្វើខរក្សាសិទ្ធិមិនចូលរួមនោះដែរ។ ដូច្នេះតុលាការមជ្ឈត្តការមានដែនយុត្តាធិការក្នុងការសម្រេចលើចំណុចស្នើទាំងនេះ។[86]
- ចំណុចស្នើទី១០, ១១, ១៣ ដែលពាក់ព័ន្ធនឹងជម្លោះរវាងសកម្មភាពរបស់ចិន និងផលប៉ះពាល់ទៅលើការថែរក្សាបរិស្ថានសមុទ្រក្នុងសមុទ្រចិនខាងត្បូងជុំវិញរចនាសម្ព័ន្ធសមុទ្រ ដែលសកម្មភាពរបស់ចិននេះត្រូវបានហ្វីលីពីនចោទថារំលោភទៅលើបញ្ញត្តិនៃមាត្រា១៩២ និង១៩៤នៃអនុសញ្ញានីតិសមុទ្រ រួមទាំងការរារាំងសកម្មភាពនេសាទប្រពៃណីរបស់ចិនមកលើហ្វីលីពីន និងសកម្មភាពរបស់អជ្ញាធរចិនជុំវិញ និងក្បែតំបន់ Scarborough ដែលកម្មវត្ថុនៃជម្លោះទាំងនេះមិនពាក់ព័ន្ធនឹងការកំណត់ដែនអធិបតេយ្យ ឬការកំណត់ព្រំដែនបាតសមុទ្រឡើយ។ ដូចនេះតុលាការមជ្ឈត្តការរកឃើញថាខ្លួនមានដែនយុត្តាធិការក្នុងការសម្រេចលើចំណុចស្នើទាំងនេះ។[87]
- ចំពោះចំណុចស្នើដទៃទៀតជាកម្មវត្ថុនៃជម្លោះ រួមមានចំណុចទី១, ២, ៣, ៥, ៨, ៩, ១២, ១៤, និង១៥ តុលាការមជ្ឈត្តការបានសម្រេច រក្សាសិទ្ធិក្នុងការសម្រេចលើយុត្តាធិការរបស់ខ្លួនទៅនីតិវិធីបន្ទាប់ភ្ជាប់ជាមួយការចេញសាលដីកាលើអង្គសេចក្តី (Merits phase)[88] ព្រោះចំណុចទាំងនេះមានភាពស្មុគស្មាញ និងទាមទារឱ្យមានការបកស្រាយ ពិនិត្យទៅលើបញ្ហាគតិយុត្តច្រើន មុននឹងតុលាការអាចម្រេចលើបញ្ហាទាំងនេះបាន។ ជាក់ស្តែងដូចមានបញ្ជាក់ក្នុងដីកា ចំណុចស្នើទី១ និង២ ដែលហ្វីលីពីនស្នើដោយផ្ទាល់ឱ្យតុលាការពិនិត្យ និងសម្រេចពីភាពស្របច្បាប់នៃការទាមទាររបស់ចិនពាក់ព័ន្ធនឹង "សិទ្ធិប្រវត្តិសាស្ត្រ" ក៏ដូចជាប្រភពនៃកម្មសិទ្ធិដែនសមុទ្រ (Maritime entitlement) និងតួនាទីអនុសញ្ញានៅក្នុងជម្លោះនេះជាដើម សុទ្ធសឹងតែអាចមានបញ្ហាច្បាប់ផ្សេងទៀត និងតម្រូវការនៃការបកស្រាយ រួមទាំងក្របខណ្ឌអនុវត្តនៃមាត្រាមួយចំនួនដែលពាក់ព័ន្ធផងដែរ (Interpretation and application)។ ដូចនេះ

[85] AWARD ON JURISDICTION AND ADMISSIBILITY, para. 397-412; https://pcacases.com/web/sendAttach/2579

[86] AWARD ON JURISDICTION AND ADMISSIBILITY, para. 400, 401, 403, 404; https://pcacases.com/web/sendAttach/2579

[87] AWARD ON JURISDICTION AND ADMISSIBILITY, para. 407, 408, 410; https://pcacases.com/web/sendAttach/2579

[88] AWARD ON JURISDICTION AND ADMISSIBILITY, para. 398-412;https://pcacases.com/web/sendAttach/2579

ទើចៅក្រមនៃអង្គជំនុំជម្រះហាក់មានការប្រុងប្រយ័ត្នខ្ពស់ ដ្បិតជម្លោះនេះមានលក្ខណៈស្មុគស្មាញច្រើន ហើយរាល់ការសម្រេចបែបបុរេវិនិច្ឆ័យទៅលើអង្គសេចក្តី (Pre-judgement) ត្រូវបានហាមឃាត់ដោយច្បាប់ ដើម្បីធានាយុត្តិធម៌ដល់គូភាគី។[89]

ជាចុងក្រោយ តាមរយៈសាលដីកាមួយចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៦ ប្រកាសដោយតុលាការមជ្ឈត្តការពិសេស បានវិនិច្ឆ័យសម្រេចថាខ្លួនមានយុត្តាធិការទៅលើចំណុចសេសសល់ លើកលែងតែចំណុចទី១៥[90] ប៉ុន្តែនៅតែបញ្ជាក់បន្ថែមថាខ្លួន ពុំមានយុត្តាធិការទៅលើចំណុចជម្លោះដែលពាក់ព័ន្ធនឹងការកំណត់ដែនអធិបតេយ្យ និងក៏ពុំមានយុត្តាធិការលើការកំណត់ព្រំដែនបាតសមុទ្រដែរ។ តុលាការមជ្ឈត្តការនេះក៏បានសម្រេចផងដែរថា ការមិនចូលរួមក្នុងដំណើរការនីតិវិធីរបស់ភាគីចិន មិនមែនជាលក្ខខណ្ឌបញ្ជាក់ពីអសម្ថកិច្ច ឬភាពមិនមានយុត្តាធិការរបស់តុលាការមួយនេះឡើយ ដោយតុលាការបានលើកឡើងទៅមាត្រា៩ នៃឧបសម្ព័ន្ធ ៧ ហើយវត្តមាននៃសេចក្តីថ្លែងការណ៍រួមស្តីពីកិច្ចប្រតិបត្តិរបស់ភាគីក្នុងជម្លោះសមុទ្រចិនខាងត្បូង DOC ក៏មិនបានហាមឃាត់គូភាគីពីការប្រើប្រាស់យន្តការតុលាការមជ្ឈត្តការពិសេសនេះឡើយ។[91]

នៅក្នុងសាលដីកាដដែលតុលាការបានវិនិច្ឆ័យទៅលើ៖

- ជម្លោះរវាងចិន និងហ្វីលីពីនទាក់ទិននៅនឹងប្រភពនៃសិទ្ធិទទួលបានតំបន់សមុទ្រ (Entitlement to maritime zones) (ចំណុចស្នើទី១ និងទី២) ត្រូវបានកំណត់ដោយអនុសញ្ញានីតិសមុទ្រ ហើយការទាមទាររបស់ចិនលើសិទ្ធិប្រវត្តិសាស្ត្រតាមរយៈតំបន់ក្នុង "ខ្សែបន្ទាត់ប្រាំបួនចំណុច" មិនអនុលោមទៅតាមអនុសញ្ញានីតិសមុទ្រឡើយ ហើយមិនមានមូលដ្ឋានគតិយុត្តក្នុងខរក្សាសិទ្ធិរបស់ចិនទេ។
- របបគតិយុត្តនៃរចនាសម្ព័ន្ធសមុទ្រ ក្នុងសមុទ្រចិនខាងត្បូង (ចំណុចស្នើទី៣ ដល់ទី៧)
- សកម្មភាពរបស់ចិនក្នុងសមុទ្រចិនខាងត្បូង ដែលរួមមានការចោទប្រកាន់អំពីការរំខានរបស់ចិនក្នុងសកម្មភាពអធិបតេយ្យរបស់ហ្វីលីពីនក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ (ចំណុចទី៨) ការរំលោភបំពានរបស់ចិនមកលើការនេសាទ និងផលនេសាទរបស់ហ្វីលីពីន (ចំណុចទី៩ និងទី១០) ការចោទប្រកាន់ពីការបរាជ័យក្នុងការការពារបរិស្ថានសមុទ្រ រួមទាំងការកាន់កាប់ និងសកម្មភាពសាងសង់សំណង់ខុសច្បាប់

[89] AWARD ON JURISDICTION AND ADMISSIBILITY, para. 398, 399; https://pcacases.com/web/sendAttach/2579

[90] The South China Sea Arbitration Award of 12 July 2016, para. 1203; https://docs.pca-cpa.org/2016/07/PH-CN-20160712-Award.pdf

[91] The South China Sea Arbitration Award of 12 July 2016, para. 150, 159; https://docs.pca-cpa.org/2016/07/PH-CN-20160712-Award.pdf

របស់ចិនទៅតំបន់ Mischief (ចំណុចទី១១ និង១២) និងសកម្មភាពប្រតិបត្តិការក្នុងចរិតគ្រោះថ្នាក់របស់នាវារបស់កងកម្លាំងអជ្ញាធរ។

- ភាពកាន់តែយ៉ាប់យ៉ឺន ឬការរីកសាយភាយកាន់តែធំនៃជម្លោះរវាងគូភាគី (ចំណុចទី១៤)[92]

## ផ្នែកទី៣៖ មូលហេតុនៃការមិនអាចដោះស្រាយបាននៃជម្លោះ

ជម្លោះសមុទ្រចិនខាងត្បូងរវាងចិន និងហ្វីលីពីនជាជម្លោះដែលមានលក្ខណៈស្មុគស្មាញ និងសាំញ៉ាំ រួមទាំងមានកត្តាច្រើនដែលជាបុព្វហេតុ និងជាកត្តារារាំងដល់ការសម្រេចបាននូវជម្លោះនេះ។ តួយ៉ាងកង្វះខាតនៃយុត្តាធិការចាប់បង្ខំនៃច្បាប់អន្តរជាតិ ដែលពឹងផ្អែកទាំងស្រុងទៅលើសុច្ឆន្ទៈ (Good Faith) របស់រដ្ឋក្នុងការអនុវត្តនូវសេចក្តីសម្រេចនានារបស់តុលាការ រួមទាំងការលូកដៃពីភាគីមិនស្ថិតក្នុងជម្លោះសុទ្ធសឹងតែជាកត្តាចម្បងដែលរារាំងដល់ការសម្រេចបាននូវការបិទបញ្ចប់ជម្លោះមួយនេះ។

### កថាខណ្ឌទី១៖ ភាពមិនអាចអនុវត្តទៅបាននូវសេចក្តីសម្រេចរបស់មជ្ឈត្តការ

ទោះបីជាតុលាការមជ្ឈត្តការពិសេសនេះបានចេញសេចក្តីសម្រេចតាមរយៈសាលដីកាឆ្នាំ២០១៦ របស់ខ្លួនក៏ដោយ ក៏ចិននៅតែប្រកាន់ជំហររបស់ខ្លួនក្នុងការមិនចូលរួម និងមិនទទួលស្គាល់យុត្តាធិការរបស់តុលាការនេះដដែល។ យោងតាមសេចក្តីថ្លែងការណ៍របស់ក្រសួងការបរទេសចិនចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១២, ចិនបានប្រកាសថាដីកាសម្រេចចុងក្រោយ (Final Award) របស់តុលាការមជ្ឈត្តការដែលបង្កើតដោយឯកតោភាគីតាមសំណើរបស់ហ្វីលីពីននេះគឺមិនត្រឹមត្រូវ និងត្រូវចាត់ទុកជាមោឃៈ ហើយដីកានេះក៏គ្មានអនុភាពគតិយុត្តចាប់បង្ខំ(Binding force) នោះដែរ។ ចិនមិនទទួលយក ហើយក៏មិនទទួលស្គាល់ដីកានេះឡើយ។[93] ដែលប្រការនេះបានចោទឡើងម្តងទៀតនូវសំណួរ និងបញ្ហាគតិយុត្តក្នុងការអនុវត្តសេចក្តីសម្រេចរបស់តុលាការអន្តរជាតិ។ ជាគោលការណ៍ទូទៅក្នុងច្បាប់អន្តរជាតិ រាល់ការអនុវត្តកាតព្វកិច្ចនានាដែលមាននៅក្នុងសាលដីកា ឬសេចក្តីសម្រេចរបស់តុលាការអន្តរជាតិគឺពឹងផ្អែកទាំងស្រុងទៅលើគោលការណ៍ "សុឆន្ទៈ" ឬ Good Faith principle របស់គូភាគីក្នុងជម្លោះ ដែលមានន័យថាយុត្តាធិការអន្តរជាតិគ្មានឡើយអំណាច ឬនីតិវិធីអនុវត្តដោយបង្ខំ (Enforcement procedure) ខុសពីការអនុវត្តច្បាប់ក្នុងស្រុកដែលមានចែងពីស្ថាប័នមានសម្ថកិច្ចក្នុងការទទួលបន្ទុកអនុវត្តសាលក្រម សាលដីកា ឬសេចក្តីសម្រេចនានារបស់តុលាការ។ គួរបញ្ជាក់ផងដែរអនុភាពចាប់បង្ខំ (Binding force) របស់សាលដីកា ឬសេចក្តីសម្រេចរបស់យុត្តាធិការអន្តរជាតិ គឺខុសពីការអនុវត្តដោយបង្ខំ (Enforcement procedure) ។ ជាគោលការណ៍នូវរាល់ដីកា ឬសេចក្តីសម្រេចនានារបស់អង្គការយុត្តាធិការ

[92] Ibid

[93] Statement of the Ministry of Foreign Affairs of the People's Republic of China on the Award of 12 July 2016; https://www.fmprc.gov.cn/eng/wjdt_665385/2649_665393/201607/t20160712_679470.html

អន្តរជាតិ សុទ្ធសឹងតែមានអនុភាពចាប់បង្ខំទៅលើគូភាគី។ ក្នុងករណីជម្លោះរវាងចិន និងហ្វីលីពីនក៏ដូចគ្នាដែរ ដ្បិតមានចែងក្នុងមាត្រា២៦ នៃលក្ខន្តិកៈនៃនីតិវិធីរបស់តុលាការមជ្ឈត្តការពិសេសនោះ។[94] ដែលជារួមមានន័យថាសាលដីកា ឬសេចក្តីសម្រេចទាំងនោះមានអនុភាពបង្កើតទំនួលខុសត្រូវសម្រាប់រដ្ឋ អនុលោមតាមច្បាប់អន្តរជាតិ។[95] ប៉ុន្តែចំពោះការអនុវត្តសេចក្តីសម្រេចទាំងនោះវិញ មកទល់សព្វថ្ងៃនេះយើងពុំទាន់ឃើញមានការបង្កើតស្ថាប័នមានសម្តកិច្ចណាមួយដើម្បីទទួលខុសត្រូវក្នុងការអនុវត្តសាលដីកា របស់អង្គការយុត្តាធិការអន្តរជាតិទាំងនោះឡើយ មានន័យថាសេចក្តីសម្រេចរបស់យុត្តាធិការអន្តរជាតិគ្មានឡើយកងកម្លាំង ឬភ្នាក់ងារស្ថាប័នដែលចាំអនុវត្តសេចក្តីសម្រេចទាំងនោះ ខុសពីច្បាប់ជាតិដែលនគរបាលយុត្តិធម៌ជា អ្នកទទួលបន្ទុកក្នុងការអនុវត្តសាលក្រម ឬសាលដីកាតុលាការ។

យ៉ាងណាមិញប្រសិនបើយើងក្រលេកមើលមាត្រា៩៤ នៃធម្មនុញ្ញអង្គការសហប្រជាជាតិវិញបានលើកឡើងថាប្រសិនបើភាគីណាមួយបរាជ័យក្នុងការអនុវត្តកាតព្វកិច្ចក្នុងសេចក្តីសម្រេចរបស់តុលាការ ភាគីម្ខាងទៀតអាចលើកបញ្ហានេះទៅក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិ (UNSC) ដើម្បីពិនិត្យ និងសម្រេចយកសកម្មភាពសមស្របដើម្បីធានាបានការអនុវត្តសេចក្តីសម្រេចនោះ។[96] ប៉ុន្តែពាក្យថាតុលាការត្រង់ប្រការនេះហាក់សំដៅទៅលើសាលដីកាដែលចេញពីតុលាការយុត្តិធម៌អន្តរជាតិ ICJ ដែលជាផ្នែកមួយនៃស្ថាប័នយុត្តិធម៌របស់អង្គការសហប្រជាជាតិ ដោយមិនរាប់បញ្ចូលស្ថាប័នយុត្តិធម៌ ឬអង្គការយុត្តាធិការដទៃទៀតឡើយ ជាហេតុនាំឱ្យវាមិនអាចយកមកអនុវត្តបាននៅលើករណីចិន និងហ្វីលីពីនឡើយ។ ម៉្យាងទៀតក្រុមប្រឹក្សាសន្តិសុខនេះត្រូវបានគេជឿថាជាអង្គការនយោបាយ[97] ជាហេតុនាំឱ្យយន្តការបែបនេះមានលក្ខណៈនយោបាយ និងការទូតច្រើនជាងនីតិវិធីច្បាប់។

ទោះបីសន្មត់ថាខ្លឹមសារនៃមាត្រា៩៤ នេះត្រូវបានយកមកអនុវត្តនៅលើជម្លោះរវាងចិន និងហ្វីលីពីននេះក៏ដោយក៏ដំណោះស្រាយនានានឹងត្រូវបានរាំងស្ទះដ្បិតសមាជិកអចិន្ត្រៃយ៍ទាំង៥ ដែលក្នុងមានចិនមួយផងច្បាស់ជានឹងប្រើសិទ្ធិវេតូរបស់ខ្លួន ក្នុងការជំទាស់លើសកម្មភាពចេញសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សា

94 Article 26, Rule of Procedures; AN ARBITRAL TRIBUNAL CONSTITUTED UNDER ANNEX VII TO THE 1982 UNITED NATIONS CONVENTION ON THE LAW OF THE SEA; https://www.pcacases.com/web/sendAttach/233

95 Draft articles on Responsibility of States for Internationally Wrongful Acts, with commentaries; https://legal.un.org/ilc/texts/instruments/english/commentaries/9_6_2001.pdf

96 Article 94, section 2, UN Charter

97 Mutlaq Majed Al-Qahtani, (2003). ENFORCEMENT OF INTERNATIONAL JUDICIAL DECISIONS OF THE INTERNATIONAL COURT OF JUSTICE IN PUBLIC INTERNATIONAL LAW; https://theses.gla.ac.uk/2487/1/2003Al-QahtaniPhD.pdf

សន្តិសុខ ដូចដែលប្រទេសជាសមាជិកផ្សេងធ្លាប់ប្រើនាពេលកន្លងមកមិនខាន។[98] ឧទាហរណ៍ការប្រើប្រាស់សិទ្ធិវេតូរបស់សហរដ្ឋអាមេរិកក្នុងកិច្ចប្រជុំក្រុមប្រឹក្សាសន្តិសុខឆ្នាំ១៩៨៦ ដែលមានខ្លឹមសារបង្គាប់ឱ្យក្រុមប្រឹក្សាសន្តិសុខ *"អនុវត្តយ៉ាងពេញលេញ"* ទៅតាមសេចក្តីសម្រេចរបស់តុលាការយុត្តិធម៌អន្តរជាតិដែលបង្គាប់ឱ្យសហរដ្ឋអាមេរិកដកទ័ព និងបញ្ឈប់ការផ្តល់ជំនួយដល់ក្រុមប៉ះបោរក្នុងប្រទេស Nicaragua។[99] ម្យ៉ាងវិញទៀតប្រសិនបើគេក្រលេកមើលគោលជំហររបស់ចិនដែលជាភាគីជម្លោះពេលគឺចិនវិញ យើងអាចសន្និដ្ឋានបានថាចិនពុំមានឆន្ទៈក្នុងការដោះស្រាយជម្លោះនេះតាមផ្លូវច្បាប់ ឬផ្លូវតុលាការឡើយដោយជារឿយៗ ក្រសួងការបរទេសតំណាងរដ្ឋាភិបាលចិនតែងប្រកាសមិនទទួលស្គាល់យុត្តាធិការតុលាការ ឬមជ្ឈត្តការនានា។ ហេតុនេះហើយទើបមានការលើកឡើងពីលទ្ធភាពនៃការដកខ្លួនចេញរបស់ចិនពីអនុសញ្ញានីតិសមុទ្រ UNCLOS ប្រសិនបើសេចក្តីសម្រេចរបស់តុលាការមជ្ឈត្តការពិសេសត្រូវបាន ឬមានលទ្ធភាពអនុវត្តបាន។ សម្រាប់ទីក្រុងប៉េកាំង ជម្លោះនៅសមុទ្រចិនខាងត្បូងនេះជាភាពជាប់គាំង (Dilemma) សម្រាប់ខ្លួនឯងដ្បិតចិនជាភាគីមួយដែលបានចូលរួមចរចារបង្កើតអនុសញ្ញានេះពីឆ្នាំ១៩៧៣ ដល់ឆ្នាំ១៩៨២។[100] ប្រសិនបើចិនពិតជាដកខ្លួនចេញដោយហេតុផលណាមួយមែននោះ ចង់មិនចង់វាអាចនឹងជះឥទ្ធិពលគម្រាមកំហែងដល់សន្តិសុខ និងស្ថិរភាពតំបន់ទាំងមូលផងដែរ។

**កថាខណ្ឌទី២៖ ការលូកដៃពីរដ្ឋមិនមែនភាគីនៃជម្លោះ**

ជម្លោះដែនអធិបតេយ្យនៅសមុទ្រចិនខាងត្បូង បានទាក់ទាញចំណាប់អារម្មណ៍ពីសំណាក់ពិភពលោកពិសេសប្រទេសនូវរាល់បណ្តាប្រទេសដែលសម្លឹងឃើញមានប្រយោជន៍ជាតិ (National Interests) ដែលអាចទាញបានពីដែនទឹកមានជម្លោះ។ ឧទាហរណ៍ជម្លោះដែលផ្តើមឡើងពីប្រទេសចិន និងហ្វីលីពីនបានបន្តកើនឡើងរហូតដល់០៦ភាគីជម្លោះគិតមកដល់បច្ចុប្បន្ន ដែលក្នុងនោះមានរហូត០៥ ជាសមាជិកអាស៊ាន។ នេះក៏អាចជារនាំងឧបសគ្គមួយដែលរារាំងដល់ការសម្រេចបាននូវក្រមប្រតិបត្តិសមុទ្រចិន ខាងត្បូង ឬ COC ផងដែរដ្បិតអីអាស៊ានផ្អែកលើការសម្រេចចិត្តបែបឯកច្ឆន្ទ ឬកុងសង់ស៊ីស ក្នុងការសម្រេចចិត្តនានារបស់ខ្លួន។[101] ក្រៅពីនេះគេក៏សង្កេតឃើញតែងមានការ "លូកដៃ" ឬបង្កសកម្មភាពផ្សេងៗពីប្រទេសក្នុង និងក្រៅតំបន់មួយចំនួន ដែល

[98] UN Security Council Meetings & Outcomes Tables; https://research.un.org/en/docs/sc/quick

[99] U.S. Vetoes Nicaraguan Resolution On Compliance With Court Decision; https://washingtonpost.com/archive/politics/1986/08/01/us-vetoes-nicaraguan-resolution-on-compliance-with-court-decision/ecdf20d6-cf3a-4761-ba23-5c49a9fa379a/

[100] Wang. J. (2016). China and UNCLOS: An Inconvenient History; https://thediplomat.com/2016/07/china-and-unclos-an-inconvenient-history/

[101] Article 20, ASEAN Charter

ភាគីជម្លោះពិសេសគឺចិន តែងចាត់ទុកថាជាការលូកដៃ ឬអន្តរាគមន៍រារាំងកិច្ចប្រឹងប្រែងជម្លោះរបស់ខ្លួន។ ជាក់ស្តែងក្រោយពីចិនសម្រេចបដិសេដមិនទទួលស្គាល់សេចក្តីសម្រេចរបស់តុលាការមជ្ឈត្តការពិសេស ពាក់ព័ន្ធនឹងជម្លោះសមុទ្រចិនខាងត្បូងកាលពីឆ្នាំ២០១៦ កន្លងទៅ[102] បណ្តាប្រទេស G7 និងសហភាពអឺរ៉ុប EU ផងបានចេញសេចក្តីអំពាវនាវឱ្យចិនគោរពតាមការសម្រេចរបស់តុលាការមជ្ឈត្តការនេះ។[103] ក្រៅពីនេះគេក៏សង្កេតឃើញមានការធ្វើសកម្មភាពដទៃទៀតដែលចិនតែងចាត់ទុកថាជាការគម្រាមកំហែងដល់សន្តិសុខជាតិ និងការបញ្ចប់ជម្លោះនេះ តួយ៉ាងសហរដ្ឋអាមេរិក ដែលគេតែងចាត់ទុកថាជាគូប្រជែងយុទ្ធសាស្ត្ររបស់ចិន ជាថ្មីម្តងទៀតក្រោយហ្វីលីពីនផ្លាស់ប្តូរប្រធានាធិបតី ពោលគឺក្រោយលោក Ferdinand Romualdez Marcos Jr. ឡើងកាន់តំណែង អាមេរិក និងហ្វីលីពីន តាមរយៈកិច្ចព្រមព្រៀងពង្រឹងកិច្ចសហប្រតិបត្តិការការពារជាតិ Enhanced Defense Cooperation Agreement (EDCA) បានផ្តល់បន្ទាយទាហ៊ានចំនួន0៤ សម្រាប់កងយោធារបស់សហរដ្ឋអាមេរិកមកដាក់ពង្រាយនៅហ្វីលីពីន។[104] ស្រដៀងគ្នានេះដែរ ជារឿយៗអាមេរិក និងសម្ព័ន្ធមិត្តតែងចល័តនាវាផ្ទុកយន្តហោះ (Aircraft Carrier) មកតំបន់ដែនទឹកមានជម្លោះ និងធ្វើប្រតិបត្តិការហោះហើរនានានៅតំបន់នោះផងដែរ។[105] សកម្មភាពបែបនេះត្រូវបានភាគីចិន ចាត់ទុកថាជាសកម្មភាពបង្កភាពតានតឹង ជាក់ស្តែងលោក Wang Yi រដ្ឋមន្ត្រីការបរទេសចិនបានថ្លែងកាលពីឆ្នាំ២០២២ កន្លងទៅថា "*យើងបានមើលឃើញថាប្រទេសក្រៅតំបន់មួយចំនួនមិនសប្បាយចិត្តនិងភាពស្ងប់ស្ងាត់នៅសមុទ្រចិនខាងត្បូង ហើយលោកសង្ឃឹមថាអាស៊ាននឹងមើលឃើញពីចំណុចនេះ ហើយនឹងធ្វើកិច្ចសហប្រតិបត្តិការដើម្បីកុំឱ្យមានការលូកដៃពីភាគីដទៃខាងក្រៅ*" ។[106] ឯភាគីអាមេរិកវិញបានចាត់ទុកថានេះជាសកម្មភាពនេះ ជាសកម្មភាពស្របតាមច្បាប់អន្តរជាតិពិសេសគោលការណ៍សេរីភាពនាវាចរ ឬ Freedom of Navigation ប៉ុណ្ណោះ។[107]

---

[102] China neither accepts nor recognizes so-called award on South China Sea arbitration http://english.scio.gov.cn/pressroom/2023-07/13/content_92131216.htm

[103] South China Sea: The Positions and the Facts https://www.crisisgroup.org/asia/south-east-asia/south-china-sea/south-china-sea-positions-and-facts

[104] Philippines reveals locations of 4 new strategic sites for U.S. military pact https://www.reuters.com/world/asia-pacific/philippines-reveals-locations-4-new-strategic-sites-us-military-pact-2023-04-03/

[105] Carrier USS Ronald Reagan Now in the South China Sea; https://news.usni.org/2023/06/19/carrier-uss-ronald-reagan-now-in-the-south-china-sea

[106] ASEAN must prevent 'external interference' in South China Sea row https://www.phnompenhpost.com/international/asean-must-prevent-external-interference-south-china-sea-row

[107] US carrier strike group begins operating in South China Sea as tensions with China simmer; https://edition.cnn.com/2023/01/13/politics/us-strike-group-south-china-sea/index.html

ក្រៅតែពីអាមេរិកគេសង្កេតឃើញ ជប៉ុនក៏ជារឿយបានអំពាវនាវឱ្យមានការបញ្ចប់ជម្លោះនៅសមុទ្រចិនខាងត្បូងផងដែរ។ ប៉ុន្តែសកម្មភាពមួយចំនួនរបស់ទីក្រុងតូក្យូ ត្រូវបានរដ្ឋាភិបាលទីក្រុងប៉េកាំងចាត់ទុកថាជាសកម្មភាពបង្កើនភាពតានតឹង និងជាកត្តាជម្រុញឱ្យជម្លោះកាន់តែតានតឹង។ សកម្មភាពទាំងនោះ របស់ជប៉ុនរួមមានការបង្កើនការចំណាយយោធា ការសាងសង់មូលដ្ឋានយោធានៅកោះ Okinawa រួមទាំងការធ្វើសមយុទ្ធរវាងជប៉ុន និងអាមេរិកជាដើម។[108] សម្រាប់ទីក្រុងតូក្យូ សមុទ្រចិនខាងត្បូងជាដែនទឹកយុទ្ធសាស្ត្រ ដ៏សំខាន់មួយដ្បិតជាង៨០% នៃទំហំនាំចូលឥន្ទនៈរបស់ជប៉ុនគឺបានដឹកឆ្លងកាត់សមុទ្រចិនខាងត្បូង ហើយក៏ជាដែនទឹកយុទ្ធសាស្ត្រសន្តិសុខមួយដែលមិនអាចមលើរំលងបានដែរដ្បិតជប៉ុន និងចិនក៏មានវិវាទនៅតំបន់ប្រជុំកោះ Senkaku/Diaoyu ផងដែរ។ មិនតែប៉ុណ្ណោះការលេចត្រដែតឡើងនូវអានុភាព និងការបង្កសកម្មភាពមួយចំនួនរបស់ចិនតួយ៉ាងការចល័តនាវាកងទ័ព ការសង់មូលដ្ឋានយោធាសមុទ្រ ត្រូវបានជប៉ុនមើលឃើញថានឹងជះឥទ្ធិពលដល់សន្តិសុខ និងជីវិត (Survival) របស់ជប៉ុន និងតំបន់ទាំងមូលផងដែរ។ ក្តីបារម្ភនេះត្រូវបានរំលេចឡើងកាន់តែច្បាស់ ក្រោយអតីតតនាយករដ្ឋមន្ត្រីជប៉ុនលោក Abe Shinzo លើកឡើងថា *"កាន់តែខ្លាំងឡើងៗ សមុទ្រចិនខាងត្បូងកំពុងត្រូវបានប្រែក្លាយជា បឹងប៉េកាំង (Lake Beijing) ហើយ"*។

ដោយសារតែសកម្មភាពដែលតែងតែចោទគ្នាទៅវិញទៅមកនេះរវាងភាគីក្នុងជម្លោះចិន និងហ្វីលីពីន រួមទាំងភាគីមិនស្ថិតក្នុងជម្លោះទាំងក្នុង និងក្រៅតំបន់បានជម្រុញជម្លោះនេះឱ្យកាន់តែស្មុគស្មាញ និងពិបាករកដំណោះស្រាយបិទបញ្ចប់។

[108]Carrier USS Ronald Reagan Now in the South China Sea; https://news.usni.org/2023/06/19/carrier-uss-ronald-reagan-now-in-the-south-china-sea

# ជំពូកទី៣៖ យន្តការដោះស្រាយ ជម្លោះដែលអាចប្រកាន់

## ជំពូកទី៣៖ យន្តការដោះស្រាយជម្លោះដែលអាចប្រកាន់យក

ជម្លោះនៅក្នុងលំហរសមុទ្រចិនខាងត្បូងពិសេសរវាងប្រទេសចិន និងហ្វីលីពីនបានជះឥទ្ធិពលអវិជ្ជមានយ៉ាងខ្លាំងទាំងទៅលើចំណងសេដ្ឋកិច្ច និងការទូតរវាងប្រទេសទាំងពីរ រួមទាំងមកលើសេដ្ឋកិច្ច សន្តិសុខ និងស្ថិរភាពតំបន់អាស៊ីអាគ្នេយ៍ជារួមផងដែរ។ ក្នុងបរិបទដែលពិភពលោកកំពុងបោះជំហានកាន់តែជិតទៅរកភាពបែកបាក់គ្នាដូចសព្វថ្ងៃ ប្រទេសទាំងពីរ រឹតតែត្រូវធ្វើយ៉ាងណាឆាប់ដោះស្រាយ និងស្វែងរកមធ្យោបាយមួយដែលអាចបញ្ចប់ជម្លោះដ៏រ៉ាំរ៉ៃនេះដោយសន្តិវិធី និងចៀសឱ្យបានការប្រឈមមុខដាក់គ្នាដោយប្រការណាមួយ។ ខាងក្រោមជាមធ្យោបាយមួយចំនួនដែលចិន និង ហ្វីលីពីនអាចប្រកាន់យក ដោយរួមមានយន្តការក្រៅប្រព័ន្ធតុលាការ (ផ្នែកទី១) និងយន្តការតុលាការ (ផ្នែកទី២)។

### ផ្នែកទី១៖ យន្តការក្រៅប្រព័ន្ធតុលាការ

បើទោះបីជាទំនាកទំនងចិន និងហ្វីលីពីននាពេលថ្មីៗនេះ មានភាពមិនល្អក់កករនឹងគ្នាដោយសារតែជម្លោះដណ្តើម ដែនអធិបតេយ្យនៅសមុទ្រចិនខាងត្បូង និងសមុទ្រហ្វីលីពីនខាងលិច ដែលប្រឈមមុខដាក់គ្នាតាំងពីឆ្នាំ ២០១២ មកនិងបញ្ហារបស់ចិន ដែលបានឈ្លានពានកាន់កាប់ និង ការបង្កើតហេដ្ឋារចនាសម្ព័ន្ធខុសច្បាប់ ថែមទាំងឈ្លានពានកាន់កាប់នៅតំបន់សេដ្ឋកិច្ចផ្តាច់មុខ (EEZ) ។ ទោះជាទំនាក់ទំនងទ្វេភាគីត្រូវបានធ្លាក់ចុះដោយ ហ្វីលីពីនបានប្តឹងប្រទេសចិនទៅតុលាការមជ្ឈការ ដែលនៅក្រោមអនុសញ្ញាសហប្រជាជាតិស្តីពីនីតិសមុទ្រ (UNCLOS) កាលពីឆ្នាំ ២០១៣ នេះ ទៅលើខ្សែបន្ទាត់ប្រាំបួនចំណុច (Nine-Dash Lines) របស់ចិន នៅក្នុងតំបន់ប្រកួតប្រជែង។[109] ទោះបីជាមានជម្លោះដែនដីជាច្រើនក៏ដោយ ចិន និងហ្វីលីពីន នៅតែរក្សាទំនាក់ទំនងកិច្ចសហប្រតិបត្តិការទ្វេភាគី និង កិច្ចព្រមព្រៀងទ្វេភាគី ជាមួយគ្នានៅលើវិស័យផ្សេងៗទៀត។ ទំនាក់ទំនងរវាង ចិន និងហ្វីលីពីន មានការប៉ះទង្គិចខ្លាំងយ៉ាងណាក៏ដោយ ក៏គេនៅតែមានកិច្ចសហប្រតិបត្តិការជាមួយគ្នា និងទាញផលប្រយោជន៍ពីគ្នាទៅវិញទៅមក។

ពាណិជ្ជកម្មរវាងហ្វីលីពីននិងចិនមិនត្រឹមតែមានស្ថិរភាពប៉ុណ្ណោះទេ ប៉ុន្តែក៏មានការរីកចម្រើនផងដែរ។ យោងតាមនាយកដ្ឋានពាណិជ្ជកម្ម និងឧស្សាហកម្មហ្វីលីពីន (DTI) ពាណិជ្ជកម្មសរុបឈានដល់ ១៤.៦ពាន់លានដុល្លារក្នុងឆ្នាំ ២០១៣ ដែលជាការកើនឡើងគួរឱ្យកត់សម្គាល់ពីឆ្នាំ ២០១១ និង ២០១២ ហើយស្ថិតិពាណិជ្ជកម្មកើនឡើងបង្ហាញថាវិស័យសេដ្ឋកិច្ច និងនយោបាយក្នុងទំនាក់ទំនងទ្វេភាគីអាច បែងចែកជាផ្នែក

[109] Andrea Chloe A. Wong, Philippines-China Relations: Beyond the Territoral Disputes, August 14, 2023 <https://fsi.gov.ph/philippines-china-relations-beyond-the-territoral-disputes/#:~:text=Philippines-China%20relations%20have%20lately,of%20infrastructures%2C%20and%20incidents%20of>

សម្រាប់ផលប្រយោជន៍ទៅវិញទៅមក។[110] យោងតាមនាយកដ្ឋានទេសចរណ៍ហ្វីលីពីន (DOT) បានឱ្យដឹងថា ចិនបន្តជាប្រភពទេសចរដ៏សំខាន់សម្រាប់ហ្វីលីពីន ដោយជនជាតិចិនជាង ៤ សែននាក់បានមកទស្សនាប្រទេសនេះក្នុងឆ្នាំ ២០១៣។ ការមកដល់របស់ភ្ញៀវទេសចរចិនកាន់តែច្រើនមើលទៅមានការរីកចម្រើននៅពេលដែល DOT បង្កើនការផ្សព្វផ្សាយទេសចរណ៍នៅក្នុងប្រទេសចិន។ ជាលទ្ធផលនៃយុទ្ធនាការ "វាកាន់តែសប្បាយនៅក្នុងប្រទេសហ្វីលីពីន" [111]ហ្វីលីពីនបានក្លាយជាគោលដៅជ្រើសរើសសម្រាប់ភ្ញៀវទេសចរចិន។

ភាពលេចធ្លោនៃបញ្ហានយោបាយ និងសន្តិសុខបានបង្ហាញពីភាពធំធេង និងពហុទិដ្ឋភាពនៃទំនាក់ទំនងហ្វីលីពីននិងចិន។ មានឱកាសជាច្រើនសម្រាប់កិច្ចសហប្រតិបត្តិការ កិច្ចសហប្រតិបត្តិការ និងការផ្លាស់ប្តូរដែលប្រទេសទាំងពីរអាចស្វែងរកបាន ប្រសិនបើមិនមានការពង្រឹង។ ជាចុងក្រោយ គោលដៅគឺដើម្បីទប់ស្កាត់ជម្លោះដែលអូសបន្លាយយូរពីការប៉ះពាល់ដល់កិច្ចខិតខំប្រឹងប្រែងសហប្រតិបត្តិការដែលមានស្រាប់ និងសក្តានុពល ជាពិសេសនៅក្នុងពន្លឺនៃការកើនឡើងនូវភាពអាស្រ័យគ្នានៃសេដ្ឋកិច្ច និងទំនាក់ទំនងវប្បធម៌ដ៏ស៊ីជម្រៅរវាងប្រជាជាតិទាំងពីរ។ ជាងនេះទៅទៀត វាមានតរិយាបទទាំងរដ្ឋាភិបាលហ្វីលីពីន និងចិនក្នុងការលើកទឹកចិត្តឱ្យមានការផ្លាស់ប្តូររវាងប្រជាជននិងប្រជាជនកាន់តែច្រើន និងត្រួសត្រាយផ្លូវសម្រាប់ទំនាក់ទំនងសាធារណៈកាន់តែច្រើន។

ចាប់តាំងពីវាគ្រាន់តែជាឧប្បត្តិហេតុអរិភាព (ឧប្បត្តិហេតុដែលនាំឲ្យក្លាយជាគូជម្លោះនឹងគ្នា) នៅសមុទ្រចិនខាងត្បូងដែលបានជះឥទ្ធិពលអវិជ្ជមាន និងការមិនទុកចិត្តគ្នា ហ្វីលីពីន និងចិនត្រូវតែចងចាំតម្លៃយូរអង្វែងនៃការរក្សាកិច្ចសហប្រតិបត្តិការមុខងារដើម្បីរក្សាទំនាក់ទំនងទ្វេភាគីឱ្យលើសពីជម្លោះ។ សម្រាប់ហ្វីលីពីន ប្រទេសចិនគឺជាដៃគូសេដ្ឋកិច្ចដ៏សំខាន់ដែលខ្លួនត្រូវតែដោះស្រាយជានិច្ច ដើម្បីទទួលបានអត្ថប្រយោជន៍ផ្នែកហិរញ្ញវត្ថុសម្រាប់ជាប្រយោជន៍ដល់ការអភិវឌ្ឍន៍ជាតិរបស់ខ្លួន។ សម្រាប់ប្រទេសចិន ហ្វីលីពីនគឺជាប្រជាជាតិដ៏សំខាន់មួយ ដែលខ្លួនត្រូវតែចូលរួមជាមួយដើម្បីទទួលបានការជឿទុកចិត្ត និងការគោរពពីរដ្ឋផ្សេងទៀតនៅក្នុងតំបន់ ជាពិសេសដោយសារតែវាបង្ហាញថាខ្លួនជាមហាអំណាចដែលមានការទទួលខុសត្រូវ។[112] ខណៈពេលដែលការការពារអធិបតេយ្យភាពទឹកដីគឺជារឿងសំខាន់បំផុត ប្រទេសមួយក៏ត្រូវតែធ្វើការជាមួយប្រទេសផ្សេង

---

[110] Andrea Chloe A. Wong, Philippines-China Relations: Beyond the Territoral Disputes, August 14, 2023 <https://fsi.gov.ph/philippines-china-relations-beyond-the-territoral-disputes/#:~:text=Philippines-China%20relations%20have%20lately,of%20infrastructures%2C%20and%20incidents%20of>

[111] It´s More Fun in The Philippines, Department of Tourism <http://www.itsmorefuninthephilippines.com>

[112] Andrea Chloe A. Wong, Philippines-China Relations: Beyond the Territoral Disputes, August 14, 2023 <https://fsi.gov.ph/philippines-china-relations-beyond-the-territoral-disputes/#:~:text=Philippines-China%20relations%20have%20lately,of%20infrastructures%2C%20and%20incidents%20of>

ទៀតដើម្បីផលប្រយោជន៍ផ្សេងទៀត និងផលប្រយោជន៍ទៅវិញទៅមក។ ដូច្នេះ វាជារឿងមិនអាចខ្វះបាន សម្រាប់ហ្វីលីពីន និងចិនក្នុងនាមជាប្រទេសជិតខាងក្នុងការភ្ជាប់ទំនាក់ទំនងគ្នាទៅវិញទៅមក ទោះបីមានការខ្វែងគំនិតគ្នាខាងភូមិសាស្ត្រនយោបាយ និងសន្តិសុខ។

**កថាខណ្ឌទី១ ការចរចាការទូត**

កិច្ចចរចារការទូតដើម្បីស្វែងរកដំណោះស្រាយ នៅតែជាជម្រើសល្អសម្រាប់គូភាគីក្នុងជម្លោះសមុទ្រចិន ខាងត្បូងដ្បិតការចរចាអាចមានប្រសិទ្ធិភាព និងលឿនរហ័សជាជាងការប្រឈមមុខគ្នានៅតុលាការ។ ក្រៅពីនេះគូភាគីអាចស្វែងរកដំណោះស្រាយណាមួយដែលផ្តល់ប្រយោជន៍បានដល់ភាគីទាំងសងខាង ឬដែលគេតែងស្គាល់ថា "យុទ្ធសាស្ត្រឈ្នះៗ"។ ដើម្បីធ្វើដូច្នេះបានគូភាគីអាចស្វែងរកចំណុចចាប់ផ្តើមសមស្របណាមួយសម្រាប់បរិបទករណីសមុទ្រចិនខាងត្បូងនេះវិញ ការសម្រេចបាននូវក្រមប្រតិបត្តិ ឬ COC នៅតែជាជម្រើសល្អដើម្បីជាឧបករណ៍ក្នុងការកាត់បន្ថយភាពតានតឹង និងឈានទៅរកការបញ្ចប់ជម្លោះ។ សម្រាប់ភាគីទាំងសងខាង ការស្វែងរកនៅ "សម្បទាន" ឬ Compromise ឱ្យខានតែបានគឺជាប្រការចាំបាច់ក្នុងការសម្រេចបាននូវកិច្ចព្រមព្រៀងមួយនេះ។ ទោះជាយ៉ាងណាក៏ដោយ ក៏មានមតិខ្លះលើកឡើងថាក្រមប្រតិបត្តិដែលហាក់មានចរិតធូរលុង (Loose form of Code) នេះវានឹងពុំអាចជះឥទ្ធិពលចាប់បង្ខំអ្វីខ្លាំងលើគូភាគី និងទិដ្ឋភាពជម្លោះជារួមបានច្រើននោះឡើយ។[113]

ភាគីទាំងពីរក៏អាចប្រើប្រាស់អំណាចទន់ (Soft Power[114]) ដើម្បីអនុវត្តន៍ភាពងាយស្រួល ក្នុងទម្រង់កីឡា និងការផ្លាស់ប្តូរវប្បធម៌ គឺគេប្រើជាចាំបាច់ដើម្បីកុំឲ្យមានការប្រើអំណាចរឹង (Hard Power[115]) រវាងចិន និង ហ្វីលីពីន ដែលប្រទេសទាំងពីរនេះជាប្រទេសដែលមាន អំណាច ឥទ្ធិពល និងកម្រិតមិនស្មើគ្នា។ [116] សកម្មភាពកីឡា និងវប្បធម៌បានចូលរួមចំណែកកាន់តែខ្លាំងឡើងក្នុងការជំរុញការយល់ដឹងក្នុងចំណោមប្រជាជនហ្វីលីពីន និងចិន។ អតីតតារា NBA លោក Yao Ming បានទៅលេងប្រទេសហ្វីលីពីនសម្រាប់ការប្រកួត

---

[113] Chatys M., (2023). THE CODE OF CONDUCT – A WAY TO MOVE FORWARD WITH THE SOUTH CHINA SEA DISPUTE? https://pulaski.pl/the-code-of-conduct-a-way-to-move-forward-with-the-south-china-sea-dispute/#_edn10

[114] អំណាចទន់ (Soft Power) គឺជាសមត្ថភាពដើម្បីបញ្ចុះបញ្ចូលអ្នកដទៃឱ្យធ្វើអ្វីដែលខ្លួនចង់បាន។

[115] អំណាចរឹង (Hard Power) គឺផ្អែកលើអន្តរាគមន៍យោធា ការទូតបង្ខិតបង្ខំ និងទណ្ឌកម្មសេដ្ឋកិច្ច ហើយភាគច្រើនពឹងផ្អែកលើធនធានថាមពលជាក់ស្តែង ដូចជាកងកម្លាំងប្រដាប់អាវុធ ឬមធ្យោបាយសេដ្ឋកិច្ច។

[116] Soft Power, Hard Power and Public Diplomacy: Deputy Chief of Mission Robert B. Hilton's Remarks at BIDTI. U.S. Embassy in Sri Lanka, June 08, 2018<https://lk.usembassy.gov/soft-power-hard-power-and-public-diplomacy-deputy-chief-of-mission-robert-b-hiltons-remarks-at-bidti>

តាំងពិពណ៌រវាងក្រុមបាល់បោះហ្វីលីពីន និងចិនក្នុងខែឧសភា ឆ្នាំ ២០១៣[117]។ ទន្ទឹមនឹងនេះ ស្ថានកុងស៊ុលហ្វីលីពីនប្រចាំទីក្រុងសៀងហៃ បានរៀបចំកម្មវិធី "រសជាតិនៃប្រទេសហ្វីលីពីន" នៅក្នុងខែកញ្ញា ឆ្នាំ ២០១៣ ដែលជាព្រឹត្តិការណ៍វប្បធម៌មួយដែលបង្ហាញពីអាហារហ្វីលីពីន តន្ត្រីប្រពៃណី និងរបាំប្រជាប្រិយ។[118] ការរៀបចំជាបន្តនៃគំនិតផ្តួចផ្តើមកីឡា និងវប្បធម៌ អាចបម្រើដើម្បីពង្រឹងទំនាក់ទំនងរវាងប្រជាជននិងប្រជាជននៃប្រទេសទាំងទាំងពីរបាន។ ដូចនេះ រដ្ឋាភិបាលដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើតការគាំទ្រជាតិដ៏រឹងមាំ និងក្នុងការពង្រឹងទំនាក់ទំនងទ្វេភាគីដោយការកែលម្អការយល់ឃើញក្នុងស្រុក និងអន្តរជាតិ។

**កថាខណ្ឌទី២ ការបង្កើតតំបន់អភិវឌ្ឍន៍រួម** ( Joint Development Zone )

ក្រៅតែពីកិច្ចចរចារការទូតហើយនោះ ការប្រើប្រាស់វិធានការបណ្តោះអាសន្នណាមួយទៅលើតំបន់មានជម្លោះក៏ជាមធ្យោបាយមួយល្អសម្រាប់ទប់ទល់កុំឱ្យមានការប្រឈមមុខគ្នាខ្លាំង ខណៈពេលដែលគូភាគីកំពុងស្វែងរកដំណោះស្រាយ។ យន្តការមួយដែលពេញបានចាប់ផ្តើមពេញនិយមចាប់ពីអំឡុងទសវត្សឆ្នាំ១៩៥០ ក្នុងការជ្រើសរើសជាយន្តការបណ្តោះអាសន្ននោះគឺ "តំបន់អភិវឌ្ឍន៍រួម ឬ Joint Development Zone (JDZ) [119]។ ទោះបីជាទទួលបានការពេញនិយម និងប្រើប្រាស់ជាយូរហើយមកក៏ដោយ ក៏គោលគំនិតនៃតំបន់អភិវឌ្ឍន៍រួមនេះ នៅពុំទាន់មាននិយមន័យជាផ្លូវការណាមួយឡើយ ប៉ុន្តែជារួមគេអាចនិយាយបានថាតំបន់អភិវឌ្ឍន៍រួមសំដៅលើកិច្ចសហប្រតិបត្តិការអន្តររដ្ឋាភិបាលរវាងភាគីដែលមានជម្លោះដែនអធិបតេយ្យ ក្នុងការបង្កើតនូវកិច្ចព្រមព្រៀងមួយដើម្បីសាងសង់ អភិវឌ្ឍន៍ និងត្រួតពិនិត្យរួមគ្នាទៅលើតំបន់ដែលមានជម្លោះ។ កិច្ចព្រមព្រៀងទាំងនោះជាទូទៅរួមបញ្ចូលទាំងការប្រើប្រាស់ធនធានមានជីវិតដូចជាធនធានត្រី រួមទាំងការទាញយកផលប្រយោជន៍ពីធនធានគ្មានជីវិតផ្សេងទៀតដូចជាប្រេងកាត ឧស្ម័នធម្មជាតិ ឬធនធានអ៊ីដ្រូកាបួនទៃទៀត។[120]

យន្តការតំបន់អភិវឌ្ឍន៍រួមនេះក៏ជាស្មារតីនៃច្បាប់អន្តរជាតិផងដែរដ្បិតក្នុងកថាខណ្ឌ៣នៃ មាត្រា៧៤ និងមាត្រា៨៣ នៃអនុសញ្ញានីតិសមុទ្របានចែងថាៈ *...រដ្ឋដែលពាក់ព័ន្ធក្នុងអំឡុងពេលស្វែងរកការចុះសន្ធិសញ្ញា*

[117] Yao Ming in Manila for friendship games. (2013, May 5). China Daily. <https://www.chinadaily.com.cn/sports/2013-05/05/content_16476333.htm>

[118] Lee-Brago, P., Pinoy food fest opens in Shanghai, September 8, 2013 <https://www.philstar.com/headlines/2013/09/08/1185531/pinoy-food-fest-opens-shanghai>

[119] Bernard L., (n.d.), PROSPECT FOR JOINT DEVELOPMENT IN THE SOUTH CHINA SEA; https://cil.nus.edu.sg/wp-content/uploads/2013/06/Bernard-CSIS-Draft-1-June-2013-Prospect-for-Joint-Development-in-the-SCS.pdf

[120] Faiz Aziz M., (2018.), Developing Joint De eloping Joint Development Z elopment Zone in Disputed Maritime one in Disputed Maritime Boundaries; https://scholarhub.ui.ac.id/cgi/viewcontent.cgi?article=1062&context=ijil

*កំណត់ព្រំដែន ក្នុងស្មារតីនៃការយោគយល់ និងកិច្ចសហប្រតិបត្តិការ ត្រូវព្យាយាមឱ្យអស់លទ្ធភាពក្នុងការស្វែងរកការបង្កើតវិធានការបណ្តោះអាសន្នដែលមានចរិតប្រាកដនិយមមួយ ក្នុងដំណាក់កាលអន្តរកាលនេះ។ វិធានការនេះដែមិនត្រូវបង្កើតឡើងក្នុងគោលបំណងរារាំងការចុះសន្ធិសញ្ញាដើម្បីបញ្ចប់ជម្លោះនោះទេ...។*[121] ក្នុងស្មារតីនេះប្រសិនបើគូភាគីក្នុងជម្លោះសមុទ្រចិនខាងត្បូងនេះ អាចស្វែងរកនៅការបង្កើតកិច្ចព្រមព្រៀងអភិវឌ្ឍន៍រួម (JDA) បាននោះវាជាប្រការមួយល្អដ្បិតក្រៅតែពីមានលទ្ធភាពក្នុងការកាត់បន្ថយការប្រឈមមុខដាក់គ្នាហើយ កិច្ចព្រមព្រៀងនេះ ក៏នឹងអាចបើកផ្លូវឱ្យភាគីទាំងពីទាញយកផលប្រយោជន៍ពីធនធានដ៏មហាសាលក្នុងតំបន់ដែនទឹកមានជម្លោះផងដែរ។ ប្រការនេះនឹងអាចជាត្រីវិស័យក្នុងការស្តាឡើងវិញនូវទំនាក់ទំនងការទូត និងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរវាងទីក្រុងប៉េកាំង និងទីក្រុងម៉ានីលដែលអាចជម្រុញទៅរកការបញ្ចប់ជម្លោះជាស្ថាពរណាមួយ។ ជាក់ស្តែងចាប់តាំងពីឆ្នាំ២០១៧ មកគេសង្កេតឃើញមានការលើកឡើងពីគំនិតផ្តួចផ្តើមបង្កើតតំបន់អភិវឌ្ឍន៍រួមនៅសមុទ្រចិនខាងត្បូង ពិសេសរវៀងចិន ហ្វីលីពីន និងវៀតណាម។[122]

ទោះជាយ៉ាងនេះក៏ដោយក៏យន្តការនេះនៅមានឧបសគ្គចម្បងផ្សេងៗ មួយចំនួនផងដែរដូចជាការប្រើប្រាស់ពាក្យពេចន៍ វិសាលភាពនៃកិច្ចព្រមព្រៀង និងជាពិសេសឆន្ទៈរបស់គូភាគីផងដែរ។

## ផ្នែកទី២៖ យន្តការតាមផ្លូវតុលាការ

ទោះបីជាមានការប្រើប្រាស់យន្តការតុលាការតាមរយៈការប្តឹងរបស់ហ្វីលីពីនទៅកាន់តុលាការមជ្ឈត្តការពិសេសក្នុងឧបសម្ព័ន្ធ៧ និងរហូតមានការចេញសេចក្តីសម្រេចរួចហើយក៏ដោយ ក៏គេសង្កេតឃើញថាភាគីចិនពុំបានចូលរួមក្នុងនីតិវិធីណាមួយនៃតុលាការនេះទេ ក៏មិនទទួលស្គាល់យុត្តាធិការរបស់តុលាការនេះដែរ។[123] ប៉ុន្តែទោះបីជាយ៉ាងនេះក៏ដោយ ក៏នៅមានមធ្យោបាយច្បាប់ និងផ្លូវតុលាការផ្សេងទៀតដែលគូភាគីអាចជ្រើសរើសផងដែរតួយ៉ាងតាមរយៈ តុលាការអន្តរជាតិនីតិសមុទ្រ តុលាការយុត្តិធម៌អន្តរជាតិ ឬការជ្រើសមជ្ឈត្តការដោយខ្លួនឯងក្តី សុទ្ធសឹងជាមធ្យោបាយដែលភាគីអាចជ្រើសរើស និងស្របតាមស្មារតីនៃច្បាប់អន្តរជាតិក្នុងការមិនប្រើប្រាស់កម្លាំងក្នុងការដោះស្រាយបញ្ហា (Non-use of force in dispute settlement)។

**កថាខណ្ឌទី១ តុលាការអន្តរជាតិនីតិសមុទ្រ** The International Tribunal for the Law of the Sea ( ITLOS )

[121] Article 74(3) and 83(3), UNCLOS

[122] Qi H., (2019)., Joint development in the South China sea: China's incentives and policy choices; https://www.tandfonline.com/doi/full/10.1080/24761028.2019.1685427

[123] Statement of the Ministry of Foreign Affairs of the People's Republic of China on the Award of 12 July 2016 of the Arbitral Tribunal in the South China Sea Arbitration Established at the Request of the Republic of the Philippines; https://www.fmprc.gov.cn/eng/wjdt_665385/2649_665393/201607/t20160712_679470.html

តុលាការអន្តរជាតិសមុទ្រដែលបានចាប់កំណើតដំបូង ក្នុងឆ្នាំ១៩៩៧[124] ដែលដំបូងឡើយផ្តោតលើការដោះស្រាយជម្លោះបាតសមុទ្រ ធនធានធម្មជាតិ និងបរិស្ថានសមុទ្រ[125] និងដែលជាតុលាការដែលមានចៅក្រមអចិន្ត្រៃយ៍រហូត២១រូបនេះ ជាអង្គភាពយុត្តិធម៌អន្តរជាតិថ្មីថ្មោង និងមិនទាន់មានបទពិសោធន៍ច្រើននៅឡើយទេក្នុងការដោះស្រាយជម្លោះដែលពាក់ព័ន្ធដល់ការកំណត់ព្រំដែនសមុទ្រ។ សកម្មភាពទូទៅ និងដែលកើតឡើងជារឿយៗរបស់តុលាការនេះ គឺការស្នើសុំនូវវិធានការបណ្តោះអាសន្ន (Provisional Measures) របស់រដ្ឋក្នុងបរិបទដែលមានការឃាត់នាវា ឬសមាជិកនាវិកនាវាពីសំណាក់រដ្ឋមួយទៀតស្របតាមស្មារតីដែលមានចែងក្នុងមាត្រា ២៩២ នៃអនុសញ្ញាស្តីពីនីតិសមុទ្រប៉ុណ្ណោះ។[126] ទោះជាបែបនេះក៏ដោយ ក៏គេនៅចាំបានថាសាលដីកាសម្រេចក្តីដំបូងមួយទៅលើការកំណត់ព្រំដែនសមុទ្ររវាងមីយ៉ាន់ម៉ា និងបង់ក្លាដេសនៅឈូងសមុទ្រ Bangal (Bay of Bangel) បានប្រកាសចេញដោយដោយតុលាការនេះកាលពីឆ្នាំ២០១២។[127] សាលដីកានេះត្រូវបានគេទទួលស្គាល់ជាអន្តរជាតិ និងត្រូវបានគេចាត់ទុកថាជាសេចក្តីសម្រេចលើកដំបូងគេមួយក្នុងប្រវត្តិសាស្ត្រកំណត់ព្រំដែនសមុទ្រ ដែលតុលាការនេះចេញសេចក្តីសម្រេច និងរកឃើញថា ខ្លួនមានយុត្តាធិការគ្រប់គ្រាន់ក្នុងការចេញសេចក្តីសម្រេចលើជម្លោះកំណត់ព្រំដែនបាតសមុទ្រដែលមានចម្ងាយលាតសន្ធឹងហួសពី ២០០ ណូទីខលម៉ាលយ៍ (Nautical Mile) ពីខ្សែរបន្ទាត់មូលដ្ឋាន (Baseline) ។[128] ក្រៅពីនេះ ម៉ាឡេស៊ី និង សិង្ហបុរី ក៏ជាប្រទេសអាស៊ានពីរទៀតដែរដែលបានស្នើសុំអន្តរាគមន៍ពីតុលាការនេះដោយព្រមព្រៀងគ្នាប្តឹងទៅតុលាការនេះក្នុងកម្មវត្ថុស្នើសុំនូវវិធានការណ៍បណ្តោះអាសន្នទាក់ទិននឹងការចាក់ដីពង្រីកឆ្នេរនៅជុំវិញច្រកសមុទ្រ0 Johor ធ្វើឡើងដោយសិង្ហបុរីក្នុងឆ្នាំ២០០៣[129]។

ផ្អែកលើបទពិសោធន៍មួយចំនួន ពិសេសបទពិសោធន៍មកលើប្រទេសដែលជាសមាជិកអាស៊ាន ដូចហ្វីលីពីនផងដែរនេះ តុលាការអន្តរជាតិនីតិសមុទ្រអាចជាជម្រើសមួយសម្រាប់ចិន និងហ្វីលីពីនក្នុងការជ្រើសជាមធ្យោបាយដោះស្រាយជម្លោះតាមផ្លូវច្បាប់ ដ្បិតបើយើងក្រលេកទៅមើលក្ខខណ្ឌនៃការបើកផ្លូវបណ្តឹង ប្រទេស

[124] Rosenne, S. (1995). Establishing the International Tribunal for the Law of the Sea. The American Journal of International Law, 89(4), 806–814. https://doi.org/10.2307/2203941

[125] https://www.itlos.org/en/main/the-tribunal/history/

[126] Article 292, UNCLOS

[127] Delimitation of the maritime boundary in the Bay of Bengal (Bangladesh/Myanmar), Judgment, ITLOS Reports 2012

[128] Delimitation of the maritime boundary in the Bay of Bengal (Bangladesh/Myanmar), Judgment, ITLOS, para. 363

[129] Land Reclamation in and around the Straits of Johor (Malaysia v. Singapore), Provisional Measures, Order of 8 October 2003, ITLOS Reports 2003

ទាំងពីរសុទ្ធតែជាភាគីហត្ថលេខីនៃអនុសញ្ញាសហប្រជាជាតិស្តីពីនីតិសមុទ្រ (UNCLOS) ប៉ុន្តែប្រទេសទាំងពីពុំបានបំពេញលក្ខខណ្ឌគ្រប់ ដោយពុំបានធ្វើសេចក្តីថ្លែងការណ៍ទទួលស្គាល់យុត្តាធិការនៃតុលាការនេះដូចមានចែងក្នុងមាត្រា២៨៧ នៃអនុសញ្ញានោះទេ[130] ដូចនេះតុលាការនេះពុំមានសមត្ថកិច្ច ឬដែនយុត្តាធិការគ្រប់គ្រាន់ក្នុងការដោះស្រាយជម្លោះនេះទេ លុះត្រាណាតែមានកិច្ចព្រមព្រៀងពិសេសណាមួយរវាងគូភាគីព្រមទទួលស្គាល់យុត្តាធិការនិងបើកផ្លូវបណ្តឹង ឬតាមរយៈវិធាន Forum Porogatum (ការពង្រីកដែនយុត្តាធិការរបស់តុលាការតាមរយៈកិច្ចព្រមព្រៀងព្រមទទួលស្គាល់របស់គូភាគីក្នុងជម្លោះ "*The extension of the jurisdiction of a court by agreement of the parties in a case which would otherwise be outside the court's jurisdiction.*")[131]។

ទោះជាយ៉ាងនេះក្តីក៏តុលាការនេះនៅតែជាជម្រើសមួយល្អជាង អនុសញ្ញានៃនីតិសមុទ្រ និងលក្ខន្តិកៈនៃតុលាការនេះបានផ្តល់ភាពងាយស្រួល និងជម្រើសច្រើនដែលគូភាគីអាចជ្រើសរើសក្នុងការដំណើរការនីតិវិធីនៃរឿងក្តីរបស់ពួកគេ ជាក់ស្តែងក្នុងមាត្រា១៥ នៃលក្ខន្តិកៈរបស់តុលាការនេះបានអនុញ្ញាតឱ្យគូភាគីអាចជ្រើសរើសប្រើប្រាស់នីតិវិធីក្នុងការបង្កើតសាលាជម្រះក្តីពិសេស(Special Chambers)[132] ទៅតាមការស្នើសុំឆ្លើយតបតាមតម្រូវការនានារបស់គូភាគី និងដែលមានចំនួនចៅក្រមកំរិតរិតត្បិតប្រៀបទៅនឹងអង្គជំនុំជម្រះទូទៅ ដែលមានចៅក្រមអចិន្ត្រៃយ៍រហូត ២១រូប។

**កថាខណ្ឌទី២ តុលាការយុត្តិធម៌អន្តរជាតិ** ( International Court of Justice – ICJ )

តុលាការយុត្តិធម៌អន្តរជាតិ ឬ ICJ ជាស្ថាប័នយុត្តិធម៌ និងជាសាលាជម្រះមួយដ៏មានឥទ្ធិពល និងមានកេរ្តិ៍ឈ្មោះល្បីល្បាញ ក៏ដូចជាមានបទពិសោធន៍ជ្រៅជ្រះក្នុងការដោះស្រាយវិវាទ និងជម្លោះអធិបតេយ្យរវាងរដ្ឋនឹងរដ្ឋ។ ក្រៅតែពីអធិបតេយ្យដែនដីគោក យុត្តិសាស្ត្រនានាដែលដាក់ចេញដោយតុលាការនេះក៏បានជះឥទ្ធិពលក្នុងការបង្កើត និងអភិវឌ្ឍន៍ឡើងនូវអ្វីដែលយើងស្គាល់ថាជាវិធាន និងមូលដ្ឋានគ្រឹះនានាក្នុងការកំណត់អធិបតេយ្យ ឬព្រំដែនសមុទ្រផងដែរ។ លើសពីនេះស្ថាប័នតុលាការអន្តរជាតិកំពូលមួយនេះធ្លាប់បានប្រើប្រាស់យកមកដោះស្រាយជម្លោះនៅតំបន់ អាស៊ី ពិសេសដោយសមាជិកអាស៊ានជាច្រើនដងរួចមកហើយជាក់ស្តែងរួមមាន៖

---

[130] Article 287, UNCLOS

[131] YEE, S. (2003). Forum Prorogatum Returns to the International Court of Justice. Leiden Journal ofInternational Law, 16(4), 701-713. doi:10.1017/S0922156503001390

[132] Article 15, ITLOS Statute

- ជម្លោះរវាងកម្ពុជា និងថៃពាក់ព័ន្ធនឹងអាធិបតេយ្យលើប្រាសាទព្រះវិហារ[133] រួមទាំងការប្ដឹងស្នើសុំបកស្រាយសាលដីកាឆ្នាំ១៩៦២ ធ្វើឡើងដោយកម្ពុជាក្នុងឆ្នាំ២០១១ ផងដែរ[134]។
- ជម្លោះរវាងសិង្ហបុរី និងម៉ាឡេស៊ី ពាក់ព័ន្ធនឹងអធិបតេយ្យដែនកោះ Pedra Branca/Pulau Batu Puteh, Middle Rocks និង South Ledge តាមបណ្ដឹងទ្វេភាគីរបស់ភាគីជម្លោះក្នុងឆ្នាំ ២០០៣។[135]

ទោះជាយ៉ាងនេះក្ដី បើយើងក្រលេកមកមើកក្នុងបរិបទជម្លោះរវាងចិន និងហ្វីលីពីនវិញត្បិតថាភាគីទាំងពីរសុទ្ធសឹងជាសមាជិកនៃអង្គការសហប្រជាជាតិ ដែលបំពេញឱ្យលក្ខខណ្ឌមួយក្នុងក្នុងចំណោមលក្ខខណ្ឌដទៃទៀតក្នុងការអនុញ្ញាតឱ្យបណ្ដឹងទៅតុលាការនេះអាចធ្វើឡើងបានក្ដី ក៏នៅមានបញ្ហាមួយចំនួនទៀតដែលរារាំងដល់យន្តការនេះពិសេសរារាំងដល់ការប្ដឹងជាឯកតោភាគីទៅនឹងជម្លោះ ដូចអ្វីដែលកម្ពុជាធ្លាប់បានធ្វើ។ បញ្ហាគោលចំបងនោះគឺទោះបីជាហ្វីលីពីនបានទទួលស្គាល់នូវយុត្តាធិការរបស់តុលាការកំពូលនេះ តាមរយៈសេចក្ដីប្រកាសឯកតោភាគីរបស់ខ្លួនក្នុង ខែមករា ឆ្នាំ១៩៧២[136] ក្ដី ក៏នៅតែមកដល់ពេលនេះ ចិន មិនដែលទទួលស្គាល់យុត្តាធិការរបស់តុលាការកំពូលនេះឡើយ[137] នោះក៏មានន័យថាតុលាការយុត្តិធម៌អន្តរជាតិពុំមានសមត្ថកិច្ចក្នុងការដោះស្រាយជម្លោះរវាងប្រទេសទាំងពីរជុំវិញអធិបតេយ្យដែនកោះ និងព្រំដែនសមុទ្រចិនខាងត្បូងនោះទេ។ គួគួសបញ្ជាក់ផងដែរមិនមែនចិនតែឯងនោះទេដែលមិនទទួលស្គាល់យុត្តាធិការរបស់តុលាការនេះនោះទេ ដោយក្នុងចំណោមសមាជិកអចិន្ត្រៃយ៍ទាំង៥នៃក្រុមប្រឹក្សាសន្តិសុខ (P5) មានតែចក្រភពអង់គ្លេសប៉ុណ្ណោះដែលទទួលយកផ្នែកខ្លះ ក្រៅពីនោះសុទ្ធតែមិនទទួលស្គាល់យុត្តាធិការរបស់តុលាការអន្តរជាតិ ICJ។[138]

រួមមកប្រសិនបើហ្វីលីពីនចង់ប្រើប្រាស់មធ្យោបាយតុលាការនេះ គឺតម្រូវដាច់ខាតឱ្យមានការយល់ព្រមពីសំណាក់ភាគីចិនទើបតុលាការនេះមានសម្ថកិច្ចគ្រប់គ្រាន់ក្នុងការទទួលពិនិត្យ និងវិនិច្ឆ័យលើជម្លោះនេះ ប៉ុន្តែបើ

---

[133] Case Concerning the Temple of Preah Vihear Cambodia/Thailand (Judgement) [1962] https://www.icjcij.org/sites/default/files/case-related/45/045-19620615-JUD-01-00-EN.pdf

[134] Case Concerning the Request for Interpretation of The Judgement of 15 June 1962 in The Case Concerning the Temple of Preah Vihear (Response to Cambodia) [2012] ICJ Rep. Vol. 1 https://www.icj-cij.org/sites/default/files/case-related/151/17288.pdf

[135] Case Concerning Sovereignty over Pedra Branca/Pulau Batu Puteh, Middle Rocks and South Ledge Malaysia/Singapore (Judgement) [2008]

[136] Declarations recognizing the jurisdiction of the Court as compulsory - Philippines (ICJ) https://www.icj-cij.org/declarations/ph

[137] Harriet Moynihan International Law Programme, *China's Evolving Approach to International Dispute Settlement* (2017), p. 2

[138] Harriet Moynihan International Law Programme, *China's Evolving Approach to International Dispute Settlement* (2017), p. 2

មើលឱ្យជាក់ស្តែងទៅ វាជារឿងពិបាកទៅរួចមួយដែលភាគីចិនសុខចិត្តព្រមទទួលយកយុត្តាធិការរបស់តុលាការនេះតាមរូបភាព ឬវិធានណាក្តីដ្បិតចិនហាក់មិនចង់ប្រើប្រាស់យន្តការនេះឡើយ ហើយក៏តែងប្រកាសជារឿយៗពីការប្រឆាំងទៅលើយុត្តាធិការនៃសេចក្តីសម្រេចនានារបស់មជ្ឈិតការ ឬអង្គការផ្សេងទៀតផងដែរ។

**កថាខណ្ឌទី៣ តុលាការមជ្ឈតការទូទៅ** ( General Arbitration )

ជម្រើសការដោះស្រាយតាមបែបមជ្ឈតការនេះ ជាទូទៅត្រូវបានពេញនិយមលើឆាកអន្តរជាតិ ដ្បិតគូភាគីអាចជ្រើសរើសនូវមជ្ឈតករ (អ្នកសម្រេចក្តី) រួមទាំងនីតិវិធីផ្សេងៗទាំងការរៀបចំដំណើរការ រួមទាំងនីតិវិធីច្បាប់ដែលនឹងលើកយកមកធ្វើជាគោលសម្រាប់ការស្វែងរកដំណោះស្រាយផង។ ទាំងនេះស្តែងឡើងនូវលក្ខណៈបត់បែន និងមានភាពងាយស្រួលដោយផ្តល់ជម្រើសច្រើនដល់គូភាគីក្នុងរឿងក្តី។ យ៉ាងណាមិញតុលាការនេះ ក៏អាចដោះស្រាយបាននូវជម្លោះភាគច្រើនដែលកគ្របដណ្តប់ក្រោមឆ័ត្រនៃច្បាប់អន្តរជាតិ រួមទាំងការដោះស្រាយលើបញ្ហាទំនាស់ទឹកដីឬដែនអធិបតេយ្យ និងជម្លោះលើការកំណត់ព្រំដែនសមុទ្រផងដែរដែលជាកម្មវត្ថុចម្បងក្នុងអ្វីដែលយើងកំពុងសិក្សានេះផងដែរ។ ទោះបីជាមានភាពងាយស្រួល និងលឿនរហ័សជាងមធ្យោបាយឬយន្តការតុលាការផ្សេងៗក្តី ក៏ជារឿយៗយើងសង្កេតឃើញសេក្តីថ្លែងការណ៍របស់ក្រសួងការបរទេសចិនចេញមកជំទាស់នឹងមធ្យោបាយតុលាការមជ្ឈតការទូទៅនេះ និងហាក់សម្តែងការមិនពេញចិត្តក្នុងការជ្រើសរើសយកមធ្យោបាយនេះមកធ្វើជាយន្តការដោះស្រាយជម្លោះ ដែលផ្ទុយពីគោលជំហរជារឿយៗរបស់ហ្វីលីពីនដែលហាក់ពេញចិត្តនឹងការដោះស្រាយតាមបែបមជ្ឈតការទូទៅនេះ។ នេះជាបញ្ហាគោលចម្បងក្នុងដំណើរជ្រើសរើសមជ្ឈត្តការទូទៅជាយន្តការដោះស្រាយបញ្ហា ដោយសារជាចម្បងភាគីទាំងពីត្រូវធ្វើកិច្ចព្រមព្រៀងបើលផ្លូវបណ្តឹង (Arbitration Agreement) សិនដើម្បីជ្រើសតាំងមជ្ឈតករ និងប្រគល់សម្តកិច្ចឱ្យតុលាការមជ្ឈតការនោះអាចមានសិទ្ធិសម្រេចលើបណ្តឹង និងជម្លោះរបស់គូភាគីបាន។

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

សរុបរួមមក ជម្លោះដែនអធិបតេយ្យនៅសមុទ្រចិនខាងត្បូងរវាងចិន និងហ្វីលីពីន គឺជាជម្លោះមួយដ៏ស្មុគស្មាញ និងសាំញ៉ាំ។ ក្រៅតែពីពាក់ព័ន្ធពីប្រវត្តិសាស្ត្រ និងបញ្ហាច្បាប់ហើយនោះ ជម្លោះនេះក៏មាននូវចរិតជាលក្ខណៈនយោបាយផងដែរ ដ្បិតដែនទឹកមានជម្លោះនេះគឺមានផ្ទុកទៅធនធានធម្មជាតិដ៏ច្រើន និងក៏ជាដែនយុទ្ធសាស្ត្រសម្រាប់ការពារសន្តិសុខមួយផងដែរ ដ្បិតទំនិញជាច្រើនពាន់លានដុល្លាក្នុងមួយឆ្នាំៗត្រូវបានដឹកឆ្លងកាត់តំបន់នេះ។ សម្រាប់ចិន តំបន់នេះជាតំបន់យុទ្ធសាស្ត្រដ៏សំខាន់សម្រាប់មហិច្ឆតាក្លាយជាមហាអំណាចពិភពលោករបស់ខ្លួន ឯហ្វីលីពីនវិញតំបន់នេះជាតំបន់ដ៏សំខាន់សម្រាប់សេដ្ឋកិច្ច និងកិច្ចការពារសន្តិសុខជាតិរបស់រដ្ឋាភិបាលទីក្រុងម៉ានីល។ មូលហេតុទាំងនេះបន្ថែមលើភាពមិនអាចអនុវត្តដោយបង្ខំបាននូវសេចក្តីសម្រេចរបស់តុលាការអន្តរជាតិ និងភាពផុយស្រួយនៃច្បាប់អន្តរជាតិដោយកង្វះកិច្ចសហប្រតិបត្តិការអន្តរជាតិទៀតនោះ បានធ្វើឱ្យជម្លោះនេះហាក់មានភាពស្មុគស្មាញ និងពុំអាចរកដំណោះស្រាយបាន។

ការលូកដៃ និងការប្រណាំងប្រជែងភូមិសាស្ត្រនយោបាយរវាងប្រទេសជាភាគី និងមិនមែនភាគីជម្លោះ និងកង្វះឆន្ទៈរួមក្នុងការដោះស្រាយវិបត្តិនេះក៏ជារនាំងឧបសគ្គមួយជាន់ទៀតដល់ការរកដំណោះស្រាយផងដែរ។ យើងតែងសង្កេតឃើញម្តងហើយម្តងទៀតថានៅពេលផលប្រយោជន៍ជាតិរបស់ប្រទេសមួយ ពិសេសពួកប្រទេសមហាអំណាច ឬដែលមានធនធានច្រើនត្រូវបានប៉ះពាល់ នោះគោលការណ៍ និងយន្តការច្បាប់អន្តរជាតិនឹងត្រូវពួកគេមើលរំលង និងមិនគោរពតាមឡើយជាក់ស្តែងក្រៅតែពីរឿងសមុទ្រចិនខាងត្បូងហើយ វិបត្តិរុស្សី និងអ៊ុយក្រែនក៏ជាឧទាហរណ៍មួយថ្មីទៀតពីការមិនគោលរពគោលការណ៍ច្បាប់អន្តរជាតិ។ ក្រៅពីនេះកង្វះឆន្ទៈរួម ដែលនៅត្រង់នេះយើងឃើញថាចិន ចង់ប្រើប្រាស់យន្តការចរចាទ្វេភាគីច្រើនជាងយន្តការច្បាប់ ឯហ្វីលីពីនដែលជាប្រទេសមានអនុភាពមិនសមប្រកបដូចចិន ចង់ជ្រើសយកយន្តការច្បាប់ ឬយន្តការពហុភាគីផ្សេងទៀតដើម្បីខ្លួនមានភាពកក់ក្តៅក្នុងការបញ្ចប់ជម្លោះដោយសមស្រប។ ការមិនអាចស្វែងរកឆន្ទៈរួមនេះហើយដែលជាបញ្ហាគោលក្នុងការស្វែងរកច្រកចេញពីជម្លោះ។

ត្រលប់មកវិញ ក្នុងករណីជម្លោះនេះ ប្រសិនបើគូភាគីពិតជាចង់បញ្ចប់ជម្លោះមែននោះលក្ខខណ្ឌមួយចំនួនគឺត្រូវតែសម្រេចឱ្យ ទី១ គឺការមិនប្រើប្រាស់កម្លាំងដោះស្រាយបញ្ហាដែលជាស្មារតីមួយមានចែងក្នុងក្របខណ្ឌធម្មនុញ្ញនៃអង្គការសហប្រជាជាតិផងដែរ ឯទី២ គឺត្រូវសម្រេចឱ្យបាននូវឆន្ទៈរួមក្នុងការដោះស្រាយជម្លោះ។ ក្នុងបរិបទនេះ ចិនដែលមើលឃើញថាតាមរយៈសេចក្តីសម្រេចរបស់តុលាការមជ្ឈត្តការពិសេស ខ្លួនហាក់មានការខាតបង់ប្រយោជន៍ច្រើនបើប្រៀបទៅនឹង ភាគីហ្វីលីពីន បានប្រកាសមិនទទួលស្គាល់នូវសេចក្តីសម្រេចនេះទេ។ ដូច្នេះគូភាគីទាំងពីរត្រូវស្វែងរកឱ្យបាននូវឆន្ទៈ និងដំណោះស្រាយរួមមួយ។ ដំណោះស្រាយមួយដែលអាចនឹងក្លាយជាជម្រើសល្អនោះគឺការបង្កើតតំបន់អភិវឌ្ឍន៍រួម និងបង្កើនកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរវាងចិន និង

ហ្វីលីពីន។ ធ្វើបែបនេះក្រៅតែពីអាចកាត់បន្ថយភាពតានតឹងនៃជម្លោះ និងបង្កើនកិច្ចសហប្រតិបត្តការរវាងគ្នានឹងគ្នាហើយ ភាគីទាំងពីរក៏អាចនឹងរកផលចំណេញបានកាន់តែច្រើនពីធនធានមហាសាលក្នុងតំបន់ទឹកមានជម្លោះនេះដូចជាផលនេសាទ រ៉ែប្រេង និងឧស្ម័នជាដើមផងដែរ។ ក្រៅពីនេះប្រសិនបើសម្រេចទៅបាន យន្តការនេះនឹងអាចជះឥទ្ធិពលដល់គូភាគីចជម្លោះផ្សេងទៀតក្នុងការប្រើប្រាស់យន្តការស្រដៀងគ្នានេះដែ ហើយវាក៏នឹងជាគំរូល្អស្របទៅនឹងស្មារតីច្បាប់អន្តរជាតិផងដែរ។ បន្ថែមពីនេះចិនអាចប្រើប្រាស់យន្តការច្បាប់ដើម្បីបដិសេដនឹងសេចក្តីសម្រេចរបស់តុលាការមជ្ឈត្តការពិសេសផងដែរដើម្បីបង្ហាញពីឆន្ទៈគោរពច្បាប់អន្តរជាតិ និងជាគំរូល្អប្រសិនបើចង់ប្រជែងតំណែងជាមហាអំណាចសកលមួយដែលប្រទេសដទៃគួរយកគម្រូតាម។ ក្នុងន័យនេះចិនអាចប្តឹងទៅតុលាការយុត្តិធម៌អន្តរជាតិ ICJ ដើម្បីសុំមោឃភាពសេចក្តីសម្រេចរបស់តុលាការមជ្ឈត្តការនោះដោយមូលហេតុមិនត្រឹមត្រូវនៃនីតិវិធី ឬការរំលោភអំណាចមជ្ឈត្តការជាដើមដូចរឿងក្តីរវាង GUINEA-BISSAU ទល់នឹង SENEGAL ដើម្បីមោឃសេចក្តីសម្រេចរបស់មជ្ឈត្តការក្នុងឆ្នាំ ១៩៨៩។[139]

ជារួមគូភាគីជម្លោះត្រូវតែរក្សាឱ្យបាននូវការមិនប្រើប្រាស់កម្លាំងទ័ព ក្នុងការដោះស្រាយជម្លោះនេះ ហើយក្រៅតែពីគិតគូពីផលប្រយោជន៍ជាតិរៀងខ្លួនហើយ ស្មារតីក្នុងការគោរពច្បាប់ និងកិច្ចសហប្រតិបត្តិការអន្តរជាតិត្រូវតែបានគោរព និងលើកស្ទួយក្នុងន័យលើកកំពស់សាកលភាវូបនីយកម្ម សណ្តាប់ធ្នាប់ ស្ថិរភាព និងកិច្ចសហប្រតិបត្តិការស្របតាមច្បាប់អន្តរជាតិ៕

[139] CASE CONCERNING THE ARBITRAL AWARD OF 31 JULY 1989; https://www.icj-cij.org/sites/default/files/case-related/82/082-19911112-JUD-01-00-EN.pdf

# ឯកសារយោង

## ឯកសារច្បាប់/លិខិតបទដ្ឋានគតិយុត្ត

- United Nations Charter
- United Nation Convention on Law of the Sea
- ASEAN Charter
- Statute of the International Tribunal for the Law of the Sea
- Statute of the International Court of Justice

## សៀវភៅ

- ទំនាក់ទំនងអន្តរជាតិ
- ព្រឹត្តិបត្រច្បាប់សាលាត្រាជូ
- មជ្ឈត្តការអន្តរជាតិ

## ឯកសារអន្តរជាតិ

- H.E. CONG Peiwu, Ambassador of People's Republic of China in Canada, The History and Reality of the South China Sea Issue, 2020 http://ca.china-embassy.gov.cn/eng/sgxw/202009/t20200913_4615002.htm
- Cairo Declaration, 1943, https://www.ndl.go.jp/constitution/e/shiryo/01/002_46shoshi.html
- Potsdam Declaration, 1945, https://www.atomicarchive.com/resources/documents/hiroshima-nagasaki/potsdam.html
- Peace Treaties after World War II: Peace treaty signed in San Francisco, September 8, 1951.
- Khoury, E. (2017). ‶Recent trends in the South China Sea disputes″, Asia Focus#16 – Asia Programme, Insititut de relations internationales et stratégiques.
- Damn, M.J. (2020). Introduction to South China Sea military capability studies, South China Sea military capability series, July, 2020.
- ‶Territorial Disputes in the South China Sea″, Council on Foreign Relations, 2021, https://www.cfr.org/global-conflict-tracker/conflict/territorial-disputes-south-china-sea.

- Wang, K.H. (2015). ‶Peaceful settlement of disputes in the South China Sea through fisheries resources cooperation and management″, Maryland series in Contemporary Asian Studies: Vol.2015: No. 3, Article 1
- Storey, I. (2014). ‶Discordes en Mer de Chine Méridionale : Les Eaux Troubles du Sud-Est Asiatique″, Institut français des relations internationales, 2014/3 Automne, pages 34 à 47.
- Roche, Y. (2013). ‶La Mer de Chine Méridionale : un Jeu Frontalier Majeur en Asie du Sud-Est″, OpenEdition Journals, L´Espace Politique, 21/2013-3
- Sakamoto, S. (2021). ‶The global South China Sea issue″, The Diplomat, July 04, 2021, https://thediplomat.com/2021/07/the-global-south-china-sea-issue/
- Ministry of Foreign Affairs of the People´s Republic of China Adheres to the Position of Setting Through Negotiation the Relevant Disputes Between China and the Philippines in the South China Sea, (13,Juy, 2016) < https://www.fmprc.gov.cn/nanhai/eng/snhwtlcwj_1/201607/t20160713_8527301.htm >
- Matsuzawa, M. (2019, March 21). How The Hague Court ruled on the Philippines´s 15 arguments<https://www.philstar.com/news-commentary/2016/07/13/1602470/how-hague-court-ruled-philippiness-15-arguments>
- Statement of the Ministry of Foreign Affairs of the People's Republic of China on the Award of 12 July 2016 https://www.fmprc.gov.cn/eng/wjdt_665385/2649_665393/201607/t20160712_679470.html
- 1976 Philippines Discovers Oil Field https://www.cfr.org/timeline/chinas-maritime-disputes
- Statement of the Ministry of Foreign Affairs of the People's Republic of China on Settling Disputes Between China and the Philippines in the South China Sea Through Bilateral Negotiation https://www.fmprc.gov.cn/eng/wjdt_665385/2649_665393/201606/t20160608_679464.html
- Joint Statement Between China and the Philippines on the Framework of Bilateral Cooperation in the Twenty-First Century

https://www.fmprc.gov.cn/eng/wjdt_665385/2649_665393/200011/t20001115_678991.html

- Declaration on The Conduct of Parties in The South China Sea https://asean.org/declaration-on-the-conduct-of-parties-in-the-south-china-sea-2/
- Thao, Nguyen. (2003). The 2002 Declaration on the Conduct of Parties in the South China Sea: A Note. Ocean Development and International Law - OCEAN DEV INT LAW. 34. 279-285. p 281
- Liu, F. (2016). *South China Sea Lawfare: Legal Perspectives and International Responses to the Philippines v. China Arbitration Case* (J. Spangler, Ed.).
- PCA-UNCLOS Annex VII cases arbitrated under the auspices of the PCA. https://pca-cpa.org/en/services/arbitration-services/unclos/
- Status of the United Nations Convention on the Law of the Sea, of the Agreement relating to the Implementation of Part XI of the Convention and of the Agreement for the Implementation of the Provisions of the Convention relating to the Conservation and Management of Straddling Fish Stocks and Highly Migratory Fish Stocks as at 27 June 2019 - status2019.pdf (un.org)
- UNCLOS, Declarations and Statements - Declarations or Statements upon UNCLOS ratification.pdf (marineregions.org)
- DFA: Notification and Statement of Claim On West Philippine Sea: Notification and Statement of Claim On West Philippine Sea | PDF (scribd.com)
- ARBITRATION 101: PHILIPPINES V. CHINA: Arbitration 101: Philippines v. China | Asia Maritime Transparency Initiative (csis.org)
- Former Judge in South China Sea Arbitration Case Discusses New Challenges to Philippine Maritime Security. https://fsi.gov.ph/2022/01/04/former-judge-in-south-china-sea-arbitration-case-discusses-new-challenges-to-philippine-maritime-security/
- The PCA provides administrative support in international arbitrations: https://pca-cpa.org/en/services/arbitration-services/
- NEW ARBITRATOR AND PRESIDENT APPOINTED IN THE ARBITRAL PROCEEDINGS INSTITUTED BY THE REPUBLIC OF THE PHILIPPINES AGAINST

THE PEOPLE´S REPUBLIC OF CHINA: https://www.itlos.org/fileadmin/itlos/documents/press_releases_english/PR_197_E.pdf

- Preliminary Objections of the Government of Thailand; https://www.icj-cij.org/node/104467
- CASE CONCERNING THE TEMPLE OF PREAH VIHEAR: JUDGMENT OF 15 JUNE 1962; https://www.icj-cij.org/public/files/case-related/45/045-19620615-JUD-01-00-EN.pdf
- Declarations made by States Parties under article 298; https://www.itlos.org/en/main/jurisdiction/declarations-of-states-parties/declarations-made-by-states-parties-under-article-298/
- Position Paper of the Government of the People's Republic of China on the Matter of Jurisdiction in the South China Sea Arbitration Initiated by the Republic of the Philippines; https://www.fmprc.gov.cn/eng/wjdt_665385/2649_665393/201412/t20141207_679387.html
- The South China Sea Arbitration Award of 12 July 2016, https://docs.pca-cpa.org/2016/07/PH-CN-20160712-Award.pdf
- AWARD ON JURISDICTION AND ADMISSIBILITY, https://pcacases.com/web/sendAttach/2579
- AN ARBITRAL TRIBUNAL CONSTITUTED UNDER ANNEX VII TO THE 1982 UNITED NATIONS CONVENTION ON THE LAW OF THE SEA; https://www.pcacases.com/web/sendAttach/233
- Draft articles on Responsibility of States for Internationally Wrongful Acts, with commentaries; https://legal.un.org/ilc/texts/instruments/english/commentaries/9_6_2001.pdf
- Mutlaq Majed Al-Qahtani, (2003). ENFORCEMENT OF INTERNATIONAL JUDICIAL DECISIONS OF THE INTERNATIONAL COURT OF JUSTICE IN PUBLIC INTERNATIONAL LAW; https://theses.gla.ac.uk/2487/1/2003Al-QahtaniPhD.pdf
- U.S. Vetoes Nicaraguan Resolution On Compliance With Court Decision; https://washingtonpost.com/archive/politics/1986/08/01/us-vetoes-nicaraguan-

resolution-on-compliance-with-court-decision/ecdf20d6-cf3a-4761-ba23-5c49a9fa379a/

- China neither accepts nor recognizes so-called award on South China Sea arbitration http://english.scio.gov.cn/pressroom/2023-07/13/content_92131216.htm
- South China Sea: The Positions and the Facts https://www.crisisgroup.org/asia/south-east-asia/south-china-sea/south-china-sea-positions-and-facts
- Philippines reveals locations of 4 new strategic sites for U.S. military pact https://www.reuters.com/world/asia-pacific/philippines-reveals-locations-4-new-strategic-sites-us-military-pact-2023-04-03/
- Carrier USS Ronald Reagan Now in the South China Sea; https://news.usni.org/2023/06/19/carrier-uss-ronald-reagan-now-in-the-south-china-sea
- ASEAN must prevent ˋexternal interferenceˊ in South China Sea row https://www.phnompenhpost.com/international/asean-must-prevent-external-interference-south-china-sea-row
- US carrier strike group begins operating in South China Sea as tensions with China simmer; https://edition.cnn.com/2023/01/13/politics/us-strike-group-south-china-sea/index.html
- Qi H., (2019)., Joint development in the South China sea: Chinaˊs incentives and policy choices; https://www.tandfonline.com/doi/full/10.1080/24761028.2019.1685427
- Rosenne, S. (1995). Establishing the International Tribunal for the Law of the Sea. The American Journal of International Law, 89(4), 806–814. https://doi.org/10.2307/2203941
- Delimitation of the maritime boundary in the Bay of Bengal (Bangladesh/Myanmar), Judgment, ITLOS Reports 2012
- Land Reclamation in and around the Straits of Johor (Malaysia v. Singapore), Provisional Measures, Order of 8 October 2003, ITLOS Reports 2003
- Case Concerning the Temple of Preah Vihear Cambodia/Thailand (Judgement) [1962] https://www.icjcij.org/sites/default/files/case-related/45/045-19620615-JUD-01-00-EN.pdf

- Case Concerning the Request for Interpretation of The Judgement of 15 June 1962 in The Case Concerning the Temple of Preah Vihear (Response to Cambodia) [2012] ICJ Rep. Vol. 1 https://www.icj-cij.org/sites/default/files/case-related/151/17288.pdf
- Declarations recognizing the jurisdiction of the Court as compulsory - Philippines (ICJ) https://www.icj-cij.org/declarations/ph
- Harriet Moynihan International Law Programme, *China's Evolving Approach to International Dispute Settlement* (2017),


**គេហទំព័រ**


https://www.fmprc.gov.cn/nanhai/eng/snhwtlcwj_1/201607/t20160713_8527301.htm

https://behorizon.org/the-conflict-in-the-south-china-sea-a-focus-on-a-possible-solution/

https://www.lawfaremedia.org/article/south-china-sea-dispute-brief-history

https://maritime-executive.com/editorials/historical-support-for-china-s-south-china-sea-territorial-stance-1

https://theprint.in/theprint-essential/what-is-nine-dash-line-the-basis-of-chinas-claim-to-sovereignty-over-south-china-sea/469403/

https://jusmundi.com/en/document/publication/en-competence-competence

https://www.nationsonline.org/oneworld/map/South-China-Sea-political-map.htm

https://www.documentcloud.org/documents/2165477-phl-prc-notification-and-statement-of-claim-on

https://www.businessinsider.com/no-nine-dash-line-in-the-south-china-sea-2016-7

http://ca.china-embassy.gov.cn/eng/sgxw/202009/t20200913_4615002.htm

# ឧបសម្ព័ន្ធ


南海諸島位置圖
中華民國
湖南省
江西省
福建省
廣東省
廣西省
台灣省
越南
西沙群島
中沙群島
菲律賓
南沙群島


CHINA
Guangzhou
Shantou
Taiwan
Hong Kong
Macau
Kao-hsiung
Hanoi
Haiphong
Zhanjiang
Gulf of Tonkin
Haikou
Hainan Dao
Pratas Island (occupied by Taiwan)
Pratas Reef
Luzon Strait
Helen Shoal
200-meter depth
See "The Paracel Islands"
Paracel Islands
Crescent Group
Amphitrite Group
Chinese claim line
Triton Island
Macclesfield Bank
Da Nang
LAOS
THAILAND
South
China
Sea
Truro Shoal
Scarborough Reef
Luzon
Manila
VIETNAM
CAMBODIA
Phnom Penh
Cam Ranh
Ho Chi Minh City
PHILIPPINES
Mindoro
Calamian Group
Panay
See "The Spratly Islands"
Reed Tablemount
Thitu Reefs
Union Atoll
Spratly Islands
Spratly Island
Malaysian claim line
Philippine (Kalayaan) claim line
Rifleman Bank
Ardasier Reefs
Royal Charlotte Reef
Puerto Princesa
Palawan
Palawan Province
Negros
Sulu Sea
Mindanao
Con Son
Kudat
Kota Kinabalu
Sabah State
Luconia Reefs
Bandar Seri Begawan
BRUNEI
Sulu Archipelago
Kepulauan Natuna
James Shoal
MALAYSIA
INDONESIA
Borneo
Kuching
SINGAPORE
China, Malaysia, Philippines, Taiwan, and Vietnam all have claims to the Spratly Islands. China, Taiwan, and Vietnam claim the Paracels. Claim lines shown on this map are only those relevant to these two island groups.
Scale 1:12,800,000
400 Kilometers
400 Miles
Boundary representation is not necessarily authoritative. Names in Vietnam are shown without diacritical marks.


CHINA
TAIWAN
Hanoi
Hong Kong
Hainan
Scarborough Shoal
Paracel Islands
THAILAND
Manila
VIETNAM
CAMBODIA
Spratly Islands
PHILIPPINES
Ho Chi Minh City
500 km
SOUTH CHINA SEA
Kuala Lumpur
BRUNEI
MALAYSIA
SINGAPORE
INDONESIA
China
Malaysia
Vietnam
Brunei
Philippines
Taiwan

PROCLAMATION

BY THE HEADS OF GOVERNMENTS,

UNITED STATES, CHINA AND THE UNITED KINGDOM

(1) We, the President of the United States, the President of the National Government of the Republic of China and the Prime Minister of Great Britain, representing the hundreds of millions of our countrymen, have conferred and agree that Japan shall be given an opportunity to end this war.

(2) The prodigious land, sea and air forces of the United States, the British Empire and of China, many times reinforced by their armies and air fleets from the west are poised to strike the final blows upon Japan. This military power is sustained and inspired by the determination of all the Allied nations to prosecute the war against Japan until she ceases to resist.

(3) The result of the futile and senseless German resistance to the might of the aroused free peoples of the world stands forth in awful clarity as an example to the people of Japan. The might that now converges on Japan is immeasurably greater than that which, when applied to the resisting Nazis, necessarily laid waste to the lands, the industry and the method of life of the whole German people. The full application of our military power, backed by our resolve, will mean the inevitable and complete destruction of the Japanese armed forces and just as inevitably the utter devastation of the Japanese homeland.

REPUBLIC OF THE PHILIPPINES
DEPARTMENT OF FOREIGN AFFAIRS
MANILA

No. 13-0211

The Department of Foreign Affairs of the Republic of the Philippines presents its compliments to the Embassy of the People's Republic of China and, with respect to the dispute with China over the maritime jurisdiction of the Philippines in the West Philippine Sea, the Government of the Philippines has the honor to submit the attached Notification under Article 287 and Annex VII of the 1982 United Nations Convention on the Law of the Sea (UNCLOS) and the Statement of Claim on which the Notification is based, in order to initiate arbitral proceedings to clearly establish the sovereign rights and jurisdiction of the Philippines over its maritime entitlements in the West Philippine Sea.

The Government of the Philippines has initiated these arbitral proceedings in furtherance of the friendly relations with China, mindful of its obligation under Article 279 of UNCLOS to seek a peaceful and durable resolution of the dispute in the West Philippine Sea by the means indicated in Article 33 (1) of the Charter of the United Nations.

The Department of Foreign Affairs of the Republic of the Philippines avails itself of this opportunity to renew to the Embassy of the People's Republic of China the assurances of its highest consideration.

Manila, 22 January 2013

The Embassy of the People's Republic of China
Manila

Attachments: Notification and Statement of Claims

**United Nations Conference on the Law of the Sea**

Geneva, Switzerland
24 February to 27 April 1958

Document:-
**A/CONF.13/1**

**Historic Bays: Memorandum by the Secretariat of the United Nations**

Extract from the *Official Records of the United Nations Conference on the Law of the Sea, Volume I (Preparatory Documents)*

Copyright © United Nations
2009


YUNGUI PLATEAU
Kunming
Guilin
Nan Ling Mts.
1673
Daiyun Shan
1856
Fuzhou
Min
Hongshui
Hongtu Zhang
1265
Taipei
Taiwan Strait
Yü Shan
3997
TAIWAN
Sakishima Is.
RYŪKYŪ
Guangzhou
Xi
Hong Kong
Mekong
Red
Hanoi
Leizhou Pen.
Qiongzhou (Hainan) Strait
Gulf of Tonkin
1867
HAINAN
Luzon Strait
Babuyan Is.
Plain of Jars
Chiang Mai
Vientiane
CHAÎNE ANNAMITIQUE
INDOCHINA PENINSULA
Khorat Plat.
Da Nang
2598
Paracel Islands
Pulog
2934
LUZON
Mt. Pinatubo
1486
Manila
Taal Volcano
400
Mindoro
PHILIPPINES
Dângrêk Ra.
Bangkok
Tonle Sap
Mekong
South China Sea
Krâvanh Mts.
1813
Phnom Penh
Central Highlands
Calamian Group
Panay
Gulf of Thailand
Ho Chi Minh City
ISTHMUS OF KRA
Mekong Delta
Spratly Islands
Palawan
2085
Negros
Bohol
Sulu Sea
Cà Mau Point
MALAY PENINSULA
Zamboanga
Gunung Kinabalu
4101
Sulu Archipelago
Bandar Seri Begawan
Pinang
Gunung Tahan
2190
Natuna Basar
Celebes Sea
Strait of Malacca
Kuala Lumpur
-5520
Lake Toba
Riau
Singapore
Longnawan
2988
Datu Pen.
Riau Arch.
BORNEO
2913
Makassar Strait
SUMATRA
Pontianak
Batu Is.
Bukit Raya
2278
Barito
Siberut
Barisan Mountains
Bangka I.
SULAWESI
GREATER SUNDA ISLANDS
South Pagai
Belitung I.
Bulu Rantekombola
3455
Java Sea
Makassar
Enggano
Krakatau
Jakarta
Madura I.
JAVA
Surabaya
Bali
Lombok
Gunung Tambora
2850
Gunung Merapi
2914
Gunung Semeru
3676
3142
Sumbawa
Flores
LESSER SUNDA ISLANDS
Sumba
JAVA TRENCH
Christmas I.
-7125
Deepest point in Indian Ocean




*Figure 5: "China's Maximum Potential Entitlements under UNCLOS Compared to its Nine-Dash Line Claim in the Southern Sector" (Memorial, Figure 4.2)*

## No. 1832

# ARGENTINA, AUSTRALIA, BELGIUM, BOLIVIA, BRAZIL, etc.

## Treaty of Peace with Japan (with two declarations). Signed at San Francisco, on 8 September 1951

*Official texts: English, French, Spanish and Japanese.*

*Registered by the United States of America on 21 August 1952.*

---

# ARGENTINE, AUSTRALIE, BELGIQUE, BOLIVIE, BRÉSIL, etc.

## Traité de paix avec le Japon (avec deux déclarations). Signé à San-Francisco, le 8 septembre 1951

*Textes officiels anglais, français, espagnol et japonais.*

*Enregistré par les États-Unis d'Amérique le 21 août 1952.*